01676239

F1/11.1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber
Chambre de la Court Suprême

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីសវនាការបណ្តឹងសាទុក្ខ

# ក្នុងសំណុំរឿង ០០២/០២

## សាធារណៈ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក

**ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១**

**ម៉ោង ០៩:០០នាទី**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-21, 14:45
CMS/CFO: Sann Rada

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រ៊ីម ជាប្រធាន

ចៅក្រម យ៉ា ណារិន

ចៅក្រម ម៉ូរីន ហាឌីង ក្លាក
*(Judge Maureen Harding CLARK)*

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មន្នីចរិយា

ចៅក្រម ផ្លូរិនស៍ ដេផេល វីរឈិន-ម៉ុមបា
*(Judge Florence N. MWACHANDE-MUMBA)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

លោក ផន ធឿន

កញ្ញា ភីស ម៉ាល្លេនី *(Ms. Peace Malleni)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី ប្រេនដា ហូលិស
*(Ms Brenda J. HOLLIS)*

លោក ស្រ៊ា រតនៈ

លោក សេង ប៊ុនឃាង

លោកស្រី នីសា ប៉ាតែល *(Ms Nisha Patel)*

លោកស្រី ហេឡេន វើសនុប *(Ms Helen Worsnop)*

លោកស្រី រូថ ម៉ារី ហេគ្ល័រ
*(Ms Ruth Mary Hackler)*

លោក វីល្លៀម ស្មីត *(Mr.William Smith)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr.Vincent de wilde d'Estmael)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី មេហ្គិន ហ៊ឺសត៍ *(Ms. Megan Hirst)*

លោកស្រី ទី ស្រ៊ីនណា

**មេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ *(Ms. Anta GUISSE )*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្ល សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម គង់ ស្រ៊ឹម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ូរីន ហាឌីង ក្លាក | អង់គ្លេស |
| ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ | អង់គ្លេស |
| ចៅក្រម ម៉ុង មុន្នីចរិយា | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោកស្រី រូថ ម៉ារី ហេគ័រ | អង់គ្លេស |
| លោកស្រី ប្រេនដា ហូលិស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គិសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| ក្រឡាបញ្ជី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០០:៣៣]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមប្រកាសបន្តសវនាការ។ ហើយថ្ងៃនេះ ជាថ្ងៃទីបី ហើយ គឺថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ បន្តសវនាការថ្ងៃនេះគឺក្រឡាបញ្ជីត្រូវបានមានការផ្លាស់ប្ដូរពីលោកក្រឡាបញ្ជី ស៊ា ម៉ៅ មកលោក ក្រឡាបញ្ជី ផន ធឿន។ ហើយសូមលោកក្រឡាបញ្ជី រាយការណ៍អំពីវត្តមាន។

**ក្រឡាបញ្ជី៖**

ឯកឧត្ដមប្រធាន យើងខាងព្រះរាជអាជ្ញា គឺមានព្រះរាជអាជ្ញាជាតិ លោកជំទាវ ជា លាង ព្រះរាជអាជ្ញាអន្តរជាតិ ប្រេនដា ជេ ហូលិស ហើយចំពោះសហមេធាវី ខៀវ សំផន វិញយើងមានលោក គង់ សំអុន និងលោកស្រី អង់តា ហ្គីសសេ។ ហើយយើងមានវត្តមានជនជាប់ចោទ លោក ខៀវ សំផន ផងដែរ។ ខាងដើមបណ្ដឹងរដ្ឋប្បវេណី គឺសហមេធាវី មានលោក ពេជ អង្គ និងលោកស្រី មេហ្គិន ហ៊ីសត៍។ យើងមានការចូលរួមពីដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ គឺលោក រ័ត្ន ពុន លោកស្រី--លោក វិត វុន លោកស្រី ម៉ោក ផល្លា លោកស្រី ផេន សន អ្នកស្រី ប៊ុន សំអឿន និងអ្នកស្រី បិត លន់។ សូមអរគុណឯកឧត្ដមប្រធាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាបន្តនេះ គឺសូមអញ្ជើញសហចៅក្រមរបាយការណ៍ដើម្បីធ្វើរបាយការណ៍អំពីទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន។ សូមអញ្ជើញ!

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

សូមជម្រាបសួរ ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីទាំងអស់។ ខ្ញុំសូមធ្វើរបាយការណ៍ក្នុងនាមលោកចៅក្រម សោម សិរីវឌ្ឍ និងខ្ញុំចៅក្រម ក្លាក។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលបានរៀបរាប់ពីខាងលើក្រោមទម្រង់នៃ

ការទទួលខុសត្រូវពីសហឧក្រិដ្ឋកម្មរួម និងការជួយទំនុកបម្រុងដល់បទឧក្រិដ្ឋនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មមនុស្សជាតិដែលពុំស្ថិតក្នុងសហឧក្រិដ្ឋកម្មរួម។ ដំបូងជនជាប់ចោទ ត្រូវបានសម្រេចដាក់ពិរុទ្ធភាពក្រោមទម្រង់នៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលតាមរយៈការចូលរួមរបស់គាត់ក្នុងគោល-បំណងរួម និងរួមចំណែកក្នុងចេតនាឧក្រិដ្ឋដូចគ្នានៃសហឧក្រិដ្ឋកម្មរួម។ ការសម្រេចដាក់ពិរុទ្ធភាពទាំងនោះ គឺសម្រាប់បទឧក្រិដ្ឋដែលប្រព្រឹត្តក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយ ប្រាំចំណុចរបស់បក្សកុម្មុយនីស្តកម្ពុជាពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយទាំងនោះមាន៖ ១) ការផ្លាស់ទីប្រជាជនពីទីក្រុងទៅតាមជនបទនានា ២) ការបង្កើតនិងការប្រតិបត្តិសហករណ៍ និងការដ្ឋានធ្វើការ ៣) ការបង្កើតនិងប្រតិបត្តិមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ទី៤) ការកំណត់គោលដៅក្រុមជាក់លាក់ដូចជា ជនជាតិចាម វៀតណាម អ្នកកាន់ពុទ្ធសាសនា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ និង ៥) បទបញ្ញាលៀបអាពាហ៍ពិពាហ៍។

[០៩:០៥:១៦]

ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទសម្រាប់បទឧក្រិដ្ឋដោយសារជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម បានផ្អែកលើមូលដ្ឋានថា គាត់បានចូលរួមចំណែកក្នុងចេតនារើសអើងជាក់លាក់និងផ្ទាល់ជាមួយសមាជិកនៃសហឧក្រិដ្ឋរួមដទៃទៀត។ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្តរហូតមកដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ជនជាប់ចោទដែលគេមេដឹកនាំជាន់ខ្ពស់ក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជាបានចូលរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម និងគោលបំណងរួម ដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមឆាប់រហ័សក្នុងកម្ពុជាតាមរយៈផែនការមហាលោតផ្លោះ មហាអស្ចារ្យដែលបានបង្កើតឡើងដើម្បីកសាងប្រទេស ការពារពីសត្រូវ និងប្រែក្លាយប្រជាជនទាំងស្រុងឱ្យទៅជាសង្គមកម្មករ កសិករខ្មែរមួយដែលគ្មានការបែងចែកវណ្ណៈ និងសាសនា។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលបំណងរួមនេះពុំមែនជាបទឧក្រិដ្ឋចាំបាច់ទៅខ្លួនឯងផ្ទាល់នោះទេ។ ប៉ុន្តែតាមការអនុវត្តជោគជ័យនៃគោលបំណងជាចុងក្រោយបានកំណត់ចរិតលក្ខណៈឧក្រិដ្ឋនៃគោលបំណងរួមនេះ ដោយសារគោលបំណងនេះ អាចកើតឡើងបានអាស្រ័យលើការអនុវត្តគោលនយោបាយអាក្រក់ និងការលុបបំបាត់សមាសធាតុទាំងអស់ដែលប្រឆាំងបដិវត្តន៍។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា តួនាទីរបស់ជនជាប់ចោទក្នុងគោលបំណងរួមមានអាទិភាពតាមរយៈការរួមចំណែករបស់គាត់យ៉ាងសំខាន់នៅ

ក្នុងការគាំទ្រជាសាធារណៈ ការជំរុញ និងការយល់ព្រមតាមគោលដៅ តាមរយៈតួនាទីជាន់ខ្ពស់របស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ និងតាមរយៈការដឹកនាំផ្ទាល់ខ្លួននៃវគ្គរៀនសូត្រ និងការជួបជុំដែលបានណែនាំ បញ្ចុះបញ្ចូល និងផ្តល់ការគាំទ្រដល់គោលនយោបាយបក្សកុម្មុយ-នីស្តកម្ពុជា។ ទី២ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងតួនាទីជាន់ខ្ពស់របស់គាត់នៅក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា ជនជាប់ចោទបានជួយទំនុកបម្រុងបទឧក្រិដ្ឋនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយចេតនាប្រយោលនៅតាមទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋនានា។ ជនជាប់ចោទជានិច្ចកាលតែងតែបដិសេធថា គាត់មានតួនាទី និងមុខតំណែងជាន់ខ្ពស់ក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬថា គាត់បានដឹងនូវអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតក្រៅដែនកំណត់នៃការទទួលខុសត្រូវរបស់គាត់ ដែលមានត្រឹមតែការបញ្ជាទិញ និងការចែកចាយរបស់ចាំបាច់ដូចជាថ្នាំពេទ្យជាដើម និងការទំនាក់ទំនងរវាងសម្តេចព្រះ នរោត្តម សីហនុ និងបក្សកុម្មុយនីស្តកម្ពុជា និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលមានឈ្មោះ -- ដែលមានតែឈ្មោះ។ គាត់បានលើកទឡ្ហីករណ៍ផ្សេងៗនៃបណ្តឹងសាទុក្ខ ពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់គាត់ក្រោមទម្រង់នៃការទទួលខុសត្រូវទាំងពីរប្រភេទ។ ទាក់ទងនឹងការទទួលខុសត្រូវក្រោមទម្រង់នៃសហឧក្រិដ្ឋរួម ជនជាប់ចោទបានលើកអំណះអំណាងជាច្រើនប្រឆាំងនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះភស្តុតាង និងការយល់ឃើញ ដែលអំណះអំណាងនេះអាចត្រូវបានដាក់តាមប្រភេទនិងសង្ខេបដូចខាងក្រោម។ អំណះអំណាងទី១ ពាក់ព័ន្ធទៅនឹងមូលដ្ឋានផ្លូវច្បាប់នៃពាក្យសំណើស្តីពីការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម។

[០៩:០៨:៣០]

ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសជាច្រើនផ្សេងៗគ្នា។ កំហុសទី១ កើតឡើងនៅពេលដែលអង្គជំនុំជម្រះបានយកបទដ្ឋានផ្លូវច្បាប់ពុំត្រឹមត្រូវមកអនុវត្តក្នុងការវាយតម្លៃទំនាក់ទំនងរវាងចារីផ្ទាល់ និងអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។ គាត់បានលើកឡើងថា នៅពេលដែលអ្នកចូលរួមម្នាក់ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះអំពើដែលប្រព្រឹត្តដោយចារីដទៃទៀតនោះ គឺតម្រូវឲ្យមានការកំណត់និយមន័យមួយដែលមានលក្ខណៈចង្អៀតអំពីបំណងរួមនេះ។ ជនជាប់ចោទក៏បានជំទាស់ទៀតថា គោលបំណងនៃសហឧក្រិដ្ឋកម្មរួមអាចវិវឌ្ឍតាមពេលវេលា ដូច្នេះអាចរួមបញ្ចូលបទឧក្រិដ្ឋថែមទៀតនៅក្នុងគោលបំណងរួមនោះ។ ប៉ុន្តែគាត់អះអាងថា ការវិវឌ្ឍនិងចំណុចដែលថា សមាជិកនៃសហឧក្រិដ្ឋរួមបានដឹងអំពីការប្រព្រឹត្តបទឧក្រិដ្ឋដែលបានបន្ថែមនោះពុំត្រូវបានពណ៌នា

ឲ្យបានច្បាស់លាស់ ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ ទី២ ជនជាប់ចោទ ជំទាស់ទៅនឹងទស្សនៈដែលថា បទឧក្រិដ្ឋដែលបានប្រព្រឹត្តក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួមអាចជាអំពើអកម្ម។ ទី៣ គាត់អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលបានបន្ទាបបទដ្ឋាននៃចេតនាផ្ទាល់តម្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។ អំណះអំណាងទី២ គឺពាក់ព័ន្ធទៅនឹងគោលបំណងរួម។ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសបីសំខាន់ៗ។

[០៩:០៩:៥១]

ដោយសារគោលបំណងរួមដែលបានកំណត់អត្តសញ្ញាណដែលអង្គជំនុំជម្រះសាលាដំបូងដែលជាការអនុវត្តនៃបដិវត្តន៍សង្គមនិយមឆាប់រហ័សនោះ ពុំមែនជាបទឧក្រិដ្ឋខ្លួនឯងផ្ទាល់ ទើបអង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលយល់ឃើញថា គោលបំណងរួមក្លាយជាបទល្មើសដោយសារមានការប្រព្រឹត្តបទឧក្រិដ្ឋក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាជាងតាមរយៈការពិនិត្យលើផែនការនយោបាយ ដែលពុំមែនជាបទល្មើសរបស់បក្សកុម្មុយនីស្តកម្ពុជា។

បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបន្ទាបលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម ដោយអង្គជំនុំជម្រះបានកំណត់យកលក្ខណៈឧក្រិដ្ឋនៃសហឧក្រិដ្ឋកម្មរួមផ្អែកលើគោលនយោបាយជាជាងលើគោលបំណងរួម។

អំណះអំណាងទី៣ គឺពាក់ព័ន្ធទៅនឹងការយល់ឃើញអំពីការរួមចំណែករបស់ជនជាប់ចោទនៅក្នុងការអនុវត្តគោលបំណងរួម។ ដំបូងជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ដោយសារពុំមានភស្តុតាងគ្រប់គ្រាន់អាចឲ្យយល់ឃើញថា គាត់បានរួមចំណែកយ៉ាងសំខាន់ក្នុងបទឧក្រិដ្ឋ ឬថាអង្គជំនុំជម្រះខកខានក្នុងការបង្ហាញភស្តុតាងអំពីការរួមចំណែកយ៉ាងសំខាន់ដែលជាធាតុផ្សំចាំបាច់សម្រាប់ការទទួលខុសត្រូវក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម។ ពិសេសជាងនេះទៅទៀតគាត់បានអះអាងថា ការពាក់ព័ន្ធរបស់គាត់ជាមួយនឹងសមាជិកនៃគណៈអចិន្ត្រៃយ៍ពុំមានលក្ខណៈ គ្រប់គ្រាន់ក្នុងការបង្ហាញនៃការរួមចំណែកយ៉ាងសំខាន់ នៅក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយឡើយ។ ទី២ គាត់បានជំទាស់ទៅលើភាពគ្រប់គ្រាន់នៃភស្តុតាងសម្រាប់ការយល់ឃើញ អំពីអង្គហេតុជាក់លាក់ស្តីពីតួនាទីរបស់គាត់ និងសិទ្ធិអំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ។ ទី៣ គាត់បានលើកឡើងថា ការវាយតម្លៃលើភស្តុតាងដើម្បីបង្ហាញពីការរួមចំណែករបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមមានលក្ខណៈលម្អៀង និងមិនបានគ្រប់ជ្រុងជ្រោយ។ អង្គជំនុំជម្រះតុលាការ

កំពូលស្វាគមន៍ការបង្ហាញជាក់លាក់លើបញ្ហានេះ។

[០៩:១១:៤៧]

អំណះអំណាងចុងក្រោយគឺពាក់ព័ន្ធទៅនឹងការដឹងរបស់ជនជាប់ចោទអំពីបទឧក្រិដ្ឋ។ គួររំឭកថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ តម្រូវឲ្យមានចេតនាផ្ទាល់ និងការដឹងអំពីបទឧក្រិដ្ឋ។ តាមការអះអាងគាត់បានលើកឡើងជាញឹកញាប់ថា គាត់ពុំបានដឹងអំពីបទឧក្រិដ្ឋ និងជាពិសេសអំពីលក្ខខណ្ឌរស់នៅ និងធ្វើការដែលបានដាក់នៅសហករណ៍ និងការដ្ឋានការងារឡើយ។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងជាទូទៅពុំបានទទួលស្គាល់អំពីគោលការណ៍តឹងរ៉ឹងនៃការសម្ងាត់ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងថាការយល់ឃើញពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីប្រព័ន្ធនៃទំនាក់ទំនងនៃបក្សកុម្មុយនីស្តកម្ពុជាមានកំហុស។ គាត់បានអះអាងថា គាត់ពុំបានដឹងពិតប្រាកដអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តទូទាំងប្រទេស។ ចំពោះការទទួលខុសត្រូវរបស់គាត់ដោយសារការជួយទំនុកបម្រុង គាត់អះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងអង្គហេតុនិងអង្គច្បាប់។

គាត់លើកអំណះអំណាងពីរសំខាន់ៗ។ ទី១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យពុំត្រឹមត្រូវអំពីធាតុផ្សំអត្តនោម័តិម័តិនៃការជួយទំនុកបម្រុង។ នៅពេលដែលអង្គជំនុំជម្រះបានអនុម័តតាមបទដ្ឋានដែលថា ដើម្បីឲ្យជនជាប់ចោទជាប់ពិរុទ្ធចំពោះការទទួលខុសត្រូវដែលជាការផ្សំគំនិត គាត់ត្រូវតែដឹងថា បទឧក្រិដ្ឋទំនងជាត្រូវបានប្រព្រឹត្តឡើង។ អង្គជំនុំជម្រះសាលាដំបូងបន្ទាប់មកអនុវត្តដែលពុំសមហេតុផលនូវចេតនាក្នុងកម្រិតមួយទាបជាង ដែលពុំត្រូវបានគ្របដណ្តប់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលច្បាប់នេះមានអត្ថិភាពក្នុងពេលដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង។ គាត់ជំទាស់ជាពិសេសទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ តាមរយៈសេចក្តីសម្រេចស្តីពីការជួយទំនុកបម្រុងនៅក្នុងរឿងក្តីហ្វូរ៉ាន់ឌីចាអាគេយិស្ស៊ូ និង ប៉ាស៊ីគិច។

[០៩:១៣:៤២]

គាត់ជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ភាពផ្សំអត្តនោម័តិនៃការជួយទំនុកបម្រុងយកទៅតាមបង្ហាញ។ ការយល់ឃើញដែលថានៅពេលនោះគាត់បានដឹងអំពីធាតុផ្សំចាំបាច់នៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ ត្រូវបដិសេធ ដែលគាត់លើកឡើងថាមានភស្តុតាងគាំទ្រការជំទាស់របស់គាត់ដែលថា គាត់ពុំបានដឹងអំពីភរនីយភាព ដែលថាការស្តាប់បណ្តាល

មកពីលក្ខខណ្ឌដែលបានដាក់ចេញទៅតាមការដ្ឋានធ្វើការ និងសហករណ៍ និងពុំបានដឹងថាអំពើមនុស្សឃាតត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សឡើយ។ ជនជាប់ចោទអាចប្រាប់អង្គជំនុំជម្រះអំពីភស្តុតាងដែលគាំទ្រដោយអំណះអំណាងរបស់ខ្លួន ដែលថាជនជាប់ចោទពុំបានដឹងអំពីការស្លាប់ និងការសម្លាប់នៅកន្លែងទាំងនោះ។ ទី២ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថាធាតុផ្សំសត្យានុម័តនៃការជួយទំនុកបម្រុងក្នុងអំពើមនុស្សឃាតដោយចេតនាប្រយោល បំពេញតាមលក្ខខណ្ឌតម្រូវនៅតាមការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខនានា។ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការគាំទ្រផ្នែកសីលធម៌ ការលើកទឹកចិត្តដោយប្រយោល ឬការជួយជាក់ស្តែងដល់ស្ថាប័នធ្វើសេចក្តីសម្រេចនៃបក្សកុម្មុយនីស្តកម្ពុជា និងទស្សនកិច្ចតាមកន្លែងមួយចំនួន នេះជះឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តអំពើមនុស្សឃាតទាំងនោះ។

ចុងក្រោយជនជាប់ចោទអះអាងថា ត្រឹមតែវត្តមានរបស់គាត់នៅពេលប្រជុំពុំអាចស្មើទៅនឹងការជួយទំនុកបម្រុងឡើយ។ ជាថ្មីម្តងទៀត គាត់បានជំទាស់ទៅនឹងភាពត្រឹមត្រូវតាមច្បាប់នៃការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសេចក្តីសម្រេចស្តីពីការជួយទំនុកបម្រុងនៅក្នុងរឿងក្តី ហ្វូរ៉ាន់ឌីចាអាគេយិស៊្វ និង ប៉ាស៊ីគិច។ ខ្ញុំសូមបញ្ចប់របាយការណ៍ស្តីពីទឡ្ហីករណ៍បណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ ហើយនៅមុនពេលដែលខ្ញុំប្រគល់វេទិកាទៅដល់ភាគី ខ្ញុំសូមជម្រាបទាំងព្រះរាជអាជ្ញា និងមេធាវីការពារក្តីអំ -- ដូចខ្ញុំបានរៀប -- ផ្តល់ព័ត៌មានច្រើនដងរួចមកហើយគឺថា សូមឲ្យផ្តោតទៅលើការបង្ហាញមកអង្គជំនុំជម្រះនេះនូវភស្តុតាងដោះបន្ទុក ដែលពួកគេបានចោទជាច្រើនដងថា អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណា។

ហើយនៅក្នុងរបាយការណ៍នេះ ក៏ខ្ញុំបានបញ្ជាក់ផងដែរឲ្យបង្ហាញភស្តុតាងដោះបន្ទុក។ ហើយប្រហែលជាខ្ញុំមិនអាចសួរសំណួរទាំងអស់នេះនៅថ្ងៃនេះទេ ប៉ុន្តែប្រហែលជាស្អែកខ្ញុំនឹងសួរបន្ថែមទៀតរឿងភស្តុតាងដោះបន្ទុកនេះ។ សូមអរគុណ។

[០៩:១៦:១៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីការពារក្តីធ្វើសារណា។

**លោកស្រី អង់តា ហ្គីសសេ៖**

សូមគោរពលោកប្រធាន លោក លោកស្រីជាទី - លោកស្រីចៅក្រម។ សូមអរគុណដែលផ្តល់

វេទិកានេះជូនខ្ញុំពាក់ព័ន្ធនឹងប្រធានដ៏សំខាន់មួយនេះ។ ខ្ញុំនិយាយអំពីការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលរបស់លោក ខៀវ សំផន។ យើងដឹងអំពីការលំបាកនៃភារកិច្ចនេះ ក៏ប៉ុន្តែវាមិនងាយស្រួលទេក្នុងការបង្ហាញខ្លួនពីរដងនៅចំពោះមុខចៅក្រមស្ទើរតែដដែល ដោយសង្ឃឹមថានឹងទទួលបានលទ្ធផលផ្សេងពីអ្វីដែលបានសម្រេចរួចទៅហើយទៅលើបញ្ហាគតិយុត្តដូចគ្នានេះ។ ការនិយាយអំពីសហឧក្រិដ្ឋកម្មរួមដែលខ្ញុំធ្វើនៅពេលនេះ ទុកដូចជាសញ្ញាណនៃអំពើមនុស្សឃាតដោយចេតនាប្រយោលនោះតម្រូវឱ្យពន្យល់ថាហេតុអ្វីបានជាយើងយល់ឃើញថា តុលាការកំពូលមានការភ័ន្តច្រឡំក្នុងសំណុំរឿង០០២/០១។ វាមិនមែនជាការងាយស្រួលទេក្នុងការនិយាយអំពី -- និយាយទៅកាន់ចៅក្រមដែលទទួលបន្ទុកជោគវាសនារបស់ជនជាប់ចោទថា ពួកគាត់មានកំហុសនោះ។ ហើយខ្ញុំគិតទៅដល់ចៅក្រមដែលបានសង្ខេបអំពីភារកិច្ចរបស់ខ្លួនយ៉ាងល្អបំផុតគឺចៅក្រម បាកូណេស៊ុយស្ទីស ម៉ូឡូតូ ជាចៅក្រមអាហ្វ្រិកខាងត្បូងនៅចំពោះមុខអតីតតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលបានធ្វើអន្តរាគមន៍នៅក្នុងសន្និសីទមួយអំពីសារៈសំខាន់នៃតួនាទីរបស់មេធាវីការពារក្ដី។ ហើយគាត់និយាយទៅកាន់មេធាវីថា មុខងារដ៏សំខាន់បំផុតដែលមេធាវីការពារក្ដីត្រូវតែគិតដល់គ្រប់ពេលវេលានោះគឺថា មានលក្ខណៈច្បាស់លាស់ណាស់ គឺត្រូវតែការពារកូនក្ដីរបស់ខ្លួន និងការពារកូនក្ដីតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន។ ការបដិសេធមិនទទួលយកនូវការគំរាមកំហែងពីអ្នកផ្សេងក្នុងការអនុវត្តភារកិច្ចនេះ ទោះជាអ្នកណាក៏ដោយ ជាព្រះរាជអាជ្ញា ជាចៅក្រម ឬក៏ជាអ្នកណាក៏ដោយ គឺត្រូវមិនត្រូវខ្លាចទេ។ ការងាររបស់យើងគឺការពារកូនក្ដីរបស់ខ្លួនរហូតទៅដល់ចប់សវនាការ ទោះជាបានលទ្ធផលយ៉ាងម៉េចក៏ដោយ។ យើងអាចនិយាយបានថា ខ្ញុំធ្វើអស់លទ្ធភាពហើយអ៊ីចឹងខ្ញុំអាចដេកលក់ស្រួលហើយ។ អ៊ីចឹងខ្ញុំមិនត្រូវមានការព្រួយបារម្ភអីទេ គឺថាត្រូវតែធ្វើយ៉ាងម៉េចដើម្បីដោះស្រាយការងាររបស់ខ្ញុំ ហើយអ៊ីចឹងខ្ញុំនឹងនិយាយអំពីទម្រង់នៃការទទួលខុសត្រូវដែលអង្គជំនុំជម្រះចោទប្រកាន់ទៅលើ ខៀវ សំផន គឺសហឧក្រិដ្ឋកម្មរួម និងការជួយជំរុញ។

[០៩:១៩:២៣]

ខ្ញុំនឹងនិយាយអំពីសហឧក្រិដ្ឋកម្មរួម។ ជាដំបូង នៅពេលដែលនិយាយអំពីការផ្ដន្ទាទោស ខៀវ សំផន សហព្រះរាជអាជ្ញា និងចៅក្រមសាលាដំបូង ក៏ដូចជាតុលាការកំពូល គឺប្រឈមមុខទៅនឹងការលំបាកពីរ។ ទី១ គឺគោលបំណងរួម ដូចដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតហ្នឹង គឺវាមិនមានលក្ខណៈឧក្រិដ្ឋទេ វាគ្រាន់តែជាផែនការនយោបាយ ជាគោលបំណងនយោបាយតែប៉ុណ្ណោះ។ ទី២ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ គឺ

មិនមែនជាច្បាប់អន្តរជាតិទំនៀមទម្លាប់នៅសម័យនោះទេ។ ចំពោះយើងការលំបាកទាំងពីរនេះគឺចំណុចស្នូលនៃកំហុសរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវ ខៀវ សំផន គឺមានការព្យាយាមបញ្ចូលឧក្រិដ្ឋកម្មនៅក្នុងគោលបំណងរួម ឬក៏មានការព្យាយាមបញ្ចូលនូវសញ្ញាណនៃភវនីយភាពនៃទម្រង់ទី៣ ទៅក្នុងធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១។

នេះជាអ្វីដែលយើងបានបញ្ជាក់រួចទៅហើយនៅក្នុងសំណុំរឿង០០២/០២ គឺសារណារបស់យើង គឺឯកសារ D457/6/4/1 កថាខណ្ឌ៤៣០ ទៅដល់ ៥១៦ ដែលយើងបាននិយាយអំពីសហឧក្រិដ្ឋកម្មរួមកូនកាត់។ ដើម្បីបញ្ចៀសនូវបញ្ហាទាំងពីរនេះ អង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាអង្គជំនុំជម្រះតុលាការកំពូលបានប្រថុយប្រថានក្នុងការកំណត់ឡើងវិញនូវធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម។

អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០២/០១ បានពង្រីកធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ដើម្បីដាក់បញ្ចូលនូវសញ្ញាណនៃចេតនាដោយប្រយោល។

សាលាដំបូងវិញ នៅក្នុងសំណុំរឿង០០២/០២ បានបដិសេធ គឺថាវាផ្ទុយទៅនឹងច្បាប់នៃការកំណត់ឡើងវិញនេះ។ ក៏ប៉ុន្តែដើម្បីទទួលបានលទ្ធផលដូចគ្នានេះ សាលាដំបូងបានកំណត់ឡើងវិញនូវគោលបំណងរួម។ ក្នុងករណីទាំងពីរនេះ លោក ខៀវ សំផន ត្រូវបានប្រកាសថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋដែលគាត់មិនបានចូលរួមដោយផ្ទាល់ ហើយគាត់ក៏មិនដែលមានចេតនា -- ធាតុផ្សំអត្តនោម័តិដែរ ហើយឧក្រិដ្ឋកម្មហ្នឹងត្រូវបានប្រព្រឹត្តទៅដោយបុគ្គលដែលគាត់មិនមានការគ្រប់គ្រងទេ។ ខ្ញុំសូមយោងទៅទទ្បីករណ៍របស់យើងនៅក្នុងសារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៩៤៧ ដល់ ១៩៥៣។

[០៩:២២:២២]

ជាបឋម អង្គជំនុំជម្រះសាលាដំបូងមិនគោរពតាមការបកស្រាយរបស់តុលាការកំពូលទេ។ ខ្ញុំសុំយោងទៅសំអាងហេតុនៃសាលក្រមកថាខណ្ឌ៣៧១៥។ អង្គជំនុំជម្រះនិយាយពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួម។ គាត់បានពន្យល់ថា អង្គជំនុំជម្រះយល់ឃើញថា ចេតនាដែលជាធាតុផ្សំបង្កើតជានិយមន័យនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ពុំអាចក្លាយជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១បានទេ។

អង្គជំនុំជម្រះសាលាដំបូងបានត្រឡប់មកការកំណត់នូវលក្ខណៈវិនិច្ឆ័យត្រឹមត្រូវ ដែលបានរិះគន់អ្វីដែលសហព្រះរាជអាជ្ញាធ្វើឡើង គឺនៅកថាខណ្ឌ៣៧១៦ ដែលអង្គជំនុំជម្រះបានយោងទៅលើដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាដែលបានបញ្ជាក់ថា ដូច្នេះបទដ្ឋានដែលសហព្រះរាជអាជ្ញាបាន

រៀបរាប់ថាជាចេតនាដោយចំពោះកម្រិតទី២ ពិតណាស់ គឺមានកម្រិតទាបជាងចេតនាដោយចំពោះ ដែលវាមានកម្រិតស្មើ -- ស្មើរតែស្មើនឹងសញ្ញាណនៃការធ្វេសប្រហែស និងចេតនាដោយប្រយោល។

[០៩:២៥:១០]

ពេលនិយាយអ៊ីចឹងនឹងរួចហើយនោះ អង្គជំនុំជម្រះបានកំណត់នូវផែនការគោលបំណងរួមដែលបានកំណត់នូវផែនការដែលនាំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម គឺថាឧក្រិដ្ឋកម្មត្រូវតែប្រព្រឹត្ត ដែលវាស្មើទៅនឹងចេតនាផ្ទាល់នៅកម្រិតទី២។ ខ្ញុំសូមយោងទៅកថាខណ្ឌ៤០៦៨ នៃសាលក្រម ០០២/០២។ អង្គជំនុំជម្រះយល់ឃើញថា គោលបំណង -- គោលនយោបាយទាំងអស់នេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងគោលបំណងរួម ហើយមានការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ដូច្នេះអង្គជំនុំជម្រះយល់ឃើញថា គោលបំណងរួមនេះមានផ្ទាល់នេះ វាមានលក្ខណៈឧក្រិដ្ឋ។ ដូច្នេះនេះមិនមែនជាការនិយាយនៅក្នុងដីកាដំណោះស្រាយទេ។ ដូច្នេះវាមានការពង្រីកធៀបទៅនឹងដីកាដំណោះស្រាយ។

នៅក្នុងសារណាបណ្តឹងសាទុក្ខ យើងបានរិះគន់សញ្ញាណនៃគោលនយោបាយដែលជាប់ពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធនេះ ដែលវាពាក់ព័ន្ធជាថ្មីម្តងទៀតទៅនឹងការពោល -- ការប៉ុនប៉ងពង្រីកផែនការរួមដើម្បីដាក់បញ្ចូលឧក្រិដ្ឋកម្មដែលមិនមាននៅក្នុងគោលបំណងនេះ។ ខ្ញុំសូមយោងទៅសារណារបស់យើងគឺកថាខណ្ឌ១៩៦៨ ដល់ ១៩៨០ និង ១៩៨១ ដល់ ២០០៧។ ជាការឆ្លើយតបទៅវិញនោះ សហព្រះរាជអាជ្ញាបានអះអាងថា មេធាវីការពារក្តី គឺនៅកថាខណ្ឌ៩៥៤ នៅចម្លើយតបរបស់សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាបាននិយាយថា មេធាវីការពារក្តី ខ្ញុំសុំដកស្រង់៖ “កម្រិតនៃការវិភាគផ្លូវច្បាប់របស់ខ្លួនត្រឹមសហឧក្រិដ្ឋកម្មរួមដែលផែនការរួមនាំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មជាជាងការពិចារណាទៅលើសហឧក្រិដ្ឋកម្មរួមដែលខ្លួនបានយល់ឃើញ ហើយដែលតម្រូវឲ្យមាន -- ដែលនាំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម”។ សូមបញ្ចប់ការដកស្រង់។

[០៩:២៦:២៣]

តាមសហព្រះរាជអាជ្ញា គោលបំណងរួមនាំឲ្យការប្រព្រឹត្តឧក្រិដ្ឋកម្ម ទោះបីជាគោលបំណងរួមហ្នឹង វាមិនមែនជាឧក្រិដ្ឋកម្មក៏ដោយ ហើយនៅពេលដែលឧក្រិដ្ឋកម្មនោះវាបង្កើតបានជាមធ្យោបាយក្នុងការនាំទៅរកការសម្រេចនូវគោលបំណងចុងក្រោយ។ ដូច្នេះ គោលបំណងក្នុងការបង្កើតបដិវត្តន៍សង្គមនិយមនោះ ត្រូវតែវាយតម្លៃរួមគ្នាជាមួយនឹងមធ្យោបាយដែលបានប្រើប្រាស់ដើម្បីសម្រេច គឺមានន័យថា គោលនយោបាយនៃបក្សកុម្មុយនីស្តកម្ពុជា ដែលជាកម្មវត្ថុនៃសំណុំរឿង០០២ គឺកថាខណ្ឌ៩៥៤ នៃ

សាលដីកា។ នៅពេលនោះ យើងក៏បានបកទៅវិញថា ការរៀបរាប់យ៉ាងវែងអន្លាយនៃអង្គហេតុរបស់សហព្រះរាជអាជ្ញានេះ វាមិនបង្ហាញអីទាល់តែសោះអំពីទំនាក់ទំនងហេតុ និងបច្ច័យផ្ទាល់ គឺមានន័យថា ការចូលរួមនៃគម្រោងបដិវត្តន៍សង្គមនិយមៗវានាំដោយចៀសមិនរួចទៅដល់ការកំណត់ និងការអនុវត្តគោលនយោបាយដែលដូចដែលបានកំណត់ដោយសាលាដំបូងនៅក្នុងសំណុំរឿងយើង។

សហព្រះរាជអាជ្ញាមិនបានបង្ហាញទាល់តែសោះថាតើមធ្យោបាយហ្នឹង គឺជាមធ្យោបាយតែមួយគត់ដែលអាចមាន ដែលធ្វើឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដោយចៀសមិនរួច ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ ឧទាហរណ៍ ដូចជានៅក្នុងករណីជម្លៀសដោយបង្ខំ នៅពេលដែលគោលបំណងហ្នឹងគឺថាវាគឺថាបង្កើតឡើងហ្នឹងគឺដោយការបង្ខំ ដើម្បីបង្កើតនូវដែនដីមួយដែលមានតែជនជាតិតែមួយ។

[០៩:២៨:០៥]

ក្នុងសំណុំរឿង០០២ហ្នឹង ច្បាស់ណាស់ថាមធ្យោបាយដែលបានប្រើប្រាស់សម្រេចបដិវត្តន៍សង្គមនិយមហ្នឹង គឺថាវាច្បាស់លាស់ណាស់ គឺថាអត់មានទំនាក់ទំនងហេតុនិងបច្ច័យ ហើយនិងភាពមិនអាចចៀសវាងបានរវាងគោលបំណង និងមធ្យោបាយដែលកំណត់ដោយអង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញានោះទេ គឺគោលនយោបាយ។

ខ្ញុំសូមសង្កត់ធ្ងន់ទៅលើចំណុចនេះ គឺថាដូចអ្វីដែលបានកំណត់ដោយអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតនេះ ពីព្រោះថា ជាថ្មីម្ដងទៀត ខាងមេធាវីការការពារក្ដីលោក ខៀវ សំផន យើងបានជំទាស់ថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចដែលលោក ខៀវ សំផន បានស្គាល់នោះ គឺបដិវត្តន៍សង្គមនិយមនោះ គឺថាវាមានការកំណត់នៅក្នុងសំណុំរឿងយើងនេះ។

សហព្រះរាជអាជ្ញាអះអាងថា ការបែងចែកបំបែកគោលនយោបាយចេញពីបដិវត្តន៍ហ្នឹងវានាំឲ្យមានការបែងចែកមិនត្រឹមត្រូវ និងក្លែងក្លាយ ដោយហេតុថា គោលបំណងរួមហ្នឹងត្រូវតែមានគោលដៅ និងមធ្យោបាយ កថាខណ្ឌ៩៥៥ នៃការឆ្លើយតបរបស់ខ្លួន។ បើតាមសហព្រះរាជអាជ្ញាហ្នឹង គឺថាការផ្ដោតរបស់ម្ចាស់បណ្ដឹងសាទុក្ខលើគោលបំណងរួម មិនមែនជាឧក្រិដ្ឋកម្មដែលចោទឡើង ដែលបានចោទឡើងនេះ និងថាឧក្រិដ្ឋកម្មចាកឆ្ងាយពីគោលបំណងរួម វាមានភាពអរូបិយ និងមិនពាក់ព័ន្ធនឹងមើលរំលងនៃការពិត។

ក៏ប៉ុន្តែយើងឃើញថា ដោយសារតែមិនមានទឡ្ហីករណ៍ដើម្បីបង្ហាញអំពីទំនាក់ទំនងហេតុ និងបច្ច័យ និងភាពមិនអាចៀសវាងបាននៃបដិវត្តន៍ និងគោលនយោបាយ សហព្រះរាជអាជ្ញាបានតែត្រឹមតែ

ពន្យល់ថា ការបែងចែកហ្នឹងគឺថាវាមិនសមហេតុផល ហើយវាៗសិប្បនិមិត្ត។

[០៩:២៩:៥៦]

ក៏ប៉ុន្តែជំហររបស់លោក ខៀវ សំផន ហ្នឹងគឺថា គោលនយោបាយឬក៏ផែនការបដិវត្តដែលវាមិនពាក់ព័ន្ធទៅនឹងអ្វីដែលរៀបរាប់ដោយសហព្រះរាជអាជ្ញា ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូងទេ។ ទំនាក់ទំនងហេតុនិងបច្ច័យ ហើយនិងភាពមិនអាចចៀសវាងបាននេះ គឺវាជាចំណុចសំខាន់នៃទំនាក់ទំនងរវាងគ្នានិងគ្នា ដើម្បីឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្ដី។ សហព្រះរាជអាជ្ញាមិនបាន -- មិនចង់ធ្វើអ៊ីចឹងទេ ពីព្រោះថាគាត់មិនជឿទៅលើការកំណត់ដោយអង្គជំនុំជម្រះទេ ពីព្រោះថាគាត់តែងតែមានទស្សនៈរបស់គាត់ផ្សេងនៅក្នុងសំណុំរឿង។ ខ្ញុំសុំយោង ទៅសារណាបណ្ដឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០១ របស់សហព្រះរាជអាជ្ញា ដែលនៅក្នុងសារណារបស់ខ្លួនទាំងមូលនោះ រួមទាំងសារណានេះផងដែរ ហ្នឹងគឺថា ខ្ញុំសុំយោងទៅឯកសារ F11 កថាខណ្ឌទី១។ គាត់ថា -- គាត់ប្ដឹងទៅ -- គាត់ថា "អង្គជំនុំជម្រះសាលាដំបូងហ្នឹង មានកំហុសលើអង្គច្បាប់ដែលបានដកចេញនូវលទ្ធភាពដែលជនជាប់ចោទក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះផលវិបាកនៃឧក្រិដ្ឋកម្មផ្សេងដែលបានប្រព្រឹត្តដោយចារី ដល់ដោយផ្ទាល់នៃសារៈសំខាន់នៃការចូលរួមរបស់ជនជាប់ចោទក្នុងសហឧក្រិដ្ឋកម្មរួម។ នៅក្នុងកាលៈទេសៈដែលអាចប្រមាណបានយ៉ាងសមហេតុផលថា ឧក្រិដ្ឋកម្មទាំងអស់នេះមិនត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃសហឧក្រិដ្ឋកម្មរួមដែលអាចនឹងត្រូវបានប្រព្រឹត្តយ៉ាងជាក់លាក់។" សូមបញ្ចប់ការដកស្រង់។

[០៩:៣១:៥៥]

ថ្ងៃនេះសហព្រះរាជអាជ្ញាមិនបានប្ដឹងឧទ្ធរណ៍ ប្ដឹងសាទុក្ខសំណុំរឿង០០២/០២ទេ។ គាត់គួរតែធ្វើតាមពិតទៅនោះ។ គឺគាត់បង្ខំចិត្តព្យាយាមលើកឡើងអំពីទ្រឹស្ដី និងទឡ្ហីករណ៍របស់អង្គជំនុំជម្រះសាលាដំបូងដែលគាត់មិនជឿជាក់តាំងពីដំបូងមកម្ល៉េះ។ នៅក្នុងសារណាតបនោះ ក្នុងសំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាយល់ឃើញជាច្រើនដងថាការប្រព្រឹត្តឧក្រិដ្ឋកម្មហ្នឹង វាស្ថិតនៅក្នុងភវនីយភាពធម្មតា។ ខ្ញុំសុំយោងទៅកថាខណ្ឌមួយរយ -- ៩១៤ សុំទោស នៃចម្លើយតបរបស់ខ្លួនដែលសហព្រះរាជអាជ្ញា បានអះអាងថាម្ចាស់បណ្ដឹងសាទុក្ខនោះគឺបានដឹងអំពីផែនការ និងភវនីយភាពនៃឧក្រិដ្ឋកម្មនានា។ អ៊ីចឹងយើងឃើញថានេះជាភាពមិនស្រួលខ្លួនរបស់សហព្រះរាជអាជ្ញាដែលមិនអាចបង្ហាញភាពនៃអាចចៀសវាងបាននៃឧក្រិដ្ឋកម្មក្នុងន័យចេតនាដោយប្រយោល។ អ៊ីចឹងសហព្រះរាជអាជ្ញានៅរក្សាជំហរ

របស់ខ្លួន ដោយផ្អែកទៅលើចេតនាប្រយោលដោយសង្ឃឹមថា អង្គជំនុំជម្រះតុលាការកំពូលនឹង យល់ឃើញថាខ្លួនត្រឹមត្រូវ ដោយកំណត់នូវនិយមន័យឡើងវិញនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ដូចដែលបានកំណត់នៅក្នុងសំណុំរឿង០០២/០១ គឺសាលដីកា ០០២/០១។ ក៏ប៉ុន្តែទម្រង់នៃការទទួលខុសត្រូវជាមួយនឹងចេតនាប្រយោល គឺវាមិនត្រូវគ្នាជាមួយគ្នានឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលតម្រូវឲ្យមានចេតនាពិសេសដូចជាការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍ឡើយ។ ការបញ្ចូលចេតនាប្រយោលនៅក្នុងសហឧក្រិដ្ឋកម្មរួម ទម្រង់ទី១ នៅពេលបញ្ចូលអ៊ីចឹងអង្គជំនុំជម្រះមិនអាចផ្តន្ទាទោសទៅលើឧក្រិដ្ឋកម្មទាំងអស់ហ្នឹងបានទេ។

យើងសូមអះអាងថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែបោះបង់ចោលនូវការកំណត់សហឧក្រិដ្ឋកម្មទម្រង់ទី១ នៅក្នុងសាលដីកា០០២/០១។ ហេតុអ្វី? ពីព្រោះថាការកំណត់សហឧក្រិដ្ឋកម្មទម្រង់ទី១ ដែលធ្វើឡើងដោយតុលាការកំពូលនេះ គឺវាផ្អែកទៅលើការអានច្បោលៗ និងមិនត្រឹមត្រូវទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាម និងយុត្តិសាស្ត្រ ថាឌិក។ នេះជាអ្វីដែលយើងបានយោងនៅក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង០០២/០២។ ហើយត្រង់ចំណុចហ្នឹងហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាយើងត្រឹមត្រូវ។ អ៊ីចឹងជាការកត់សម្គាល់យើងនិយាយអំពីសញ្ញាណនេះ សញ្ញាណនៃចេតនាប្រយោល និងអំពីទម្រង់ទាំងអស់ហ្នឹង។ អ៊ីចឹងវាជាការសំខាន់ក្នុងការរំឭកថា អ្នកដែលបង្កើតសហឧក្រិដ្ឋកម្មរួមនេះ បង្កើត -- គឺនៅក្នុងរបាយការណ៍មិត្ត -- តុលាការនោះគឺថា គាត់បានប្រើប្រាស់ឧទាហរណ៍នៃការជម្លៀសប្រជាជន និងការប្តូរប្រដាប់អាវុធ គឺការប្រើប្រាស់ដោយសាលាដំបូងក្នុងការបង្ហាញអំពីធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងការជម្លៀសប្រជាជនស៊ីវិលនៅក្នុងសំណុំរឿង ០០២/០១ គាត់បានប្រើប្រាស់ឧទាហរណ៍ទាំងអស់ហ្នឹងដើម្បីបង្ហាញអំពីធាតុផ្សំអត្តនោម័តិ នៃសហឧក្រិដ្ឋកម្មទម្រង់ទី៣។ ដូច្នេះការកំណត់ដូចដែលបានធ្វើឡើងនៅក្នុងសាលដីកា ០០២/០១ហ្នឹង គឺវាពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣។

[០៩:៣៥:៥២]

ក្នុងសំណុំរឿង០០២/០១ តុលាការកំពូលបានពន្យល់នូវកថាខណ្ឌ៨០៧ នៃសាលដីការបស់ខ្លួនថាវាទាមទារនូវកម្រិតខ្ពស់ឲ្យទៅស្គាល់លក្ខណៈវិនិច្ឆ័យដែលអាចឲ្យកំណត់ឧក្រិដ្ឋកម្មដែលជាផ្នែកនៃគោលបំណងរួម។ អង្គជំនុំជម្រះបាននិយាយថា វាជាការវាយតម្លៃអង្គហេតុសុទ្ធសាធ។ ខ្ញុំសុំដកស្រង់កថាខណ្ឌ៨០៧ "ដឹងថាតើឧក្រិដ្ឋកម្មមួយនេះ រួមបញ្ចូលក្នុងគោលបំណងរួមដែរឬយ៉ាងណានោះ?

ជាចម្បង គឺបញ្ហាអង្គហេតុដោយពុំមានការព្រមព្រៀងច្បាស់លាស់ទើបតម្រូវឱ្យមានការធ្វើការវាយតម្លៃដោយពិចារណាទៅលើរាល់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងគោលដៅទូទៅនៃគោលបំណងរួម និងភវនីយភាព ដែលថាគោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ។ ធ្វើអ៊ីចឹងក៏ដោយ អង្គជំនុំជម្រះបាន -- តុលាការកំពូលបានឯកភាពទៅតាមសាលាដំបូង ដើម្បីកំណត់អំពីគោលនយោបាយដែលតម្រូវឱ្យមានឧក្រិដ្ឋកម្មឬក៏អត់"។ អតីតសហព្រះរាជអាជ្ញារងនៅ អ.វ.ត.ក បានពន្យល់នៅក្នុងអត្ថបទមួយដែលយើងបានដាក់នៅក្នុងបញ្ជីប្រភពរបស់យើងនោះ ហើយយើងទៅ -- យើងត្រូវតែគោរពតាមនូវមតិដ៏ល្អរបស់គាត់។ ខ្ញុំសុំដកស្រង់ជាភាសាអង់គ្លេស។ សូមអភ័យទោសផង ពីព្រោះថាភាសាអង់គ្លេសខ្ញុំប្រហែលជាមិនល្អទេ។ គាត់និយាយថា "(អានជាភាសាអង់គ្លេស) ទស្សនៈនៃការទទួលខុសត្រូវរួមគឺ មានបទដ្ឋានទាបនៃការទទួលខុសត្រូវដែលធ្វើឡើងដដែលៗ គឺបទដ្ឋានហ្នឹង គឺវាទាប ទាបជាងបទដ្ឋានអន្តរជាតិ បទដ្ឋានព្រហ្មទណ្ឌអន្តរជាតិជាច្រើន"។

[០៩:៣៧:៣៥]

ត្រង់ចំណុចមួយទៀតបញ្ជាក់ដោយតុលាការ ជាការបញ្ជាក់ដោយតុលាការកំពូល នៅក្នុងកថាខណ្ឌ៧៨៩ តុលាការកំពូលបញ្ជាក់ថា "គោលបំណងរួមគឺជាចំណុចស្នូលនៃទម្រង់ទទួលខុសត្រូវដោយសារធាតុផ្សំនេះចងភ្ជាប់សមាជិកទាំងអស់រួមគ្នានិងផ្តល់យុត្តិកម្មសម្រាប់ដាក់ឱ្យទទួលខុសត្រូវរួមចំពោះអំពើរបស់សមាជិកនេះដែលត្រូវបានចាត់ទុកជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ទោះជាយ៉ាងនេះក្តី ការធ្វើយុត្តិកម្មចំពោះការដាក់ឱ្យទទួលខុសត្រូវរួមបែបនេះ មិនត្រឹមតែគ្រប់គ្រាន់សម្រាប់អ្នកដែលបានយល់ស្របប្រព្រឹត្តជារួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានយល់ស្របគោលបំណងរួមនោះ។ អ្វីដែលតម្រូវគឺពួកគេយល់ស្របទៅនឹងគោលបំណងរួមដែលមានចរិតឧក្រិដ្ឋ។ អង្គជំនុំជម្រះសាលាដំបូងវិញ បានត្រឹមតែអះអាងថា មេដឹកនាំជាន់ខ្ពស់ចូលរួមនៅក្នុងផែនការរួម។" នេះជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបាននិយាយ។ ខ្ញុំភ្លេចដាក់ឯកសារយោង។ គឺគាត់និយាយអំពីគោលបំណងរួម និងអត្តសញ្ញាណនៃសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ សាលាដំបូងបាននិយាយថា៖ "មានមនុស្សច្រើនក្នុងចំណោមហ្នឹង ដូចជាមេដឹកនាំជាន់ខ្ពស់មាន ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, សុន សេន, វន វេត រហូតដល់គេចាប់ខ្លួនគាត់នោះ គឺនៅចុងឆ្នាំ១៩៧៨ ក៏ដូចជាលេខាភូមិភាគ ដូចជា តាម៉ុក, កែ ពក, កុយ ធួន រហូតដល់ -- រហូតពេលគេឃុំខ្លួនគាត់នៅក្នុងផ្ទះនៅពាក់កណ្តាលឆ្នាំ៧៦។ ជូ ជេត រហូតដល់ពេលគេចាប់ខ្លួនគាត់នៅខែមីនា ឆ្នាំ៧៨។ រស់ ញឹម រហូតដល់ពេលគេចាប់ខ្លួនគាត់នៅខែមិថុនា-ឧសភា

ឆ្នាំ១៩៧៨ និង សោ ភឹម រហូតទៅពេលគាត់ធ្វើអត្តឃាតនៅខែមិថុនា ឆ្នាំ៧៨ហ្នឹង សុទ្ធតែចូលរួមក្នុងផែនការរួម។

[០៩:៥០:០០]

ក៏ប៉ុន្តែគ្មានផែនការណាបង្ហាញថា ខៀវ សំផន ចូលរួមនៅក្នុងគោលបំណង និងចេតនាឧក្រិដ្ឋនៃបុគ្គលទាំងអស់ហ្នឹងទេ។ ហើយផ្អែកទៅលើហ្នឹង គឺថា គេមិនអាចបញ្ជាក់អំពី គេមិនអាចបន្ទោសថា ខៀវសំផន ចូលរួមនៅក្នុងការប្រព្រឹត្តទាំងអស់ហ្នឹងទេ។ គឺថាតាមរយៈអំណាច ឋានានុក្រម ឬក៏មុខងារទាំងអស់ហ្នឹងក៏ដោយ។ មធ្យោបាយហ្នឹងគឺថាវាធ្វើការសង្ខេបនៃការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋនៃឋានៈជាសមាជិករដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង។ អ៊ីចឹង ធ្វើអ៊ីចឹងហើយថា វាធ្វើឲ្យមានភាពឧក្រិដ្ឋនៅក្នុងការចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សំអាងហេតុដែលខ្ញុំបានរៀបរាប់អំមិញនេះ គឺថានិយាយអំពីអត្តសញ្ញាណមេដឹកនាំជាន់ខ្ពស់នោះគឺ៤០៦៩។ ដូច្នេះបញ្ហាហ្នឹងគឺវាបញ្ហានៃវិចារណកិច្ចរបស់អង្គជំនុំជម្រះ។ គាត់ថា ដោយសារតែ ខៀវ សំផន ជាសមាជិកកម្ពុជាប្រជាធិបតេយ្យ អ៊ីចឹង ខៀវ សំផន ក៏ចូលរួមនៅក្នុងគោលបំណងឧក្រិដ្ឋរួម ហើយគាត់ត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្ត។ នេះជាវិចារណកិច្ចដែលគ្រោះថ្នាក់ណាស់ ពីព្រោះថាវាជំនួសលក្ខណៈនៃគោលបំណងឧក្រិដ្ឋ គឺជាចេតនាដែលតម្រូវហ្នឹង។ ហើយដែលជំនួសទៅជាការចូលរួមដោយសត្យានុម័តទៅលើផែនការនយោបាយទៅវិញ គម្រោងនយោបាយទៅវិញ។

អ៊ីចឹងខ្ញុំសូមលើកនូវសាលដីកា ប្រានីន របស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ ដែលយើងបានដកស្រង់នៅកថាខណ្ឌ១៩៤៧ នៃសារណារបស់យើង។ សាលដីកាហ្នឹងគឺថា កថាខណ្ឌ៤៣១ បាននិយាយថា៖ “អង្គជំនុំជម្រះមិនអាចត្រឹមតែសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខបានទាក់ទងជាមួយនឹងឧក្រិដ្ឋជនទេ គឺត្រូវតែបង្ហាញឲ្យឃើញថា គាត់មានចេតនាប្រព្រឹត្តកម្ម គាត់ចូលរួមជាមួយអ្នកផ្សេងទៀត ដើម្បីសម្រេចផែនការហ្នឹង សម្រេចគោលដៅហ្នឹង ហើយគាត់គឺថាចូលរួមយ៉ាងទូលំទូលាយ ទៅនឹងឧក្រិដ្ឋកម្មទាំងអស់ហ្នឹង។”

[០៩:៤២:៣២]

អ៊ីចឹងយើងត្រូវតែធ្វើយ៉ាងម៉េចឲ្យឃើញថា វាមានការចូលរួមនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មហ្នឹងមែន។ ក៏ប៉ុន្តែនៅក្នុងសេចក្ដីសន្និដ្ឋានទៅលើតួនាទី និងការចូលរួមចំណែកនោះ អង្គជំនុំជម្រះបានសន្និដ្ឋានអំពីការចូលរួមនៅក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយរបស់ ខៀវ សំផន តាមរយៈការសេព

គប់ជាមួយនឹងសមាជិករបស់គណៈអចិន្ត្រៃយ៍។ ហើយចំពោះ -- ហើយនិងចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលគាត់ចូលរួមតាមរយៈសុន្ទរកថាផ្លូវការ ឬក៏សេចក្តីថ្លែងការណ៍ ក្រោយអង្គហេតុ ហើយនិងមុខងារដែលវាពាក់ព័ន្ធទៅនឹងទិដ្ឋភាពមិនឧក្រិដ្ឋនៃផែនការ គឺវាអត់មានពាក់ព័ន្ធទៅនឹងទិដ្ឋភាពឧក្រិដ្ឋទេ។ ដោយសារតែមិនអាចកំណត់អំពីសកម្មភាពជាក់លាក់របស់ ខៀវ សំផន ដែលកំណត់អំពីការចូលរួមនៅក្នុងទិដ្ឋភាពឧក្រិដ្ឋនៃផែនការរួម អង្គជំនុំជម្រះបានយោងទៅលើអ្វីដែលវាមិនមានពិតប្រាកដ យើងអាចហៅថាវាជាអ្វីដែលជាសិប្បនិមិត្ត ដើម្បីបញ្ចូល ខៀវ សំផន ទៅក្នុងការទទួលខុសត្រូវរួម គឺដើម្បីបញ្ចូលគាត់ទៅក្នុងការទទួលខុសត្រូវរួមដែលវាខុសពីចេតនា ពីភាពចាំបាច់ក្នុងការកំណត់ការទទួលខុសត្រូវផ្ទាល់ខ្លួន។ នេះគឺក្នុងសារណារបស់យើងកថាខណ្ឌ២០០៨។ ហើយយើងនឹងនិយាយនៅ -- យើងនឹងត្រឡប់មកនិយាយវិញនៅពេលដែលយើងឆ្លើយតបទៅនឹងសំណួររបស់តុលាការកំពូល។ដូច្នេះផលវិបាកនេះជាមួយនឹងការកំណត់សហឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿងហ្នឹង បុគ្គលណាក៏ដោយឲ្យតែមានតំណែងនៅក្នុងសម័យហ្នឹងគេអាចនិយាយថា គេជាសហចារី។ ក៏ប៉ុន្តែមូលដ្ឋានគតិយុត្ត និងធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវហ្នឹង ត្រូវតែមានភាពច្បាស់លាស់។ ជាពិសេសគឺអ្វីដែលអាចធ្វើនៅ -- ឲ្យវាមាននូវភាពសុក្រឹតនូវការប្រព្រឹត្តនោះ។ដូច្នេះវាមានការពិចារណាតាមផ្លូវនយោបាយ ដើម្បីពាក់ព័ន្ធទៅនឹងការអនុវត្តនូវសនិទាននៃច្បាប់។ ការវិវឌ្ឍនៃធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួមបង្ហាញថា ជាង២០ឆ្នាំក្រោយពីការបង្កើតនូវលទ្ធិហ្នឹងគឺថា វាមាននូវការរំលោភបំពាន។ វាមានភស្តុតាងច្បាស់ណាស់គឺថា អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា ក៏ដូចជាអង្គជំនុំជម្រះតុលាការកំពូលហ្នឹងគឺថា ក្រោយពី ១៥ឆ្នាំជាង នៃសំណុំរឿង នៃនីតិវិធីនៅក្នុងសំណុំរឿងយើងហ្នឹងគឺថា មិនយកនូវនិយមន័យដដែលនៃសហឧក្រិដ្ឋកម្មរួមទម្រង់បឋមនោះទេ។

[០៩:៤៥:២៦]

ក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់នូវនិយមន័យនៃធាតុផ្សំចេតនានៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ដែលវាពាក់ព័ន្ធទៅនឹងនិយមន័យនៃធាតុផ្សំអត្តនោម័តិ ដែលបានផ្តល់ដោយសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ដោយសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសាលាដំបូងហ្នឹងបានមិនឯកភាពជាមួយតុលាការកំពូលទេ។ គាត់និយាយថាសហឧក្រិដ្ឋកម្មរួមក្តោបទៅលើសញ្ញាណនៃចេតនាប្រយោលមុននឹងកំណត់នូវខ្លឹមសារនៃនេះ គឺថាវាធ្វើឲ្យមានការកំណត់ផែនការរួមឡើងវិញ។

ពាក់ព័ន្ធទៅនឹងផែនការរួមនេះ សហព្រះរាជអាជ្ញាខ្លួនឯងបានយល់ឃើញថា ជនជាប់ចោទ មិន

អាចត្រូវបានទទួលខុសត្រូវពីបទឧក្រិដ្ឋដែលកើតចេញពីផែនការដែលដំបូងឡើយវាស្របច្បាប់នោះទេ។ ហើយទឡ្ហីករណ៍ដែលគាត់ផ្តល់ថ្ងៃនេះ គឺថាគាត់ព្យាយាមបង្ហាញនូវអ្វីដែលផ្ទុយទៅវិញនេះ។ ខ្ញុំសូមរំឭក គឺថា សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាទៅលើសហឧក្រិដ្ឋកម្មរួម គឺឯកសារ D97/8 កថាខណ្ឌ៤៤ គឺចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨។ ដូច្នេះច្បាស់ណាស់ថា ដោយសារតែមានការបំភ្លៃដែលនៅសហឧក្រិដ្ឋកម្មរួមទម្រង់ទី១នេះ គឺធាតុផ្សំទាំងអស់ហ្នឹងវាមិនគ្រប់គ្រាន់តាមការតម្រូវដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យនៃគោលការណ៍នីត្យានុកូលភាពនោះទេ។ គោលការណ៍នីត្យានុកូលភាពនេះ យើងបាននិយាយតាំងពីដំបូងមកម្ល៉េះនៅក្នុងសវនាការយើងនេះ គឺតាំងពីសំណុំរឿង០០២មកនោះ។ ការវិវឌ្ឍនៃនិយមន័យផ្សេងៗគឺថាវាជាចេត -- វាជាឆន្ទៈក្នុងការធ្វើឱ្យមានទម្រង់នៃការទទួលខុសត្រូវមួយ គឺថាតែថ្ងៃយ៉ាងម៉េចធ្វើឱ្យមានការផ្តន្ទាទោសបាននោះ។ ដោយសារតែវាមានគោលជំហរផ្សេងៗគ្នាហ្នឹង យើងពិបាកមើលឃើញណាស់ថាតើទម្រង់នៃការទទួលខុសត្រូវហ្នឹងអាចប្រមើលមើលបាន អាចដឹងឮបានដោយលោក ខៀវ សំផន ឬអត់ នៅឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ពីព្រោះថាយើង -- ឥឡូវនេះ យើងពិភាក្សាគ្នានៅឆ្នាំ២០២១ហើយ។ ឥឡូវនេះ ខ្ញុំនិយាយពាក់ព័ន្ធទៅនឹងការជួយ និងការជំរុញយើងសូមយោងទៅសារណារបស់យើង កថាខណ្ឌ២០២០ ដល់២០២១។ វាមានការអនុវត្តដដែលៗ ដូចៗគ្នារបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការ -- ពាក់ព័ន្ធនឹងការអនុវត្តការជួយ និងការជំរុញនេះ។ ជាលក្ខណៈប្រព័ន្ធតែម្តងនោះ អង្គជំនុំជម្រះបានធ្វើការបន្ទាបធាតុផ្សំអត្តនោម័តិ ពីព្រោះថាអត់មានចេតនាផ្ទាល់ទៅចំពោះឧក្រិដ្ឋកម្មភាគច្រើននៅក្នុងសំណុំរឿងយើងនេះ។ ខ្ញុំសូមកត់សម្គាល់ថា យើងបានផ្តល់ប្រភពថ្មីៗជាច្រើននៅក្នុងបញ្ជីឯកសារសំអាងរបស់យើង។ ដូច្នេះ វាមានការសំខាន់ក្នុងការយោងទៅលើឯកសារទាំងអស់ហ្នឹង ដើម្បីឱ្យឃើញថានៅសម័យនោះគឺអត់មានចេតនាប្រយោលទេ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មក៏ដោយ ទម្រង់នៃការទទួលខុសត្រូវក៏ដោយនោះ។ ធាតុផ្សំផ្នែកច្បាប់ទាំងអស់នេះ យើងបានរំឭករួចអស់មកហើយ។ ឥឡូវនេះ ខ្ញុំសូមនិយាយ ខ្ញុំនឹងនិយាយអំពីបញ្ហារបស់អង្គជំនុំជម្រះ គឺសំណួររបស់អង្គជំនុំជម្រះនឹងនិយាយអំពីចំណុចអង្គហេតុដែលយើងគិតថា ជាការរំលោភរបស់អង្គជំនុំជម្រះដោយមិនគិតទៅដល់ធាតុផ្សំដោះបន្ទុកចំពោះលោក ខៀវ សំផន។ ហើយនិងខ្ញុំសូមឆ្លើយតបទៅកថាខណ្ឌ៤៣, ៤៤, ៥២ នៃរបាយការណ៍របស់ចៅក្រម។

[០៩:៥០:០០]

ខ្ញុំបានសង្ខេបនៅក្នុងកថាខណ្ឌហើយគឺថា បើតាមអង្គជំនុំជម្រះតួនាទីរបស់ជនជាប់ចោទ គឺថា

គាំទ្រជំរុញនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយគាត់កាន់តំណែងដឹកនាំនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគាត់បានបង្រៀននៅក្នុងវគ្គរៀនសូត្រ។ អ៊ីចឹងហើយដោយពឹងផ្អែកទៅលើតួនាទីទាំងអស់ហ្នឹងហើយ ដែលអង្គជំនុំជម្រះនិយាយអំពីការចូលរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួម។

សំណួរទី២ របស់អង្គជំនុំជម្រះ គឺផ្អែកទៅលើកថាខណ្ឌ៤២ ដើម្បីឲ្យដឹងថា តើភស្តុតាងណាដែលបង្ហាញតាមរយៈថា ម្ចាស់បណ្ដឹងសាទុក្ខហ្នឹងគាត់មិនដឹងអំពីការស្លាប់នៅតាមការដ្ឋាន។ ហើយពាក់ព័ន្ធនឹងប្រធានបទដែលខ្ញុំនឹងនិយាយហ្នឹងគឺថា វា -- ខ្ញុំនឹងលើកឡើងអំពីបញ្ហាទាំងអស់នេះ *(គ្មានការបកប្រែ)* ខ្ញុំសូមរំឭកថា វាជាការសំខាន់ណាស់ដែលយើងបានបង្ហាញអំពីនិយមន័យនៃគោលបំណងរួមដែលមាននៅក្នុងសំអាងហេតុនៃសាលក្រមនៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍របស់យើងកថាខណ្ឌ-- ដែលយើងដឹងហើយថា មានពាក្យពេចន៍ជាច្រើននៅក្នុងសាលក្រមនោះគឺថា មានមួយ ការសម្រេចមួយគឺថានៅកថាខណ្ឌ១៩៨០ ដែលជាសំអាងហេតុ គឺថាធ្វើយ៉ាងណាដើម្បីគម្រោង -- គោលបំណងរួមនោះគឺថាសម្រេចបានបដិវត្តសង្គមនិយមយ៉ាងលឿន ហើយមហាលោតផ្លោះ ធ្វើយ៉ាងណាដើម្បីកសាងប្រទេសហើយនិងប្រឆាំងនឹងខ្មាំង ហើយនិងកែប្រែប្រជាជនទៅដល់សង្គមមួយដែលស្មើគ្នា កម្មករ និងកសិករ។

ខ្ញុំសុំធ្វើការស្រង់ថា និយមន័យនៃគោលបំណងរួមនេះនៅក្នុងកថាខណ្ឌ១៥៦ នៅក្នុងដីកាដំណោះស្រាយនោះគឺគម្រោងរួមនេះគឺថា ដើម្បីកសាងបដិវត្តសង្គមនិយមនៅប្រទេសកម្ពុជាតាមមធ្យោ-បាយណាក៏ដោយ ធ្វើយ៉ាងណាឲ្យមហាលោតផ្លោះ ហើយនិងការពារបក្សប្រឆាំងនឹងខ្មាំងខាងក្នុងនិងខាងក្រៅ។ ដូច្នេះយើងត្រូវប្រៀបធៀបចំណុចទាំងនេះ យើងឃើញថាមានការបន្ថែមដោយសាលាដំបូង។ យោងទៅនឹងអ្វីដែលខ្ញុំបាននិយាយឡើងអំពីសហឧក្រិដ្ឋកម្មរួម ខ្ញុំសូមរំឭកពីការចោទប្រកាន់ភវនីយកម្មដែលថាឧក្រិដ្ឋកម្មនឹងមិនអាចកើតឡើង ហើយដែលត្រូវព្យាករទុក។ ខ្ញុំបានដកស្រង់ម្សិលមិញនៅ -- អម្បាញ់មិញនេះនៅក្នុងសារណារបស់យើង គឺកថាខណ្ឌ២០០៨ ហើយយើងបានសង្ខេបការចូលរួមរបស់ ខៀវ សំផន ទៅតាមខ្លឹមសាររបស់សាលាដំបូងនោះ សាលាដំបូងនៅក្នុងកថាខណ្ឌនេះបានន័យថាបានសន្និដ្ឋានថា ខៀវ សំផន បានចូលរួមក្នុងគម្រោងឧក្រិដ្ឋនេះដោយសារគាត់បានសេពគប់ជាមួយសមាជិកគណៈអចិន្ត្រៃយ៍ ហើយនិងគាត់បានធ្វើសុន្ទរកថា ហើយនិងមានការ -- និងគាត់បានធ្វើសុន្ទរ-កថាផ្សេងទៀតក្រោយសម័យកម្ពុជាប្រជាធិបតេយ្យទៀត ហើយខ្ញុំនឹងនិយាយអំពីគណៈអចិន្ត្រៃយ៍។

[០៩:៥៤:៣០]

--១៧៣៧ និងបន្តបន្ទាប់នៅក្នុងសារណារបស់យើង យើងបាននិយាយថា មានការប្រើប្រាស់ដែលមានទំនោររបស់សាលាដំបូងអំពីកំណត់ហេតុប្រជុំ ហើយក្នុងការប្រើប្រាស់នោះគឺថា មានធ្វេសប្រហែស ហើយនិងធ្វើមិនដឹងមិនឮនូវភស្តុតាងដោះបន្ទុក។ សាលាដំបូងនិយាយនៅក្នុងមូលដ្ឋានសាលក្រមរបស់ខ្លួននោះ គាត់សន្និដ្ឋានថា ខៀវ សំផន មានគោលជំហរ -- មានឋានៈដោយឡែក ហើយគាត់ដឹងអ្វី រឿងរ៉ាវទាំងអស់ដែលកើតមានឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ ដោយសារគាត់បានចូលរួមនៅក្នុងការប្រជុំយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ គឺការចូលរួមដោយសកម្ម។ ហើយនៅក្នុងសារណារបស់យើងគឺកថាខណ្ឌ១៧៣៦ ទៅដល់ ៣៨ ហើយនិង ១៧៤៥ ដល់ ១៧៤៧ ខ្ញុំសូមរំឭកផងដែរ នៅក្នុងសំណុំរឿងមានកំណត់ប្រជុំអចិន្ត្រៃយ៍១៦ ហើយដែលចប់នៅថ្ងៃទី១០ មិថុនា ឆ្នាំ១៩៧៦ ក៏ប៉ុន្តែរបបកម្ពុជាប្រជាធិបតេយ្យនេះចប់នៅខែមករា ឆ្នាំ១៩៧៦*(ស៊ីក)*។ ដូច្នេះនិយាយអំពីការចូលរួមសកម្មនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នោះដែលមានកំណត់ហេតុប្រជុំ ហើយត្រូវប្រជុំចូលរួមសកម្មហ្នឹងមូលដ្ឋានអី ក្នុងខណៈដែលកំណត់ហេតុប្រជុំទាំង១៦នោះគឺមានឈ្មោះរបស់ ខៀវ សំផន មានតែពីរដងតែប៉ុណ្ណោះ ហើយមិនមែនដូចដែលលើកឡើងថា យ៉ាងហោចណាស់ពីរដងតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទេ។ ហើយពេលពីរដងនោះ គឺគាត់ត្រូវរាយការណ៍ទៅគណៈអចិន្ត្រៃយ៍ ហើយអ៊ីចឹងអង្គជំនុំជម្រះមិនដែលបញ្ជាក់ផងដែរថា ខៀវ សំផន មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ។ ហើយបន្ទាប់មកទៀតទាក់ទងទៅនឹងរបាយការណ៍នេះ ពុំមានទំនាក់ទំនងណាមួយដែល ខៀវ សំផន ធ្វើហ្នឹង -- តាមពិតរបាយការណ៍របស់ ខៀវ សំផន នោះ គាត់ធ្វើតែជាមួយនឹងរាជរដ្ឋាភិបាលរួបរួមជាតិ ដែលពេលសីហនុ គាត់បានលាលែងពីតំណែង ហើយអ៊ីចឹងទេ គឺមានតែនិយាយតែពីសកម្មភាពជាទូទៅទេ។ គាត់មិនដែលបានចូលរួមអីទេ ហើយមិនដែលមានឃើញមានបង្ហាញពីសកម្មភាពទូទៅរបស់គាត់នៅនឹងខាងពាណិជ្ជកម្ម ហើយនិងមិនបានបង្ហាញអំពីការចូលរួមទំនាក់ទំនងរបស់គាត់ជាមួយនឹងឧក្រិដ្ឋកម្មទេ។ អ៊ីចឹងបើមិនគិតពីអង្គហេតុទាំងអស់នេះ អ៊ីចឹងចូល -- គាត់ចូលរួមយ៉ាងសកម្មនោះយ៉ាងម៉េច ហើយបើគាត់ធ្វើរបាយការណ៍តែពីរដងហ្នឹងគត់ ហើយបើយើងពន្យល់យ៉ាងម៉េចពីការចូលរួមឧក្រិដ្ឋកម្មហ្នឹង។

[០៩:៥៧:៣៩]

ទាក់ទងនឹងកំណត់ហេតុប្រជុំដដែលហ្នឹង អង្គជំនុំជម្រះបានប្រើប្រាស់កំណត់ប្រជុំនោះ ដើម្បីសន្និដ្ឋានថា ហ៊ុន សែន --អ៎! ខៀវ សំផន ដឹងពីការប្រព្រឹត្តឧក្រិដ្ឋកម្មនៅព្រលានយន្តហោះកំពង់ឆ្នាំងដែលជាទីតាំងមួយដែលគេពិភាក្សាជំនុំជម្រះនៅក្នុងរឿងក្ដីយើងនេះ។ អ៊ីចឹងយើងឃើញថាមានការទាយ

ព្រាវៗ ហើយនិងភាពលម្អៀងរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងកំណត់ហេតុប្រជុំទាំងអស់នេះ។ ខ្ញុំយោងទៅនឹងសារណារបស់យើងគឺ ១៧៤១, ១៧៤២ កថាខណ្ឌ។ អង្គជំនុំជម្រះនិយាយថា នៅក្នុងសំអាងហេតុរបស់ខ្លួននោះគឺ ៤២៥៨ អង្គ -- សាលាដំបូងទាញសន្និដ្ឋានថាគាត់ដឹងរឿងរ៉ាវនៅព្រលានយន្តហោះនេះ ដោយថាគាត់ហ្នឹងមានវត្តមាននៅក្នុងកិច្ចប្រជុំមួយ ដែលគេលើកឡើងអំពីគម្រោងសង់ព្រលានយន្តហោះ ហើយបន្ទាប់មកគាត់ចូលរួមនៅក្នុងកិច្ចប្រជុំក្រោយទៀតដែល សុន សេន ហ្នឹងគាត់ជាអ្នកទទួលខុសត្រូវខាងយោធា និយាយពីការដ្ឋានអស់ហ្នឹង។ អ៊ីចឹងនៅក្នុងកថាខណ្ឌ១៧៤២ គឺមាននិយាយ -- មានកំណត់ហេតុមួយទៀតគឺនៅក្នុងឆ្នាំ៧៥ ដែលនិយាយពីការចូលរួម អ្នកចូលរួម។ កំណត់ហេតុនៅឆ្នាំ៧៦ ដែលមាននិយាយពីបញ្ហាកសាងហ្នឹង គឺកំពុងតែសិក្សានៅឡើយទេ។ ហើយខ្ញុំមិនយល់ដែរថា ខៀវ សំផន គាត់ដឹងអំពីឧក្រិដ្ឋកម្មដែលកើតឡើងនៅការដ្ឋានការងារនោះយ៉ាងម៉េចដែរ។ ហើយនៅមួយទៀត គឺកំណត់ហេតុប្រជុំឆ្នាំ១៩៧៥ សុន សេន និយាយពិចារណាអំពីផ្នែកបច្ចេកទេសទាក់ទងទៅនឹងថ្ម ហើយនិងធ្វើយ៉ាងម៉េចកុំឲ្យមេឃក្ដៅជាដើម។ ដូច្នេះ មានតែ១បីហ្នឹង ដែលគាត់ សាលាដំបូងគាត់ដែលទាញសន្និដ្ឋានថា ខៀវ សំផន ហ្នឹងដឹងពីឧក្រិដ្ឋកម្ម ដែលកើតឡើងនៅព្រលានយន្តហោះកំពង់ឆ្នាំង។

[០៩:៥៩:៥៣]

ខ្ញុំសូមរំឭកថា បើសិនជាសុន សេន គាត់និយាយពីព្រលានយន្តហោះនេះ ពីព្រោះថាវាជាព្រលានយន្តហោះយោធា ដែលស្ថិតនៅក្រោមការ -- នៅក្រោមអាជ្ញាធរយោធា។ ដូច្នេះ ខៀវ សំផន បានទទួលស្គាល់ដោយអង្គជំនុំជម្រះហើយថាគាត់មិនដែលស្ថិតនៅក្នុងគណៈកម្មាធិការយោធាហ្នឹងទេ។ បន្ទាប់មកទៀត អង្គជំនុំជម្រះនិយាយពីការចូលរួមរបស់ ខៀវ សំផន ដោយលើកឡើងអំពីមុខងាររបស់គាត់ទាក់ទងទៅនឹងផ្នែកពាណិជ្ជកម្ម។

យើងបានពិភាក្សាគ្នាជាច្រើននៅក្នុងក្របខ័ណ្ឌនៃភស្តុតាងសំណុំរឿង ០០១/១ -- ០០២/១ និង ០០២/២ ប្រសិនអង្គជំនុំជម្រះសន្និដ្ឋានថា គាត់មានតំណែងជាអ្នកគ្រប់គ្រង ប៉ុន្តែគាត់មិនមែនជាប្រធានពាណិជ្ជកម្មទេ ហើយនៅក្នុងសំណុំរឿងនេះ ភស្តុតាងបញ្ជាក់ស្រាប់ហើយ នៅក្នុងសារណារបស់យើងគឺកថាខណ្ឌ១៦៣៨, ១៧៦៨ និង ១៧៦៩ ដែលមានបញ្ជាក់ -- ខ្ញុំសូមទោស ខ្ញុំនិយាយពីការិយាល័យ ៨៧០។ យើងមានកំណត់ហេតុប្រជុំជាច្រើន ដែលនិយាយអំពីភស្តុតាងទាក់ទងទៅនឹងពាណិជ្ជកម្ម ក៏ប៉ុន្តែអ្នកប្រធានធំនោះគឺ វន វ៉េត ហើយនិង វ៉ាន់ រិទ្ធ ទេ។ ដូច្នេះពេលដែលនិយាយពីភស្តុតាងការរៀប

អាពាហ៍ពិពាហ៍ គេបង្ហាញថា ខៀវ សំផន ហ្នឹងគាត់ជាប្រធានក្រសួងពាណិជ្ជកម្ម។ ដែលនេះមិនត្រូវទេ វាមិនមានភស្តុតាងណាបញ្ជាក់ថាគាត់ធ្វើជាប្រធានក្រសួងពាណិជ្ជកម្មនោះទេ។

[១០:០២:០២]

ដើម្បីឲ្យវាច្បាស់លាស់តែម្តង ភស្តុតាងក្នុងបណ្តឹងសារណា បណ្តឹងឧទ្ធរណ៍យើងគឺនៅកថាខណ្ឌ -- មុខងារគាត់នៅក្នុងក្រសួងពាណិជ្ជកម្មនោះគឺគាត់ធ្វើការៗ ផ្នែកសកម្មភាពពាណិជ្ជកម្មជាមួយ ឌឿន ដែលជាប្រធានមន្ទីរ៨៨០ -- ៨៧០ ដែលគេបានពិភាក្សាច្រើនណាស់នៅក្នុងការជំនុំជម្រះសេចក្តីយើងនេះ។ ហើយវាច្បាស់ណាស់ថា ខៀវ សំផន មិនដែលបន្តតំណែងពី សឿន -- ឌឿន នៅក្នុងមន្ទីរ៨៧០ ហ្នឹងទេ ហើយអង្គជំនុំជម្រះក៏បានលើកឡើងអ៊ីចឹងដែរ។ នៅក្នុងសារណារបស់យើងគឺនៅក្នុងកថាខណ្ឌ ១៦៣៨ និង ១៧៦៨, ១៧៦៩ ដែលពីមុនមកនោះ អង្គជំនុំជម្រះបានលើកឡើងថា គាត់ប្រហែលជាបានបន្តតំណែងពី ឌឿន ប៉ុន្តែក្រោយមកបញ្ជាក់ថា អត់ទេ។ អ៊ីចឹងគឺថា ហើយខាងព្រះរាជអាជ្ញា គេថាប្រហែលជាកំហុសវាយអក្សរខុសទេ ប៉ុន្តែក្រោយមកអង្គជំនុំជម្រះសម្រេចផ្ទុយពីហ្នឹងទៅវិញ។ ក៏ប៉ុន្តែនេះជាភស្តុតាងដែលបង្ហាញថា រាល់ដងយើងមានភស្តុតាងច្បាស់លាស់លើសកម្មភាពមានកម្រិតរបស់ ខៀវ សំផន ហើយគេចេះតែទាញការសន្និដ្ឋានព្រាវៗ ដើម្បីភ្ជាប់គាត់ទៅនឹងទិដ្ឋភាពឧក្រិដ្ឋ ដូចដែលសាលាដំបូងបានកំណត់។ ចំណុចមួយទៀតសំខាន់ដែរ ដែលមានទំនាក់ទំនងជាមួយនឹងមន្ទីរ៨៧០នេះ គឺថានៅពេលដែលយើងសិក្សាអំពីរចនាសម្ព័ន្ធទំនាក់ទំនង គឺមានសាក្សីដែលសំខាន់ហ្នឹងគឺ នន សំផន -- សំផង់ ដែលទទួលបន្ទុកខាងទំនាក់ទំនងមន្ទីរប៉ែត -- ៨៧០ ហ្នឹងគឺមានខ្សែច្រកចេញចូលមួយច្បាស់លាស់ ហើយនិងមួយទៀតមានខ្សែមួយទៀតពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្មរបស់ ខៀវ សំផន ដាច់ដោយឡែក។

[១០:០៤:៣៥]

ចំណុចមួយទៀត ដែលខ្ញុំចង់លើកឡើងដែរនោះ គឺជាការវិភាគលើពាក្យសម្តីរបស់សាក្សីដែលបានលើកឡើងអំពីពាក្យសម្តីរបស់ ខៀវ សំផន។ យើងបាននិយាយដ៏វែង ដ៏យូរនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់យើង ហើយនិងសារណាបណ្តឹងឧទ្ធរណ៍។ ហើយយើងមានសាក្សីពីររូបដែលនិយាយផ្ទុយគ្នាដ៏ខ្លាំងមែនទែន ប៉ុន្តែអង្គជំនុំជម្រះបានប្រើសក្ខីកម្មរបស់ពួកគាត់ ដើម្បីចោទថា ខៀវ សំផន ហ្នឹងអ្នកនិយាយពាក្យសម្តីមួយចំនួនថា គាត់បានដឹងអំពីការចាប់ខ្លួនមនុស្សជាដើម។ ខ្ញុំនិយាយសាក្សី ឯក ហេន ដែលជាដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំយោងទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់យើង

នៅកថាខណ្ឌ១៧៥៩ ហើយនិងសុំ សំណើសុំទទួលភស្តុតាងបន្ថែម F51 ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ កថាខណ្ឌ១៧ ដល់ ៣៨ ហើយនិង ៣៩, ៥៩ ដែលយើងវិភាគអំពីសក្ខីកម្មរបស់ ឯក ហេន លើការដែលគាត់បានឆ្លើយអំពីវគ្គរៀនសូត្រជាច្រើនដែលគាត់បានចូលរួម ហើយដែលថាគាត់ថា ខៀវ សំផន បាននិយាយនៅក្នុងវគ្គរៀនសូត្រនោះ ហើយមានភាពផ្ទុយចម្រូងចម្រាសគ្នាទាក់ទង -- ហើយយើងមានការច្របូកច្របល់អំពីពេលវេលាលើកទី១ ឬក៏លើកទី២ ចូលវគ្គសិក្សាលើកទី១ លើកទី២ ហើយសំណៅជាច្រើននេះ ក៏មិនគួរណាឲ្យសាលាដំបូងហ្នឹងសន្និតថា សក្ខីកម្មរបស់គាត់គួរឲ្យទុកចិត្តបាននោះទេ។ ហើយជាពិសេសនោះពេលដែលសាក្សីហ្នឹងទទួលស្គាល់ថា នូវឯកសារ F51 កថាខណ្ឌ ២៣, ២៥ ហ្នឹងគាត់ សាក្សីហ្នឹងគាត់ថាគាត់ចាំមិនច្បាស់ទេ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ នៅពេលដែល កាលនោះព្រះរាជអាជ្ញានិងសាលាដំបូងហ្នឹង ក៏នៅស្ងៀមមិនព្រមនិយាយអ្វីទាំងអស់ទៅលើចម្លើយថ្មីរបស់គាត់ហ្នឹង ដែលបាននិយាយផ្ទុយពីចម្លើយពីមុនរបស់សាក្សីរូបហ្នឹង ហើយចាំដល់ដំណាក់កាលប្តឹងឧទ្ធរណ៍នោះ គឺគាត់ឆ្លើយខុសពីមុនទៅទៀត ដែលគាត់ឆ្លើយ ដែលផ្តល់មកឲ្យតុលាការនេះ គឺនៅពេលដែលយើងបញ្ចប់ការពិភាក្សាដេញដោយសំណុំរឿង០០២ហើយ ហើយអង្គជំនុំជម្រះថា មិនបាច់បើកសវនាការឡើងវិញទេ មិនចាំបាច់បើកឡើងវិញ ដើម្បីអាចប្រើប្រាស់ចម្លើយរបស់គាត់នោះទេ។

[១០:០៧:៥៥]

ហើយទាក់ទងទៅនឹងវគ្គសិក្សារៀនសូត្រដដែល មានសាក្សី អែម អឿន ហ្នឹងដែលគាត់និយាយថា ខៀវ សំផន ហ្នឹងបាននិយាយនៅក្នុងវគ្គសិក្សាហ្នឹង។ សាក្សី ឯក ហេន -- ហេន ហើយនិង អែម អឿន ហ្នឹង -- អែម អឿន ដើមបណ្តឹងរដ្ឋប្បវេណី គាត់និយាយក៏មានភាពចម្រូងចម្រាសច្រើនដែរនៅក្នុងសក្ខីកម្មរបស់គាត់នោះ មិនមែនការផ្ទុយគ្នាតិចតួចទេ គឺជាផ្ទុយគ្នាខ្លាំងមែនទែន។ គាត់មិនអាចនិយាយកំណត់កាលប្បវត្តិ ឬក៏កំណត់ទីតាំងឲ្យច្បាស់លាស់ពីហេតុការណ៍ដែលកើតឡើងនោះទេ ហើយនិយាយតាំងពីកាលៈទេសៈនៃការស្លាប់របស់ឪពុកម្តាយខ្លួនគាត់ក៏ដោយ។ ក៏ប៉ុន្តែនៅថ្ងៃដែលគាត់ចូលរួមប្រជុំនោះ គាត់ថាគាត់ ខៀវ សំផន មានវត្តមាននៅហ្នឹង ព្រោះថាឪពុកគាត់បានប្រាប់ថា ខៀវ សំផន ជាប្រធានរដ្ឋ ហើយក្នុងខណៈដែលឪពុកគាត់នោះស្លាប់តាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យទៅទៀត។ អ៊ីចឹងខ្ញុំសូមឲ្យអស់លោក លោកស្រីចៅក្រម ទៅមើលកថាខណ្ឌ១៧៥៧, ១៧៥៨ នៃសារណារបស់យើង ហើយឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងព្រឹត្តិការណ៍រៀបអាពាហ៍ពិពាហ៍ហ្នឹងគឺឯកសារ F50/1 កថាខណ្ឌ៥៨ ហើយនិងការនិយាយបញ្ចប់ការពិភាក្សាដេញដោល គឺឯកសារ

E1/235/1 នៅម៉ោងដប់បួន គឺថាមានភាពចម្រូងចម្រាសនិយាយផ្ទុយគ្នាជាច្រើននៅក្នុងឯកសារ F36 កថាខណ្ឌ៣៤១ គឺនៅក្នុងសាលដីកាសំណុំរឿង០០២/០១។

[១០:១០:០០]

តុលាការកំពូលទទួលស្គាល់ពីភាពផ្ទុយគ្នានេះ ក៏ប៉ុន្តែគាត់រកលេសដែលថា មាន -- មិនមានព្យសនកម្មអ្វីនោះទេទៅលើរូប ខៀវ សំផន នៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តី០០២/០១នេះ។ ក៏ប៉ុន្តែនៅក្នុងសំណុំរឿង០០២/០២ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន នេះគឺត្រូវបានប្រើដោយសាលាដំបូង ដើម្បីសន្និដ្ឋានថា ខៀវ សំផន ដឹងឮពីការចាប់ខ្លួនមួយចំនួននោះដែលត្រូវបានលើកឡើងនៅពេលវគ្គប្រជុំរៀនសូត្រនោះ គឺឯកសារ កថា១៨៥៤ នៃសារណារបស់យើង -- ១៨៦៤។ ខ្ញុំសូមរំឭកអង្គជំនុំជម្រះផងដែរថា យើងបានយោងទៅនឹងកថាខណ្ឌនេះទាំងអស់ យោងដែលយើងប្រើពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែលគាត់បានប្រើដែលចម្លើយរបស់គាត់ដែលអង្គជំនុំជម្រះបានប្រើ។

ទាក់ទងទៅនឹងការវិភាគភស្តុតាងផងដែរ យើងចង់ឲ្យធ្វើយ៉ាងណាឲ្យតែថា ខៀវ សំផន ពាក្យសម្តីទាំងអស់សុទ្ធតែពាក្យសម្តីរបស់ ខៀវ សំផន ហើយការចូលរួមគាត់នៅក្នុងទិដ្ឋភាពឧក្រិដ្ឋទាក់ទងនឹងគោលនយោបាយរៀបការដោយបង្ខំនេះ ហើយយើងជំទាស់។ អង្គជំនុំជម្រះសាលាដំបូងថាគាត់បាននិយាយអំពីការរៀបការដោយផ្អែកលើដើមបណ្តឹងរដ្ឋប្បវេណីតែមួយរូបគត់គឺ ឈ្មោះ ជា ខៀប។

[១០:១២:១៨]

កថខណ្ឌ១២៣៣, ១២៣៤ និង ២៨ នៅពេលដែលគាត់និយាយជាលើកទី១ អំពី ខៀវ សំផន នៅពេលពីមុនមកគាត់ធ្លាប់បានឆ្លើយនៅក្នុងសំណុំរឿងយើងនេះដែរ។ គាត់បង្ហាញថា គឺជាការចងចាំហ្នឹងពេលក្រោយមកហើយនេះទេ។ គួរកត់សម្គាល់ដែរថា ហេតុអ្វីបានអង្គជំនុំជម្រះចង់បានសាក្សីរូបនេះ? ព្រោះថា សាក្សីរូបនេះធ្វើការនៅខាងពាណិជ្ជកម្ម បាននិយាយអំពីសុន្ទរកថារបស់ ខៀវ សំផន ដែលក្នុងពេលហ្នឹងគាត់បានប្រាប់ថា ស្ត្រីមានអាយុលើសពី១៨ឆ្នាំ ហើយនិងមនុស្សប្រុសមានអាយុលើសប៉ុន្មានទៅត្រូវតែរៀបការជាមួយគ្នានៅក្នុងកន្លែងពាណិជ្ជកម្មហ្នឹង។ គឺសាក្សីតែមួយហ្នឹងគត់ សាក្សីមួយគត់ក្នុងចំណោមសាក្សីទាំងអស់នោះ។ ហើយសុំយោងទៅកថាខណ្ឌនៃសារណារបស់យើង។ សាក្សីផ្សេងទៀតនោះមិនដែលនិយាយអំពីសុន្ទរកថា ឬក៏ការបង្រៀនរបស់ ខៀវ សំផន ដែលនិយាយអំពីកាវៀបការហ្នឹងទេ។ ក៏ប៉ុន្តែប្រហែលជាមានអ្នកខ្លះនិយាយពីការរៀបការនៅមន្ទីរពាណិជ្ជកម្មហ្នឹង ប៉ុន្តែមិនបាននិយាយពី ខៀវ សំផន នោះទេ។ ហើយមានសាក្សី រស់ ស៊ុយ ហ្នឹងទៀតនិយាយអំពី--

ដែលមិនដែលបានអំពី ខៀវ សំផន ទេ និយាយពីការរៀបចំផ្សំផ្គុំដោយ ខៀវ សំផន នោះទេ។ ហើយខ្ញុំសូមរំឮកថា កន្លែងនេះជាចំណុចសំខាន់ណាស់។ ខៀវ សំផន មិនមែនជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មទេ។ គាត់ឆ្លើយ -- គាត់ធ្វើការសហការជាមួយនឹងក្រសួងហ្នឹងតែប៉ុណ្ណឹងទេ ប៉ុន្តែគាត់មិនមែនជាប្រធានទេ អ៊ីចឹងគឺ -- កាលហ្នឹងគឺ វ៉ាន់ រិទ្ធ ហើយនិង វន វ៉េត ទេ។

[១០:១៤:២៧]

ភស្តុតាងផ្សេងទៀតដែលខ្ញុំនឹងចាប់ផ្ដើមលើកឡើង ក៏ប៉ុន្តែទាក់ទងនឹងការរៀបការដដែល។ មានភស្តុតាងទៀតដែលបំភ្លេចចោលទាំងស្រុងគឺ ទស្សនាវដ្ដីបដិវត្ត គឺថានៅពេលដែលអង្គជំនុំជម្រះចង់បានភស្តុតាងដាក់បន្ទុកនោះ គឺគាត់យកមកប្រើ។ ហើយនៅពេលដែលនិយាយថា និយាយពីឧទាហរណ៍សីលធម៌ទាំង១២ប្រការហ្នឹងទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ហ្នឹងជាដើមនោះ សាលាដំបូងគឺធ្វើមិនដឹងមិនឮ មិនយកមកគិត ដោយសារមើលទៅហាក់ដូចជាសីលធម៌១២ប្រការហ្នឹងបោះពុម្ពផ្សាយនៅក្នុងទង់បដិវត្តហ្នឹងដល់ឆ្នាំ១៩៧៨ហើយហ្នឹង ធ្វើទៅក៏ចាត់ទុកថាគ្រាន់តែជាការឃោសនា គ្រាន់តែដូចថាទង់បដិវត្តហ្នឹងបង្កើតឡើងដើម្បីផ្សព្វផ្សាយទៅដល់សមាជិកបក្សកុម្មុយនីស្តកម្ពុជា ហើយដែលត្រូវធ្វើយ៉ាងម៉េច ដើម្បីឲ្យពួកយល់ពីសីលធម៌១២ប្រការហ្នឹង។ ហើយ ប៉ុងសូដ៍ ដែលយើងចង់ឲ្យគាត់មកផ្ដល់សក្ខីកម្មនៅទីនេះហ្នឹង តែអង្គជំនុំជម្រះបដិសេធមិនព្រមទទួលមក។ ហើយថា -- ហើយគាត់នៅស្រុកខ្មែរនេះតាំងពីមុនឆ្នាំ១៩៧៥ទៀត គាត់ដឹងពីប្រពៃណីរបស់ខ្មែរក្រហមតាំងពីមុនពេលឡើងកាន់អំណាចទៀតនោះគឺ ប៉ុងសូដ៍ ដឹងពីសីលធម៌១២ប្រការទៀត ដែលថាអាហ្នឹងកើតតាំងពីមុនកម្ពុជាប្រជាធិបតេយ្យហ្នឹងទៀត មុនឆ្នាំ១៩៧៨ហ្នឹងទៀត ប៉ុន្តែមិនព្រមឲ្យ ពែរ ប៉ុងសូដ៍ ហ្នឹងមកទីនេះ។

នៅកថាខណ្ឌ១១៩៣, ១១៩៥ នៃសារណារបស់យើង គឺបានលើកឡើងអំពីទស្សនាវដ្ដីបដិវត្តនេះដែលមានទំនាក់ទំនងជាមួយនឹងបទបញ្ញាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ដូចដែលមាននៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍របស់យើងនៅក្នុងអ្វីដែលខ្ញុំបានលើកឡើងជូនតុលាការ ដូចជានៅក្នុងសក្ខីកម្មរបស់ ឌុច ហើយនិងកម្មាភិបាលផ្សេងៗទៀតដែលបានបញ្ជាក់ភាគច្រើន។ ភស្តុតាងគួរឲ្យចាប់អារម្មណ៍មួយទៀត យើងមើលថាតើសាលាដំបូងបានប្រើភស្តុតាងទាំងអស់នេះ ដើម្បីបង្ហាញការស៊ីសង្វាក់គ្នាទាក់ទងនឹងគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍នេះទេ តើសាលាដំបូងបានប្រើយ៉ាងដូចម្ដេចលើភស្តុតាងទាំងអស់នេះ?

[១០:១៧:៣៤]

មាន ជា ឡៅ ដើមបណ្តឹងរដ្ឋប្បវេណីតែមួយគត់ដែលគាត់ផ្តល់សក្ខីកម្មទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នេះ។ គេប្រើសំណេររបស់ សីហនុ ប្រើច្រើន ប្រើជាច្រើនលើកច្រើនគ្រា ដើម្បីគាំទ្រអ្វី? ដើម្បីបង្ហាញពីភាពស៊ីសង្វាក់អ្វី? នៅពេលណា? ហើយសំណេររបស់ សីហនុ នេះគឺជាការចងចាំ គឺនិយាយតែពីចំណុចល្អរបស់ខ្លួនទេ ហើយគាត់ហ្នឹងបានបង្ហាញពីអនុស្សាវរីយ៍របស់គាត់ដែលយើងជាមេធាវីមិនអាចផ្ទៀងផ្ទាត់បាន ហើយនិងយកគាត់មកតទល់ជាមួយនឹងសាក្សីផ្សេងទៀត។ ដូច្នេះមិនមែនសំណេរក្រៅក្របខ័ណ្ឌច្បាប់ទេ ប៉ុន្តែជាសំណេរ។ សីហនុ គាត់ស្លាប់ហើយ ប៉ុន្តែកាលពីដើមទីនៃនីតិវិធីកាលសំណុំរឿង០០២/០១នោះ យើងបានសុំឲ្យកោះហៅមក ប៉ុន្តែអត់ប្រយោជន៍។ កាលនោះព្រះរាជអាជ្ញាជាតិហ្នឹង ជំទាស់មិនឲ្យកោះហៅមក។ ហើយយើង បានប្រើ -- ទោះបីយ៉ាងណាក៏ដោយគេប្រើសំណេររបស់ សីហនុ នេះ ដើម្បីសន្និដ្ឋានថាមានគោលនយោបាយទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ហ្នឹងមែន។ ហើយយើងបាននិយាយពីរឿងនេះនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើង។ ហើយ សីហនុ គាត់លើកឡើងពាក្យសម្តីដែល ខៀវ សំផន បាននិយាយកាលនោះទាក់ទងនឹងស្មារតីស្នេហាជាតិថា នារីៗនេះត្រូវតែរៀបការជាមួយយោធា។ នារីៗហ្នឹងបើស្នេហាជាតិខ្លាំង ត្រូវរៀបការជាមួយយោធា គឺវីរជន ហើយវីរជនពិការទៀត។

[១០:២០:០០]

អ៊ីចឹងនេះវាជាបញ្ហាក់ពីគោលនយោបាយ ឬក៏យ៉ាងម៉េចគ្រាន់តែជាពាក្យសម្តីដែល សីហនុ គាត់និយាយក្នុងសំណេររបស់គាត់ទេ ហើយដែលយើងមិនមានលទ្ធភាពអីមកសួរតទល់នឹងគាត់នោះទេ។ អ៊ីចឹងទាក់ទងនឹងបញ្ហានេះដដែល ខ្ញុំយោងលើ ជន ធី -- ដែលសាក្សី ជួន ធី និយាយអំពីការនៅក្នុងសម្រង់មួយ។ គាត់មាននិយាយអំពីសៀវភៅរបស់ សីហនុ ដែរ គឺយើងមិនអាចនិយាយបានថា ការលើកឡើងរបស់ សីហនុ នេះជាការគោរពដល់ ហ៊ុន សែន នោះទេ ប៉ុន្តែកាលនោះយើងត្រូវដឹងថាមានរណសិរ្សមួយជា សីហនុ អ៊ីចឹងមានការប្រឆាំងគ្នា។ វាមានការបំប្លែងរឿងវិជ្ជមានទៅជារឿងអវិជ្ជមាន។ កថាខណ្ឌ២០២៣ នៃសារណារបស់យើង យើងលើកឡើងពីសុន្ទរកថាដែលសាលាដំបូងប្រើប្រាស់ដើម្បីបង្ហាញថា ចេតនារើសអើងរបស់ ខៀវ សំផន ហ្នឹងរើសអើងលើពុទ្ធសាសនិកហ្នឹងពិតជាមាន។

យើងៗមិនយល់ពីការពិចារណារបស់អង្គសាលាដំបូងទេ គាត់ដកស្រង់សុន្ទរកថា ខៀវ សំផន ដែលសរសើរពុទ្ធសាសនិក ហើយថាគាត់ទាញការសន្និដ្ឋានអវិជ្ជមានថា ពីព្រោះ ខៀវ សំផន បោកប្រាស់ ធ្វើបង្ហាញមកធ្វើដូចជាអ្វីៗជាធម្មតា ហើយក្នុងទន្ទឹមនឹងពេលហ្នឹងគឺ ជំរុញ ជ្រោមជ្រែងឲ្យរៀប

អាពាហ៍ពិពាហ៍ហ្នឹងខុសពីប្រពៃណីជាតិ។ ហើយការប្រើប្រាស់ចំណុចហ្នឹង គឺដើម្បីឲ្យមានការគាំទ្រភស្តុតាងក្នុងការបញ្ជាក់អំពីចេតនារើសអើងទៅលើពុទ្ធសាសនិករបស់ ខៀវ សំផន។

មានភស្តុតាងផ្សេងទៀតដែលនៅក្នុងសុន្ទរកថា ឬពាក្យសម្តីដែលគេញាត់បញ្ចូលទៅក្នុងមាត់ ខៀវ សំផន ដើម្បីសន្និដ្ឋានថា គាត់បានចូលរួមក្នុងការរំដោះ -- ចូលរួមទៅក្នុងគោលបំណងរួម។ មិនប្រាកដថាចូលទៅក្នុងទិដ្ឋភាពឧក្រិដ្ឋទេ ក៏ប៉ុន្តែមានភស្តុតាងពីរគេ -- ដែលយើងដឹងថាមិនមែន ខៀវ សំផន អ្នកនិយាយទេ ពាក្យសម្តីរបស់*(ឮមិនច្បាស់)*ទេ មិនមែនត្រឹមតែយើងទេគឺចៅក្រមក៏បានលើកឡើងដែរ គឺឯកសារសារណាបណ្តឹងឧទ្ធរណ៍របស់យើង។ យើងមានឯកសារពីរដែលគេថា ខៀវ សំផន គឺសុន្ទរកថារបស់ ខៀវ សំផន នៅថ្ងៃទី -- E3/60--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យគាត់ផ្តល់លេខយោងមួយសាទៀតលោកប្រធាន ស្តាប់អត់ទាន់។

**លោកស្រី អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

[១០:២៣:៣៩]

**ប្រធានអង្គជំនុំ៖**

សូមលោកស្រីសហមេធាវីផ្តល់នូវលេខយោងឯកសារម្តង។ អ្នកបកប្រែស្តាប់អត់ទាន់ទេ។

**លោកស្រី អង់តា ហ្គីសសេ៖**

--១០២៣ នៃប៉ារ៉ាក្រាហ្វ ១០២៣ គឺនិយាយពីដែល ប៉ុងសូដ៍ នោះមិនបានកោះហៅមកវិញ។ ហើយៗអង្គជំនុំជម្រះបានប្រើដោយ ប្រើចម្លើយរបស់គាត់ហ្នឹង ដើម្បីសន្និដ្ឋានថា ខៀវ សំផន ហ្នឹងមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្រោយសម័យអង្គហេតុ។ ខាងព្រះរាជអាជ្ញានិយាយថា មិនមានផលប៉ះពាល់អីលើ ខៀវ សំផន ទេ ពីព្រោះថា យុត្តិសាស្ត្ររបស់សាលាដំបូងហ្នឹង គឺវាខុសទៅហើយ។ នៅពេលដែលនិយាយរឿងវិជ្ជមានទៅជាអវិជ្ជមាន និយាយច្បាស់ទៅហើយថាត្រូវខុសទៅវិញ តែបើសិនជាដាក់បន្ទុកគឺត្រូវរហូត។ ហើយឧទាហរណ៍ដូចជាករណីសីលធម៌១២ប្រការហ្នឹងជាដើម អត់ព្រមយកមកប្រើទេ។ ទាក់ទងនឹងសំណេររបស់ សីហនុ ដដែលហ្នឹង ខ្ញុំសូមលើកយកឧទាហរណ៍។ គេប្រើសំណេររបស់ សីហនុ ហ្នឹងដើម្បីនិយាយថា ខៀវ សំផន បានញុះញង់ដើម្បីឲ្យស្អប់ខ្មែរវៀតណាម ដោយនិយាយថាត្រូវស្អប់យួន។ នេះនៅក្នុងសៀវភៅរបស់សីហនុហ្នឹងគឺគាត់មានប្រើពាក្យហ្នឹងដែរ។ ហើយដែលយើង

មិនបានហៅ សីហនុ មកសួរដេញដោលហ្នឹង។ គឺយកសំណេររបស់គាត់ហ្នឹងមកទាញការសន្និដ្ឋានថា ខៀវ សំផន ញុះញង់ឲ្យស្រឡាញ់យួន -- អ៎! ស្អប់យួន ស្អប់កូនយួននិយាយជាទូទៅ។ នេះជាពាក្យសម្តីការរៀបរាប់កាលពីឆ្នាំ២០០០ ដោយ នរោត្តសីហនុ។

អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងកថាខណ្ឌ៤២៧០ ថា ខៀវ សំផន បានចូលរួមជ្រោមជ្រែងធ្វើយ៉ាងណា ដើម្បីអនុវត្តៗគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាតាមរយៈមុខតំណែងរបស់គាត់។ អ៊ីចឹងសុន្ទរកថាដែលប្រើដើម្បីគាំទ្រ យើងនិយាយហើយថា សុន្ទរកថារបស់ ខៀវ សំផន នៅឆ្នាំ១៩៧៨ ហ្នឹង បើយើងមិនប្រៀបគិតពីបរិបទជម្លោះប្រដាប់អាវុធជាមួយវៀតណាមនោះ មិនអាចយកសុន្ទរកថាហ្នឹងមកវិភាគបានទេ។ គាត់មិនមែននិយាយជាមួយប្រជាជនស៊ីវិលដែលគ្មានកំហុសអីនោះទេ ប៉ុន្តែចាប់តាំងពីឆ្នាំ -- ពាក់កណ្តាលឆ្នាំ១៩៧៧មក គឺវៀតណាមនោះបានចូលមកក្នុងប្រទេសកម្ពុជាទៅហើយ។

[១០:២៧:២៨]

គឺនៅក្នុងសារណារបស់យើងហ្នឹង គឺ១០៨០ និង ១០៨២ ហើយនិងឯកសារ 457/6/4/1 កថាខណ្ឌ៨០១ ដល់ ៨១១ ដែលយើងបាននិយាយអំពីពេលវេលាដែល ខៀវ សំផន ថ្លែងសុន្ទរកថារបស់គាត់នៅពេលណា ហើយតើគាត់និយាយនៅពេលដែលវៀតណាមវ៉ៃចូលស្រុកខ្មែរ ឬគឺក្រោយ ឬក៏យ៉ាងណា? អ៊ីចឹងបើសិនជាក្រោយពេលហ្នឹងគឺមិនអាចសុន្ទរកថាហ្នឹង មិនអាចនិយាយជាការស្វាគមន៍ទេ គឺដល់ពេលគាត់និយាយជាមួយនឹងយោធាខ្មែរក្រហមហ្នឹងគឺវា យើងត្រូវយល់ពីចំណុចហ្នឹង។

សារណារបស់យើងដដែលកថាខណ្ឌ១៨៣៦, ១៨៣៨ អង្គជំនុំជម្រះប្រើសៀវភៅ ខៀវ សំផន មួយទៀតក្រោយអង្គហេតុសម័យ សម័យអង្គហេតុនោះថាសៀវភៅហ្នឹង ក្នុងសរសេរហ្នឹងគឺថាមានការញុះញង់ឲ្យរើសអើងប្រជាជនថ្មីទៀតផង។ ហើយសាលាដំបូងខ្លួនឯងនិយាយថា ខ្លួននឹងប្រយ័ត្នប្រយែងក្នុងការប្រើសៀវភៅ ខៀវ សំផន នេះ ពីព្រោះថាវាជាការសង្កេតទូទៅលើអង្គហេតុដែលកើតក្រោយ -- ភស្តុតាងដែលកើតក្រោយអង្គហេតុ។ ហើយដែលមែនទែនទៅសាលាដំបូងបានប្រើភស្តុតាងទាំងអស់នេះ អ៊ីចឹងយោងទៅលើសារណារបស់យើង។ ហើយដូចនិយាយទាក់ទងទៅនឹងនៃការចូលរួមរបស់គាត់ហ្នឹង គឺមានចោទប្រកាន់ថា គាត់ហ្នឹងក្លែងបន្លំធ្វើដូចជាស្រុកខ្មែរយើង អ្វីៗកើតឡើងដូចធម្មតា។ ហើយដែលទាក់ទងនឹងជនជាតិចាមហ្នឹងគឺ -- ពុទ្ធសាសនិកហ្នឹងថា -- ទាក់ទងនឹងចាមគឺថាមានភស្តុតាងណាមួយដែលអាចបង្ហាញដល់កម្រិតថា ខៀវ សំផន នេះមានភស្តុតាងដែលបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះហ្នឹងថា បង្ហាញដល់កម្រិតមួយថា ខៀវ សំផន ហ្នឹងគឺមានចេតនាជាក់លាក់ ដើម្បីបំផ្លាញក្រុមចាម

សាសនាចាម ជាតិពន្ធុចាម។ **អ៊ី**ចឹងគាត់ត្រូវបានលើកលែងការចោទប្រកាន់ក្នុងចំណុចនេះ ហើយយើងមិនយល់ដែរ ព្រោះថាតើផ្អែកលើមូលដ្ឋានអី អត់មាន។ ឃើញថា ចេតនាជាក់លាក់ដើម្បីបង្ហាញថាមានចេតនារើសអើងលើជនជាតិចាមពីសំណាក់ ខៀវ សំផន ក៏ប៉ុន្តែអត់មានឃើញបង្ហាញអីផ្សេងទៀតពីគោលនយោបាយអី ហើយប៉ុន្តែនៅក្នុងគោលនយោបាយអីទាំងអស់នៅក្នុងទង់បដិវត្តហ្នឹង មិនបង្ហាញពីការរើសអើងហ្នឹងទេ។ នៅក្នុងមូលដ្ឋាននៃសាលក្រមដែលយើងបានជំទាស់ដែលថា ខៀវ សំផន ថា -- ដែលគេចោទប្រកាន់ថា ខៀវ សំផន គឺស្មៀម គឺស្មើនឹងយល់ព្រម។ ប៉ុន្តែចង់និយាយថា នៅស្មៀមនោះមិនមែនបានន័យថាញ៉ុះញង់ទេ។

[១០:៣១:១៨]

ឥឡូវខ្ញុំចូលមកដល់ផ្នែកបញ្ចប់នៃបទបង្ហាញរបស់ខ្ញុំ។ សួរថាតើភស្តុតាងណាខ្លះដែលត្រូវបញ្ជាក់ថា ខៀវ សំផន មិនដឹងអំពីការសម្លាប់ ហើយនិងការមនុស្សឃាតកើតឡើងនៅការដ្ឋានហ្នឹង ហើយនិងទាក់ទងទំនួលខុសត្រូវទម្រង់នៃទំនួលខុសត្រូវ ដែលមានការជួយ ហើយនិងជ្រោមជ្រែង? ចម្លើយរបស់ សីហនុ និងចម្លើយ ខៀវ សំផន គឺប្រៀបធៀបគ្នា។ សាលាដំបូងបានប្រើកថាខណ្ឌ៤២៦៥ គឺសៀវភៅ សីហនុ ដដែលហ្នឹង គឺថា មាននិយាយថា ខៀវ សំផន ហ្នឹងដឹងរឿងអ្វីៗទាំងអស់។ ហើយ ខៀវ សំផន ហ្នឹងបាននិយាយហើយថាគាត់មិនដឹងទេ ថានៅពេលដែលមានការទស្សនកិច្ចផ្លូវការទៅមើលសមិទ្ធផលនៅស្រុកខ្មែរហ្នឹង ដែលមាន សីហនុ អ្នកធ្វើដំណើរជាមួយនោះ គឺបាននិយាយជាសាធារណៈផ្សេងទេ គឺនិយាយថា អ្វីដែលគេបង្ហាញនៅមូលដ្ឋាននោះ វាអត់មានបញ្ហាអីទេ។ ក៏ប៉ុន្តែតាមពិតទៅយើងដឹងថាស្ថានភាពហ្នឹងវាមិនសម្បូរសប្បាយអីណានោះទេ កម្ពុជាប្រជាធិបតេយ្យនោះ គឺយើង -- អ៊ីចឹងហើយបាន ខៀវ សំផន ចង់ធ្វើបដិវត្តន៍ ដើម្បីផ្លាស់ប្តូរស្ថានភាពប្រជាជននោះ។ ប៉ុន្តែគោលបំណងមិនមែនធ្វើបាបប្រជាជននោះទេ ហើយមិនអំពើមនុស្សឃាតលើប្រជាជននោះទេ។ អ៊ីចឹងអង្គជំនុំជម្រះហ្នឹងបានធ្វើមិនដឹងឮ ដោយយោងលើសំណេររបស់ សីហនុ ហ្នឹង ដោយលើកឡើងថា -- នៅក្នុងសេចក្តីថ្លែងបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលរបស់យើង--

**ប្រធានអង្គជំនុំ៖**

សូមលោកស្រី គឺសូមផ្អាកបន្តិច ដើម្បីឲ្យខាងអ្នកបច្ចេកទេសគេប្តូរឌីវីឌីសិនបាទ។

*(សម្រាករយៈពេលខ្លី ប្តូរឌីវីឌី)*

[១០:៣៤:១៥]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្ត។

**លោកស្រី អង់តា ហ្គីសសេ៖**

អ៊ីចឹងគឺថា -- សហភាគារបស់ខ្ញុំសូមឲ្យលេខយោងអម្បាញ់មិញនេះមួយសាទៀត។ ខ្ញុំនិយាយថា នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើងនៅកថាខណ្ឌ២០២១ យើងរំឭកថា អង្គជំនុំជម្រះហ្នឹងមិនបានគិតអំពីទឡ្ហីករណ៍ដែលបង្ហាញពីភាពចម្រូងចម្រាសនៃសៀវភៅរបស់ សីហនុ ទេ យោងទាំងអស់នៅក្នុងកថាខណ្ឌ២០២១ របស់យើងនេះឯង។ ហើយនៅក្នុងសេចក្តីសន្និដ្ឋានយើងមួយទៀតហ្នឹង គឺឯក-សារ E1/234.1 នៅចន្លោះម៉ោង ១០:៥៨ នាទី នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលនេះ នៅកថាខណ្ឌ -- នៅៗកថាខណ្ឌ១១៧៣ ទាក់ទងនឹងលក្ខខណ្ឌជីវិតនេះ គឺនៅកថាខណ្ឌ ១០ -- ៥, ៧ -- ១៥០៧ហើយមានភស្តុតាងដោះបន្ទុកជាច្រើនដែលគេបោះបង់ចោល ហើយយើងៗបានបង្ហាញនៅពេលប្តឹងឧទ្ធរណ៍នុំងដែរ ក៏ប៉ុន្តែមិនដែលមានអ្នកណាគិតពីភស្តុតាងដោះបន្ទុកហ្នឹងទេ ក៏ -- ដូចជាករណីមាស វឿន ហ្នឹង។ យើងបានរំឭកគាត់ដែរ។ ឥឡូវខ្ញុំយោងទៅនឹងកថាខណ្ឌ១៨៧៧, ១៨៧៨ ដែលមាស វឿន ហ្នឹងគាត់ជាយោធា គឺសំខាន់ណាស់ គេបញ្ជូនគាត់ទៅតំបន់ភូមិភាគព្រះវិហារ។ សក្ខីកម្មរបស់គាត់ហ្នឹងគឺប្រើប្រាស់ហ្នឹង ដើម្បីបង្ហាញថា គាត់ហ្នឹងរាយការណ៍ ផ្ញើរបាយការណ៍មួយទៅ ខៀវ សំផន អ៊ីចឹងបង្ហាញថា ខៀវ សំផន ហ្នឹងពីការចាប់ខ្លួនរបស់ កង ចាប។ ក៏ប៉ុន្តែនៅក្នុងសំណុំរឿងរបស់យើងនោះគឺ នៅពេលដែលយើងសួរសំណួរទៅ មាស វឿន ហ្នឹងគឺការមិន -- មាស វឿន នេះ សវនាការថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ខ្ញុំសូមរំឭកថា កាលនោះយើងនិយាយអំពីចំណុចនេះនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើង នៅក្នុងកថាខណ្ឌ១៨៧៧ ហើយ ខៀវ -- ហើយគាត់នេះនៅក្នុងថ្ងៃសវនាការហ្នឹង គឺឯកសារ E1/1/32/1 ហើយគាត់និយាយ គាត់ផ្ញើរបាយការណ៍ទៅ ខៀវ សំផន យ៉ាងម៉េច? យើងសួរគាត់ថា អ្នកដែលទទួលបន្ទុកនោះ តេឡេក្រាមហ្នឹង? គាត់និយាយថា យើងមិនអាចផ្ញើសារដោយសារវាមានខ្សែខុសគ្នា។ គាត់និយាយថា សារហ្នឹងមិនបានផ្ញើទៅទេ ហើយគាត់និយាយបន្តមកទៀត ម៉ោង ១៤:១៥ គាត់ថា៖ មិនដឹងថា គាត់បានទទួលអត់ទេ ព្រោះអត់ៗបានចម្លើយពីគាត់មកវិញ។ អ៊ីចឹងគឺសក្ខីកម្មនេះ សាលាដំបូងប្រើដើម្បីប្រាប់ថាគាត់ដឹង។ អ៊ីចឹងសាក្សីឆ្លើយថាគាត់អត់ដឹងថា មិនដឹងថាគាត់បានទទួល ឬអត់ផង ហើយផ្អែកទៅលើសក្ខីកម្មហ្នឹង។

[១០:៣៨:០០]

ចំណុចមួយទៀតគឺទាក់ទងនឹងទីកន្លែងការងារដែល ខៀវ សំផន ដឹងនោះ ផ្នែក -- ខ្ញុំយោងទៅផ្នែកទី៥ នៃសារណាបណ្ដឹងឧទ្ធរណ៍របស់យើងហ្នឹង គឺកថាខណ្ឌ១៦០៤, ១៦១៥ កថាខណ្ឌ។ យើងនិយាយពីការដ្ឋានទាំងអស់ហ្នឹង ខ្ញុំក៏បានលើកឡើងផងដែរពីសក្ខីកម្មរបស់ ឌុច លើបញ្ហា -- ពីរឿងថាតើ ប៉ង់ និយាយប្រាប់គាត់ ហើយ ខៀវ សំផន ហ្នឹងដឹងអំពីអ្វីខ្លះ ឬនិយាយពាក្យចចាមអារ៉ាមថា នៅស-២១ គេមានធ្វើអីខ្លះ? ធ្វើទារុណកម្ម ឌុច ជាប្រធានមន្ទីរឃុំឃាំងហ្នឹង ហើយអង្គជំនុំជម្រះថា អត់ទេ អត់មានការធ្វើទារុណកម្មលើ ប៉ង់ ទេ ពីព្រោះអង្គ -- សាលាដំបូងចង់ប្រើសក្ខីកម្មហ្នឹង ដើម្បីដាក់បន្ទុកលើ ខៀវ សំផន ដើម្បីឲ្យ ខៀវ សំផន ជាប់ពាក់ព័ន្ធនឹងគោលនយោបាយដែលចោទប្រកាន់។

ខ្ញុំមិននិយាយអំពីវត្តមានរបស់គាត់នៅភ្នំពេញ ឬក៏ភស្តុតាង ឬក៏មុខងារគាត់ គាត់មិនដែលបដិសេធទេ ប៉ុន្តែគេចេះតែទាញការសន្និដ្ឋានព្រាវៗ ពីៗចម្លើយរបស់សាក្សីដែលអត់មានចម្លើយណាគាំទ្រនោះ ដូច ជា ឌៀប តែម្នាក់ឯងគត់និយាយពី ខៀវ សំផន និយាយពីការ និយាយថា ខៀវ សំផន ហ្នឹងសុំឲ្យគេរៀបចំការរៀបការហ្នឹង ហើយសំណេររបស់ សីហនុ ដែលប្រើឡើងដើម្បីបង្ហាញពីអំពើរបស់ជនជាប់ចោទ ដែលមានភាពចម្រូងចម្រាសជាច្រើន ហើយមិនដែលមានការដកស្រង់មកប្រើទេ ដោយសាលាដំបូង។

[១០:៤០:០៥]

ពេលដែលយើងសួរចម្លើយទៅសាក្សីរបស់មេធាវីការពារក្ដីនេះ គឺអត់ដែលយកមកប្រើទេ ហើយយើងកោះសាក្សីមួយចំនួននោះ គឺអត់ព្រមកោះហៅមកតាមយើងទេ។ ទាំងអស់នេះជាភស្តុតាង ហើយជាពិសេសនេះគឺថាមានសញ្ញាណមួយដែលសាលាដំបូងនោះ មិនព្រមយល់ថា ខៀវ សំផន អាចអត់ដឹងឮ។ នេះជាបញ្ហាក្នុងសំណុំរឿងមួយ។ អ៊ីចឹងបើគាត់នៅភ្នំពេញគាត់ គាត់ត្រូវតែដឹង។ ក៏ប៉ុន្តែនៅក្នុងសំណុំរឿង០០២/០១ ដូច -- យើងរំឭករឿងហ្នឹងនៅក្នុងសំណុំរឿង០០២ផងដែរ។ ខ្ញុំជិតបញ្ចប់ហើយលោកប្រធាន។ ខ្ញុំដឹងថាពេលវេលាខ្ញុំជិតអស់ហើយ។

យើងបាន -- ពេលមួយនោះគឺថា ដោយសារគេអត់មានភស្តុតាងច្បាស់លាស់ដើម្បីបញ្ជាក់ថាគាត់ដឹងថាយ៉ាងម៉េច? មានភស្តុតាងគាំទ្រទេ ក៏ប៉ុន្តែដោយសារគាត់នៅទីក្រុងភ្នំពេញ គាត់មានតួនាទីជាប្រធានរដ្ឋ គាត់មានមុខងារនៅក្នុងរដ្ឋាភិបាលអីជាដើម គាត់ត្រូវដែលដឹងឮ គាត់ចូលរួមប្រជុំនៅក្នុងគណៈអចិន្ត្រៃយ៍ ប៉ុន្តែគាត់មិនមែនជាសមាជិកអចិន្ត្រៃយ៍នោះទេ។ ហើយមាន -- អ៊ីចឹងព្រះរាជអាជ្ញាក៏មិនដែលបង្ហាញថាឧក្រិដ្ឋកម្មដែលកើតឡើងហ្នឹងមានភស្តុតាងអីច្បាស់លាស់ដែរ។ មានរឿងមួយដែល

គាត់អាន គឺថាតាមពិត ខៀវ សំផន ខ្លួនឯងផ្ទាល់ហ្នឹង គាត់អានឯកសារជាច្រើនដែលក្រោយសម័យអង្គហេតុអីហ្នឹង។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី គឺថាមូលហេតុតែមួយគាត់ដែលសាលាដំបូងហ្នឹង គឺគាត់បំភ្លៃខ្លឹមសារនៃសហឧក្រិដ្ឋកម្មរួម ដែលថាមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីទាញការសន្និដ្ឋានដែល ខៀវ សំផន មានទំនួលខុសត្រូវថាគាត់ មានចេតនាផ្ទាល់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយនិងចេតនាផ្ទាល់ក្នុងការចូលរួមក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយដែលចោទប្រកាន់។ អ៊ីចឹងហើយបានយើងខ្ញុំឱ្យតុលាការកំពូលទាត់ -- បដិសេធចោលនូវសេចក្តីសន្និដ្ឋានទាំងអស់របស់សាលាដំបូង។ វាមិនបញ្ហាអីទេ គឺ ខៀវ សំផន នៅតែជាប់គុក ហើយនិងកេរ្តិ៍ឈ្មោះរបស់ អ.វ.ត.ក ហ្នឹងនឹងល្បីល្បាញហើយ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមប្រកាសសម្រាក នឹងចូលវិញនៅវេលាម៉ោងដប់មួយ និងប្រាំនាទី។ សូមសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:៤២នាទី ដល់ ម៉ោង ១១:០៨នាទី)*

[១១:០៨:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសារណា។

**លោក វីណ្ឌៀម ស្មីត៖**

សូមគោរពឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម។ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ការផ្តន្ទាទោសផ្អែកទៅលើការប្រព្រឹត្តរបស់គាត់។ ហើយវាមានកំហុសឆ្គងបី។ ទី១ គឺលក្ខណៈនៃគោលបំណងរួម ទី២ ការចូលរួមរបស់គាត់នៅក្នុងគោលបំណងរួម និងទី៣ ចេតនារបស់គាត់ក្នុងការចូលរួមក្នុងគោលបំណងរួម ហើយនិងចេតនានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋជាមូលដ្ឋានទាំងអស់នេះ។ ខ្ញុំនឹងនិយាយអំពីគោលបំណងរួម និងចេតនាក្នុងការប្រព្រឹត្ត ហើយព្រះរាជអាជ្ញាអន្តរជាតិនឹងពិភាក្សាពីការចូលរួមនៅក្នុងគោលបំណងរួម ព្រមទាំងការទទួលខុសត្រូវចំពោះការជួយ និងជំរុញដល់អំពើមនុស្សឃាត។ អំពីគោលបំណងរួមវិញ មូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខគឺផ្អែកទៅលើការបកស្រាយខុសទៅលើច្បាប់ ហើយនិងការមិនគិតពិចារណាទៅដល់ភស្តុតាងជារួម។ គាត់ជំទាស់ថាគោលបំណងរួមដែលបក្សកុម្មុយនីស្តកម្ពុជាចង់បាន គឺការបង្កើតដោយមានប្រយោជន៍ទៅដល់សង្គមល្អមួយ តាមរយៈបដិវត្តន៍សង្គម

និយម ដោយលើកឡើងថាឧក្រិដ្ឋកម្មទាំងអស់ដែលធ្វើឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺហួសពីការគ្រប់គ្រងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គឺជា -- គឺបានន័យថាជាការអនុវត្តខុសពីគោលនយោបាយ មិនមែនជាគោលនយោបាយឡើយ។ ប៉ុន្តែ ភស្តុតាងជាច្រើនបានគាំទ្រដល់ការសម្រេចរបស់សាលាដំបូង ដែលបង្ហាញថាឧក្រិដ្ឋកម្មទាំងអស់នេះគឺជាផ្នែកមួយក្នុងការអនុវត្តបដិវត្តសង្គមនិយម។ ទោះបីថាអង្គជំនុំជម្រះបានរកឃើញថាគោលបំណងជាចម្បងនៃគោលបំណងរួម គឺជាលក្ខណៈមិនមានភាពជាឧក្រិដ្ឋក៏ដោយ ប៉ុន្តែពួកគេព្យាយាមស្វែងរកមធ្យោបាយដើម្បីសម្រេចគោលបំណងនោះ។ ដូច្នេះហើយទើបធ្វើឱ្យគោលបំណងរួមនោះគឺវាមានលក្ខណៈជាបទឧក្រិដ្ឋទៅវិញ។ ការរៀបចំគោលបំណងរួម គឺស្របជាមួយនឹងនិយមន័យរបស់លោក លោកស្រីចៅក្រម ដែលថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមត្រូវតែមានគោលបំណងចម្បងមួយ គឺការប្រព្រឹត្តឧក្រដ្ឋិកម្ម ឬក៏គាំទ្រទៅដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដើម្បីជាមធ្យោបាយក្នុងការសម្រេចគោលដៅមួយ ទោះបីថា គោលដៅហ្នឹងមិនមែនលក្ខណៈជាបទល្មើសក៏ដោយ។ អង្គជំនុំជម្រះបានរកឃើញគោលបំណងរួម ដែលម្ចាស់បណ្ដឹងសាទុក្ខ និងមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដទៃទៀត គឺអនុវត្តឱ្យបានឆាប់រហ័សនូវបដិវត្តសង្គមនិយមនៅក្នុងប្រទេសកម្ពុជា តាមរយៈមហាលោតផ្លោះ មហាអស្ចារ្យ ដែលរៀបចំឡើងដើម្បីកសាងការពារប្រទេសពីខ្មាំង ហើយនិងធ្វើឱ្យប្រជាជនក្លាយទៅជាសង្គមដែលមិនមានជំនឿសាសនា មានពូជសាសន៍តែមួយហើយជាសង្គមកសិករ។

[១១:១២:១៨]

អង្គជំនុំជម្រះរកឃើញថា មានការអនុវត្តនៅទូទាំងប្រទេសដោយបក្សកុម្មុយនីស្តកម្ពុជា គឺនៅតាមភូមិភាគ តំបន់ ស្រុក ហើយនិងកម្រិតមូលដ្ឋាន។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងកងកម្លាំងបដិវត្តន៍កម្ពុជា តាមរយៈការអនុវត្តគោលនយោបាយយ៉ាងតិចក៏ប្រាំ។ ទាំងអស់ -- គោលនយោបាយទាំងអស់នេះគឺទាក់ទងដែលផ្ទាល់ជាមួយនឹងគោលបំណងរួម ហើយវាពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ធ្វើឱ្យគោលបំណងរួមហ្នឹងក្លាយទៅជាបទឧក្រិដ្ឋ។ ជាមូលដ្ឋានម្ចាស់បណ្ដឹងសាទុក្ខបានជំទាស់ថាអង្គជំនុំជម្រះមានកំហុសឆ្គងដោយសម្រេចថាគោលនយោបាយឧក្រិដ្ឋទាំងអស់នេះ គឺបង្កើតឡើង។ ប៉ុន្តែផ្អែកទៅលើភស្តុតាងជាច្រើននៅចំពោះមុខអង្គជំនុំជម្រះ គឺមិនមានកំហុសឆ្គងបែបនោះទេ។ ឧទាហរណ៍ ប្រសិនបើយើងមើលទៅការសម្រេចរបស់អង្គជំនុំជម្រះដែលថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបង្កើតគោលនយោបាយ ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន បំបែក ហើយនិងកម្ទេចខ្មាំងធ្ងន់ធ្ងរ

បំផុតនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មុស្ស ហើយនិងអប់រំរៀនសូត្រសមាសភាពមិនល្អ។ ទឡ្ហីករណ៍គឺថាវាច្បាស់លាស់ណាស់ ហើយមិនមែនតែគោលនយោបាយទេ គឺវាផ្ទុយទៅនឹង -- គឺវាមានការជំទាស់យ៉ាងខ្លាំងដោយភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានរកឃើញថា គោលនយោបាយទាំងអស់នេះមានរួមពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដាក់ក្នុងមន្ទីរឃុំឃាំង ការដាក់ឱ្យទៅជាទាសករ អំពើអមនុស្សធម៌ដទៃទៀត តាមរយៈការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការបាត់បង់ដោយ -- ការបាត់ខ្លួនដោយបង្ខំ ការធ្វើទារុណកម្ម អំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ គឺត្រូវបានធ្វើឡើងផ្អែកលើមូលដ្ឋានជាប្រព័ន្ធ និងទូលំទូលាយ គឺបានសម្រេចថាមានមន្ទីរសន្តិសុខយ៉ាងហោចណាស់ ២០០ ត្រូវបានបង្កើត ហើយនិងប្រតិបត្តិនៅទូទាំងប្រទេស។ អង្គជំនុំជម្រះរកឃើញថាគោលនយោបាយខ្មាំងនេះត្រូវបានបញ្ជាពីកម្រិតខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយត្រូវបានអនុវត្តនៅតាមបណ្តាញរដ្ឋបាលទាំងស្រុងតែម្តង។

[១១:១៤:៣៦]

ពួកគេរកឃើញថា មានទំនាក់ទំនងច្បាស់លាស់ជាមួយគោលបំណងរួម ដែលធ្វើឱ្យគោលនយោបាយនេះមានលក្ខណៈឧក្រិដ្ឋ។ ឯកសារ E3/12 បានបង្ហាញថា -- បង្ហាញពីលក្ខណៈរួមនៃគោលនយោបាយ។ វាគឺជាសេចក្តីសម្រេចរបស់គណៈមជ្ឈិម គឺជាគណៈកម្មាធិការខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលទទួលស្គាល់នៅក្នុងលក្ខន្តិកៈបក្ស។ ហើយជាគណៈកម្មការដែលម្ចាស់បណ្តឹងសាទុក្ខនៅក្នុងនោះដែរ គឺចុះថ្ងៃទី -- លិខិតនោះចុះថ្ងៃទី៣០ មីនា ៧៦។ នៅក្នុងសេចក្តីសម្រេចនេះ គណៈកម្មការបានប្រគល់សិទ្ធិទៅដល់ភូមិភាគ ទៅដល់មជ្ឈិមបក្ស ហើយនិងគណៈនានា គឺមានសិទ្ធិកម្ទេចបក្សក្នុងជួរនិងក្រៅ កម្ទេចខ្មាំងនៅក្នុងជួរ និងក្រៅជួរ។ គឺវាបញ្ជាក់ពីគោលបំណងបង្កើតក្របខ័ណ្ឌមួយក្នុងការអនុវត្តគោលនយោបាយដាច់ខាត ដើម្បីពង្រឹងប្រជាធិបតេយ្យសង្គមនិយម ហើយនិងពង្រឹងទៅលើសិទ្ធិអំណាច ឬក៏អំណាចរបស់បក្សរបស់រដ្ឋយើង។

និយាយម្យ៉ាងទៀត សេចក្តីសម្រេចហ្នឹងគឺផ្តល់សិទ្ធិអំណាចក្នុងការសម្លាប់ខ្មាំង ដែលចេញពីកំពូលបក្សចុះទៅ គឺបានន័យថាពីកំពូល ពីថ្នាក់ដឹកនាំកំពូលដែល ខៀវ សំផន នៅក្នុងនុំងដែរ ហើយចុះបន្តទៅតាមលំដាប់លំដោយនៅទូទាំងប្រទេស។ មន្ទីរសន្តិសុខស-២១ គឺជាឧទាហរណ៍យ៉ាងច្បាស់លាស់មួយអំពីការអនុវត្តគោលនយោបាយនេះនៅទូទាំងប្រទេស ព្រោះថាមានឯកសាររាប់ពាន់ដែលបាននៅសេសសល់ ហើយមានអតីតបក្សកុម្មុយនីស្តកម្ពុជា និងជនរងគ្រោះដែលជាសាក្សីមកផ្តល់សក្ខីកម្ម។

អង្គជំនុំជម្រះបានរកឃើញថា គឺមានអ្នកទោសស-២១ ដែលបានចុះបញ្ជី មានជាង ១១.៧៤២ ត្រូវបានសម្លាប់ក្នុងរយៈពេលប្រហែលជាបីឆ្នាំកន្លះនៃប្រតិបត្តិការ អ្នកទោសត្រូវបានចាប់ខ្លួនពីភូមិភាគ ពីកងពលធំ ពីក្រសួងរបស់កម្ពុជាប្រជាធិបតេយ្យដែលជាលទ្ធផលនៃការបោសសម្អាតទូទាំងប្រទេសទៅលើខ្មាំងបក្សកុម្មុយនីស្តកម្ពុជា។ អង្គជំនុំជម្រះរកឃើញថា មន្ទីរនេះគឺគ្រប់គ្រងដោយសមាជិកគណៈអចិន្ត្រៃយ៍គឺ សុន សេន ហើយនិង នួន ជា តាមរយៈសេនាធិការ។

[១១:១៧:០៥]

ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ គឺថាការសម្លាប់ក្រៅប្រព័ន្ធតុលាការរបស់ខ្មាំងបក្សកុម្មុយនីស្ត គឺមិនមែនជាគោលនយោបាយទេ ប៉ុន្តែជាការងាកចេញ ឬក៏ការអនុវត្តផ្ទុយដោយមិន -- ហើយការលើកឡើងនេះគឺមិនមានភាពសមស្រប មិនមានការវាយតម្លៃទៅលើភស្តុតាង។ ទឡ្ហីករណ៍បន្ថែមមកទៀតគឺថា ការប្រើប្រាស់ពាក្យដូចជា “ការបោសសម្អាតខ្មាំង” នៅក្នុងសុន្ទរកថារបស់គាត់ក្តី របស់មេដឹកនាំកុម្មុយនីស្តកម្ពុជាក្តី ព្រមទាំងឯកសាររៀនសូត្រ និងឃោសនានានា គឺគ្រាន់តែជាទ្រឹស្តីរបស់ ម៉ាកឡេនីន ប៉ុណ្ណោះ គឺដើម្បីដែលនិយាយថាលុបបំបាត់ ឬក៏កម្ទេចខ្មាំងនយោបាយ ខ្មាំងមនោគមន៍វិជ្ជា គឺវាមិន។ ប៉ុន្តែយ៉ាងណាក៏ដោយ គឺមានភស្តុតាងជាច្រើនដែលថាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានសម្លាប់នៅទូទាំងប្រទេស។ ឥឡូវនេះខ្ញុំនឹងនិយាយអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការបង្កើតនិងប្រតិបត្តិសហករណ៍ ហើយនិងការដ្ឋានដែលមិនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនោះ។ ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខមិនបានគិតទៅដល់ភស្តុតាងជារួមទាំងអស់នោះទេ។ អង្គជំនុំជម្រះយល់ -- បានសម្រេចថាគោលនយោបាយហ្នឹងគឺពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃការដាក់ឲ្យទៅជាទាសករ អំពើអមនុស្សធម៌ដទៃទៀតតាមរយៈការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ អំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដែលផ្អែកទៅលើទំហំ និងរយៈពេលនៃឧក្រិដ្ឋកម្មនេះនៅតាមទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ បក្សកុម្មុយនីស្តកម្ពុជាបានរកឃើញថាសម្តេច នរោត្តម សីហនុ បានប្រៀបធៀបការដ្ឋានទាំងអស់នោះទៅនឹងជំរំប្រមូលផ្តុំបន្ទាប់ពីបានទៅទស្សនកិច្ចនៅតាមកន្លែងនោះ។

[១១:១៨:៤៨]

ហើយវាមានឯកសារភស្តុតាង ឯកសារសាក្សីជាច្រើននៅចំពោះមុខអង្គជំនុំជម្រះដែលកំណត់អំពីការគ្រប់គ្រងទាំងស្រុងរបស់បក្សកុម្មុយនីស្តទៅលើ គ្រប់ចំណុច គ្រប់ផ្នែកទាំងអស់នៃជីវិតរបស់មនុស្ស។ ការសម្រេចបានរកឃើញថា កម្មាភិបាលបក្សកុម្មុយនីស្តដែលទទួលខុសត្រូវ គឺផ្តោតទៅលើ

ការបំពេញទៅតាមគោលដៅផលិតកម្មរបស់ថ្នាក់ដឹកនាំ ទោះបីថាបើត្រូវចំណាយអ្វីក៏ដោយ ដោយត្រូវបង្ខំប្រជាជនឲ្យធ្វើការច្រើនម៉ោង ធ្វើការហត់នឿយ ឬក៏ក្នុងស្ថានភាពដ៏អាក្រក់ក៏ដោយ។ អ្នកដែលមិនអាចបំពេញតាមគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា គឺមិនធ្វើការ មិនប្រឹងប្រែងឲ្យគ្រប់គ្រាន់ ត្រូវទទួលទណ្ឌកម្ម។ អ្នក -- ប្រជាជនទទួលរងការឈឺចាប់ ហើយស្លាប់ដោយសារតែការអស់កម្លាំង ខ្វះអាហារ ព្រមទាំងមិនមានការព្យាបាល ព្រមទាំងកន្លែងរស់នៅដែលមិន -- ដែលគគ្រិច។ គ្រួសារត្រូវបានគេបំបែក ហើយប្ដីប្រពន្ធមិនអាចជួបគ្នាដោយសេរីភាពនោះឡើយ។

[១១:២០:០០]

អង្គជំនុំជម្រះបានរកឃើញថា គោលនយោបាយទាំងអស់នេះមានគោលដៅច្រើន ដែលពាក់ព័ន្ធទៅនឹងគោលបំណងរួម។ គោលដៅមួយគឺជាកត្តាជំរុញក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ព្រមទាំងស្បៀងអាហារសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និងការនាំចេញទៅក្រៅដើម្បីបង្កើតមូលធន។ ទី២ គឺកម្ទេចនូវប្រព័ន្ធវណ្ណៈបង្ខំឲ្យប្រជាជននៅតាមទីក្រុងក្លាយទៅជា កម្មករ កសិករ ជំនួសកម្មសិទ្ធិឯកជនដោយសហករណ៍។ ទី៣ គឺជារចនាសម្ព័ន្ធគ្រប់គ្រងដើម្បីស្វែងរកខ្មាំង ដោយតម្រូវឲ្យមានការស្រង់ប្រវត្តិរូប និងគ្រប់គ្រងទៅលើអាកប្បកិរិយាដែលប្រឆាំងបដិវត្តន៍ដែលអ្នកណាដែលធ្វើគឺត្រូវបាត់ខ្លួន ឬក៏ត្រូវសម្លាប់។ ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខគឺថា អង្គជំនុំជម្រះមានកំហុសឆ្គង ដោយព្យាយាមធ្វើឲ្យគោលនយោបាយហ្នឹងទៅជាឧក្រិដ្ឋ ដោយប្រើប្រាស់ទម្រង់ ភស្តុតាងជាទម្រង់ដែលមិនត្រឹមត្រូវទៅលើឧក្រិដ្ឋកម្មដែលនៅក្រៅទីតាំងដែលត្រូវបានគេចោទប្រកាន់ ដែលបកស្រាយខុសទៅលើពាក្យមុនសម័យកម្ពុជាប្រជាធិបតេយ្យ គឺពាក្យគ្រប់គ្រង និងចាប់ប្រជាជន ហើយមិនបានទទួលស្គាល់ពីសារៈសំខាន់នៃការបញ្ជូនស្រូវទាំងអស់នាំចេញ ដោយមិនគិតពីសារៈសំខាន់ ឬក៏ជំនួញយ៉ាងច្រើននៃស្រូវដែលនាំចេញ។ ទី១ គឺជាច្បាប់ដែលថា ភស្តុតាងនៅក្រៅវិសាលភាព ពេលវេលា និងភូមិសាស្ត្រ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចប្រើប្រាស់ ដើម្បីបញ្ជាក់បំភ្លឺទៅលើបរិបទបង្ហាញអំពីទម្រង់ជាចេតនានៃការប្រព្រឹត្ត និងការកំណត់ធាតុផ្សំនៃអំពើឧក្រិដ្ឋដែលបានចោទប្រកាន់។

[១១:២១:៣៣]

ទី២ ពាក្យរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថាគ្រប់គ្រងនិងចាប់ខ្លួន គឺត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ជាភស្តុតាង ដើម្បីគាំទ្រទៅដល់លក្ខណៈឧក្រិដ្ឋនៃគោលនយោបាយ។ ហើយម្ចាស់បណ្ដឹងសាទុក្ខអត់បានជំទាស់នោះទេ គឺមិនដូចអ្វីដែលម្ចាស់បណ្ដឹងសាទុក្ខបានជំទាស់នោះទេ។ ទី៣ អង្គជំនុំជម្រះ

ទទួលស្គាល់ថាមានស្រូវ អង្ករមួយចំនួនត្រូវបានរក្សាទុកសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែវាអត់អាចផ្លាស់ប្តូរដែលថាមានការធ្វើបាបនៅតាមការដ្ឋាន ឬក៏ទីកន្លែងពលកម្មនោះឡើយ។ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខគឺថា គោលនយោបាយហ្នឹងវាមានប្រយោជន៍ដោយមិនគិតថា បក្សកុម្មុយនីស្តទទួលយកចំណាយនៃការអនុវត្ត តាមរយៈការរំលោភទៅលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ប្រជាជនជាប្រព័ន្ធនោះទេ។

ដូចដែលសហការីរបស់ខ្ញុំបានពិភាក្សារួចហើយនៅក្នុងមូលដ្ឋានទាក់ទងទៅនឹងការកំណត់គោលដៅទៅក្រុមជាក់លាក់ ក៏ដូចជាវៀតណាម ខ្មែរ វៀតណាម ចាម កម្មាភិបាលខ្មែរ សាធារណរដ្ឋខ្មែរ ពុទ្ធសាសនិកជន និងការគ្រប់គ្រងទៅលើជាដើម។ កាលពីម្សិលមិញហ្នឹង ខ្ញុំឥឡូវហ្នឹងនឹងនិយាយអំពីមូលដ្ឋានដែលគាត់ចោទប្រកាន់ទាក់ទងទៅនឹងកំហុសឆ្គង និងការសម្រេចថាគាត់មានចេតនាចូលរួម។ ទី១ គឺថាដើម្បីបង្ហាញអំពីចេតនា ឬក៏ការដឹងឮអំពីឧក្រិដ្ឋកម្ម ផ្ទុយពីទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខគឺមិនចាំបាច់ត្រូវបង្ហាញថាមានចេតនា ឬក៏ដឹងអំពីឧក្រិដ្ឋកម្មជាក់លាក់ណាមួយឡើយ។ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី ក្រលិចស្តារឌីស្រ្ទិច និង ស្ស៊ីបចានីង តូលីងម៉័រ ហើយនិង សេសាយ ជាដើមបានសម្រេចថា នៅពេលដែលជនជាប់ចោទមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏បានដឹងឮថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តអនុលោមទៅតាមគោលបំណងរួម គឺវាមិនចាំបាច់ត្រូវបង្ហាញអំពីចេតនា ឬក៏ការដឹងឮអំពីហេតុការណ៍ឧក្រិដ្ឋកម្មជាក់លាក់ណាមួយ ដែលកើតឡើងនៅទីកន្លែងជាក់លាក់ណាមួយនៅពេលវេលា ឬក៏ប្រឆាំងទៅលើជនរងគ្រោះជាក់លាក់ណាមួយ ដើម្បីបង្ហាញពីធាតុផ្សំនោះឡើយ។ តាមពិតទៅវាជារឿងប្រឌិតទាំងស្រុង។ វាមិនមែនជាការអនុវត្តជាក់ស្តែងដែលធ្វើឲ្យជា -- ការលើកទាំងអស់នេះវាធ្វើឲ្យខូចខាតទៅដល់គោលបំណងនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ដែលថាតម្រូវឲ្យមានការដឹងឮ ឬក៏មានចេតនាច្បាស់លាស់អំពីគ្រប់ឧក្រិដ្ឋកម្ម និងឧក្រិដ្ឋកម្មមួយៗ ដែលបានប្រព្រឹត្ត។ ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខមានចេតនា ឬក៏បានដឹងអំពីលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តអនុលោមទៅតាមគោលបំណងរួម គឺគ្រប់គ្រាន់ណាស់ទៅហើយ។

[១១:២៤:២៣]

ទី២ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា សាលាដំបូងសម្រេចទៅលើចេតនារបស់គាត់ដោយគ្រាន់តែការចូលរួមរបស់គាត់នៅក្នុងគោលបំណងរួម គឺមិនមានការបញ្ជាក់ច្បាស់លាស់។ ដោយ-សារតែច្បាស់លាស់ណាស់ថា អង្គជំនុំជម្រះបានសម្រេចថាផ្អែកទៅលើការដឹងឮរបស់ម្ចាស់បណ្តឹង

សាទុក្ខទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តអនុលោមទៅតាមគោលបំណងរួម ហើយនិងការចូលរួមជាបន្តបន្ទាប់របស់គាត់នៅក្នុងឧក្រិដ្ឋកម្មរួម។

ទាំងនេះខ្ញុំនឹងនិយាយអំពីការដឹង ព្រមទាំងចេតនា។ ហើយសហព្រះរាជអាជ្ញាអន្តរជាតិនឹងនិយាយអំពីមូលដ្ឋានទាក់ទងទៅនឹងការចូលរួមជាបន្តបន្ទាប់របស់គាត់។ អង្គជំនុំជម្រះបានកំណត់ថាបានកំណត់អំពីការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខទៅលើគោលបំណងរួម តាមរយៈភស្តុតាង និងការវិភាគទៅភស្តុតាងនៅមុនសម័យខ្មែរក្រហម និងក្នុងសម័យខ្មែរក្រហម។ និយាយអំពីភស្តុតាងសម័យមុនខ្មែរក្រហម អង្គជំនុំជម្រះសន្និដ្ឋានថា នៅពេលដែលចូលមកដល់របបខ្មែរក្រហមម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីគោលនយោបាយ ហើយដឹងអំពីលទ្ធភាពដែលថា ឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្តឡើងដោយផ្អែកទៅតាមគោលបំណងរបស់គោលនយោបាយនោះ។

ពួកគេផ្អែកទៅលើ ទី១ សមាជិកភាពរបស់គាត់រយៈពេលយូរអង្វែងនៅក្នុងបក្សកុម្មុយនីស្តកម្ពុ-ជា។ ទី២ ការគាំទ្ររបស់គាត់ទៅលើសេដ្ឋកិច្ចសមូហភាពតឹងរ៉ឹង។ និងទី៣ គឺការស្នើ -- ការអំពាវនាវរបស់គាត់ឲ្យកម្ទេចកម្មាភិបាលសាធារណរដ្ឋខ្មែរ តាមរយៈមធ្យោបាយហិង្សា។ អង្គជំនុំជម្រះក៏ផ្អែកទៅលើការសន្និដ្ឋាននេះទៅលើ ដែលថានៅតំបន់រំដោះគោលនយោបាយ។ បក្សកុម្មុយនីស្តកម្ពុជាត្រូវបានរដ្ឋហើយបណ្តាលឲ្យមានទម្រង់នៃការប្រព្រឹត្តនានាដែលមានលក្ខណៈជាឧក្រិដ្ឋកម្ម ដូចជា ការបង្កើតសហករណ៍ដោយបង្ខំ ដើម្បីបង្កើនការផលិតស្រូវអង្ករ ការបិទទីផ្សារ ការបង្ខំឲ្យព្រះសង្ឃផ្សឹក ហើយនិងដែលទាំងអស់នេះគឺជាផ្នែកនៃគោលនយោបាយសមូហភាព។ ការរៀបការ ហើយនិងខ្មាំង ឬក៏អ្នកប្រឆាំងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ឬអ្នកដែលមានទំនាក់ទំនងជាមួយវៀតណាម ត្រូវបានគេសម្លាប់ និងការបោសសម្អាតរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងជួររបស់ខ្លួន។

[១១:២៦:៤២]

ម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់អំពីការដឹងឮរបស់គាត់ក្នុង -- ទៅលើការអនុវត្តជាព្រហ្មទណ្ឌរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ដូចជានៅក្នុងសៀវភៅរបស់គាត់គឺ E3/18 ជាដើមដែលគាត់បញ្ជាក់ថា ខ្ញុំសុំដកស្រង់៖ “ខ្ញុំមិនអាចនៅកណ្តាលបានទេ។ នៅក្នុងព្រឹត្តិការណ៍នយោបាយសំខាន់ៗនៅពេលនោះ ខ្ញុំត្រូវតែប្រកាន់យកម្ខាងណាមួយដោយៗត្រូវតែធ្វើ ទោះបីថាមាន -- ទោះបីជាមានកេរ្តិ៍ឈ្មោះមិនល្អ ឬក៏អំពើផ្ទុយក៏ដោយ ដូច្នេះហើយ ខ្ញុំធ្វើដូច្នេះដើម្បីការពារបូរណភាពទឹកដីកម្ពុជា”។ ដូច្នេះម្ចាស់បណ្តឹងសាទុក្ខដឹងច្បាស់អំពីលក្ខណៈឧក្រិដ្ឋកម្មនៃបក្ស ដែលនៅពេលគាត់ចូលមកក្នុងរបបកម្ពុជា

ប្រជាធិបតេយ្យ ប៉ុន្តែគាត់នៅតែសម្រេចចិត្តចូលហើយគាំទ្រពួកគេដដែល។

នៅក្នុងការវាយតម្លៃផ្សេងមួយទៀត អង្គជំនុំជម្រះបានវិភាគអំពីការដឹងឮអំពីគោលបំណងរួម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានសម្រេចថាគាត់ដឹងថាមានការប្រព្រឹត្ត។ ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា ការសម្រេចនេះខុសគឺផ្ទុយទាំងស្រុងទៅលើការសម្រេចជារួម ហើយនិងភស្តុតាងដែលគាំទ្រថាតើគាត់ទទួលបានការដឹងឮហ្នឹងដោយរបៀបណា? ពួកគេរកឃើញថា គាត់ដឹងឮតាមរយៈតួនាទីថ្នាក់ដឹកនាំរបស់គាត់ សិទ្ធិក្នុងការជួបជាមួយមេដឹកនាំជាន់ខ្ពស់ ឬក៏មេដឹកនាំដែលមានសិទ្ធិអំណាចបំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា និងការធ្វើដំណើរនៅទូទាំងប្រទេស ការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងសេចក្ដីថ្លែងការណ៍របស់គាត់ និងមេដឹកនាំដទៃទៀតទាក់ទងទៅនឹងគោលនយោបាយទាំងប្រាំ ការទទួលបាននូវឯកសារបណ្ដុះបណ្ដាល និងឯកសារនយោបាយ ដូចជា ទស្សនាវដ្ដីទង់បដិវត្ត ទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត ការចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាល និងវគ្គអប់រំរៀនសូត្រ ដែលគេផ្សព្វផ្សាយអំពីគោលនយោបាយឧក្រិដ្ឋ អំពីការពិភាក្សា ការដកស្រង់ រួមទាំងការប្រព្រឹត្តជាឧក្រិដ្ឋទៅលើខ្លាំង។ ទី៣ ការទទួលរបាយការណ៍ពីស្ថាប័នអន្តរជាតិ ទាក់ទងទៅនឹងអំពើសាហាវយង់ឃ្នងប្រឆាំងទៅលើមន្ត្រីរបបសាធារណរដ្ឋខ្មែរ និងអ្នកផ្ដាច់ខ្លួនពីបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងការបដិសេធរបស់គាត់ជាសាធារណៈទៅលើអំពើហិង្សាទាំងអស់នោះ។

[១១:២៩:១៣]

ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អង្គជំនុំជម្រះមានកំហុសឆ្គង ដែលសម្រេចថា គោលនយោបាយការសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា គឺមានលក្ខណៈតិចតួចបំផុតចំពោះគាត់ ហើយម្ចាស់បណ្ដឹង -- ព្រោះម្ចាស់បណ្ដឹងសាទុក្ខទទួលបាននូវទស្សនាវដ្ដីទង់បដិវត្ត ហើយគឺវាផ្ទុយទាំងស្រុងពីអ្វីដែលបានបញ្ជាក់ក្នុងនាមគាត់ដែលមានតួនាទីខ្ពស់បំផុត ហើយនិងការចូលរួមរបស់គាត់នៅក្នុងគោលបំណងរួមនោះ។ អង្គហេតុដែលថា អង្គជំនុំជម្រះបានសម្រេចថា ទស្សនាវដ្ដីទង់បដិវត្តមិនគ្រាន់តែបោះពុម្ពផ្សព្វផ្សាយទេ ប៉ុន្តែវាបានចែកទៅតាមក្រសួង មន្ទីររបស់មជ្ឈិមបក្ស ហើយក៏បាន -- ហើយៗសមាជិកគណៈអចិន្ត្រៃយ៍ក៏ចូលរួមក្នុងការសរសេរ។ អ៊ីចឹងវាប្រាកដណាស់ថា ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខមិនអាចជឿជាក់បានទេ។ ភស្តុតាងគឺបង្ហាញច្បាស់ថា ម្ចាស់បណ្ដឹងសាទុក្ខត្រូវបានតម្រូវឱ្យរក្សាការសម្ងាត់ មិនមែនគេមិនឱ្យគាត់ដឹងនោះទេ គាត់ត្រូវរក្សាកាសម្ងាត់ទៅវិញ។

ឥឡូវនេះ ខ្ញុំនឹងនិយាយពីមូលដ្ឋានរបស់ម្ចាស់បណ្ដឹងសាទុក្ខចោទប្រកាន់ពីកំហុសឆ្គងក្នុងការ

សម្រេចថាគាត់មានចេតនាចូលរួមនៅក្នុងគោលនយោបាយខ្មាំង ដែលវាពាក់ព័ន្ធទៅដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មផងដែរ។ ទឡ្ហីករណ៍របស់គាត់បរាជ័យទាំងស្រុង ដោយសារគាត់មិនបានគិតអំពីភស្តុតាងជារួម ក្នុងការសម្រេចអំពីចេតនារបស់គាត់ក្នុងប្រព្រឹត្តឧក្រិដ្ឋកម្ម។ អង្គជំនុំជម្រះសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខចូលរួមទៅដល់ការបោសសម្អាតនៅទូទាំងប្រទេស ដែលទាក់ទងដោយផ្ទាល់ទៅនឹងការប្រតិបត្តិមន្ទីរសន្តិសុខ ដោយគាត់គាំទ្រជាសាធារណៈទៅលើការស្វែងរកអត្តសញ្ញាណខ្មាំង ដោយព្រមានថា ជនក្បត់នឹងត្រូវគេសម្លាប់។ ឧទាហរណ៍ នៅថ្ងៃ១៥ មេសា ៧៧ នៅពេលដែលគាត់អំពាវនាវឲ្យមានការបោសសម្អាតទាំងស្រុង និងឲ្យស្អាតទៅលើខ្មាំង គាត់ក៏បានជំរុញឲ្យកម្មាភិបាលប្រកាន់នូវស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់នៅគ្រប់ពេលទៅលើខ្មាំងគ្រប់កន្លែង ទាំងនៅក្នុងស្រុក និងក្រៅស្រុក។ ទោះបីជាខ្មាំងផ្ទៃក្នុង ឬក៏ខ្មាំងខាងក្រៅក៏ដោយ។

[១១:៣១:៣០]

នៅថ្ងៃ១៥ មេសា ៧៨ គាត់បានអបអរសាទរទៅដល់ជ័យជម្នះជាបន្តបន្ទាប់ទៅលើខ្មាំង ហើយអំពាវនាវឲ្យអ្នកដែលចូលរួមរក្សាឯកភាពជាតិ ដើម្បីបោសសម្អាតខ្មាំងនៅគ្រប់រូបភាព។ នៅពេល -- ទោះបីថាការអំពាវនាវឲ្យសម្លាប់ខ្មាំងហ្នឹងក៏ដោយ ក៏អង្គជំនុំជម្រះបានរកឃើញថា គាត់ដឹងអំពីការបោសសម្អាតកម្រិតខ្ពស់ និងកម្រិតទាបទៅលើជនក្បត់។ ពួកគេរកឃើញថា គាត់គាំទ្រឲ្យមានការដឹងឮច្បាស់លាស់អំពីកាលៈទេសៈនៃការចាប់ខ្លួនមេដឹកនាំជាន់ខ្ពស់ដែលជាមិត្តភក្តិរបស់គាត់ ដោយសារតែគាត់មានតួនាទីជាអាទិភាព ឬក៏តួនាទីអភ័យឯកសិទ្ធិខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ក៏បានដឹងអំពីការបោសសម្អាតដែលកើតឡើងនៅកម្រិតទាប ដែលជាលទ្ធ-ផលនៃការចាប់ខ្លួនទ្រង់ទ្រាយធំទៅលើប្រជាជននៅតាមមូលដ្ឋាន ហើយបានរកឃើញដោយសារតែមានការទាក់ទងជាមួយខ្មាំង។

ច្បាស់ណាស់ថាអង្គជំនុំជម្រះបានផ្អែកទៅលើភស្តុតាង ហើយបានបង្ហាញថាគាត់ដឹងយ៉ាងច្បាស់អំពីការសម្លាប់ខ្មាំង ហើយគាត់ជំរុញឲ្យមានការសម្លាប់ខ្មាំង ហើយគាត់ដឹងថា មានអនុវត្តគោលនយោ-បាយទាំងអស់នេះ។ ឧទាហរណ៍នៃការដឹងមួយរបស់គាត់ អំពីការសម្លាប់ជនក្បត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមានការទទួលស្គាល់ជាច្រើននៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍ដូចជានៅក្នុងខែ៨ ១៩៨០ គាត់បានប្រាប់ ស្ទីវ ហេដឌ័រ ថា ភ្នាក់ងារយួនទាំងអស់ត្រូវតែដោះស្រាយ ហើយគ្មានខ្មាំងភ្នាក់ងារយួនណាម្នាក់មិនដែរ មិនមានកំហុសនោះទេ។ នៅឆ្នាំ៨៧ ក្នុងនាមជាអនុប្រធានាធិបតី

នៃបក្ស -- នៃកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេស ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ថាមានការសម្លាប់ភ្នាក់ងារវៀតណាម ១០.០០០នាក់ដែលជាការ -- ដែលរំលោភទៅលើគោលនយោបាយរបស់រដ្ឋ ហើយនិងមានការ -- អ្នករៀបចំរដ្ឋប្រហារចំនួនប្រាំមួយក្រុម ដែលមានគ្នាប្រហែលជា ៨.០០០នាក់។ ហើយពួកគេត្រូវបានឃុំឃាំង ហើយបានបញ្ជាក់ថាអ្នកប្រព្រឹត្តៗល្មើសតូចតាច ឬក៏ជនស៊ីវិលប្រហែលជា ៣.០០០នាក់បានស្លាប់ ដោយសារតែគេប្រព្រឹត្តខុស។

[១១:៣៤:១៤]

ទទ្ទឹករណ៍ដែលថាគាត់មិនទទួលខុសត្រូវទៅលើការបោសសម្អាតទ្រង់ទ្រាយធំនៅមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ព្រោះគាត់បានបញ្ជាក់ថា គាត់មិនបានដឹងអំពីហេតុការណ៍ជាក់លាក់នៃឧក្រិដ្ឋកម្មដែលបានកើតឡើង គឺអត់មានភាពពាក់ព័ន្ធឡើយ។ ច្បាប់មិនតម្រូវឲ្យមានការកម្រិតនៃការដឹងឮដ៏ជាក់លាក់នោះទេ។ ដូចដែលម្ចាស់បណ្តឹងសា -- ដោយសារតែម្ចាស់បណ្តឹងសាទុក្ខមានចេតនាឲ្យមានការកាប់សម្លាប់ ដូចដែលឃើញនៅក្នុងជំរុញ និងការគាំទ្ររបស់គាត់ហ្នឹង គាត់មិនចាំបាច់ដឹងថា មិនបាច់ដឹងឲ្យច្បាស់លាស់ថាគេប្រព្រឹត្តនៅទីណានោះទេ។ ប៉ុន្តែដូចដែលអង្គជំនុំជម្រះបានសម្រេចអ៊ីចឹង គាត់ដឹងអំពីការបោសសម្អាតបុគ្គលដែលមានកម្រិតខ្ពស់ គាត់ដឹងអំពីការចាប់ខ្លួន និងការសម្លាប់ជាទ្រង់ទ្រាយធំ ហើយគាត់ដឹងអំពីអាទិភាព និងប្រតិបត្តិការនៃមន្ទីរសន្តិសុខដែលត្រូវបានចោទប្រកាន់ជាក់លាក់ ដូចជា ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល។ គាត់ដឹង ដោយផ្អែកទៅលើប្រភពជាច្រើន។ ឧទាហរណ៍ចំពោះមន្ទីរស-២១ វិញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីស-២១ ដោយសារតែតួនាទីរបស់គាត់នៅក្នុងបក្ស ជាផ្នែកមួយនៃក្រុមដែលក្រុមមេដឹកនាំដែលទទួលបានការជូនដំណឹងច្បាស់លាស់។ ម្ចាស់បណ្តឹងសាទុក្ខបានជួប ឌុច ហើយបង្គាប់ ឌុច ថាបុគ្គលិកស-២១ ត្រូវបន្តធ្វើការជាធម្មតា ទោះបីជាមានការវាយចូលរបស់វៀតណាមទៅលើដីកម្ពុជាប្រជាធិបតេយ្យក្តី។

[១១:៣៥:៥៣]

អង្គជំនុំជម្រះសាលាដំបូងក៏បានកំណត់ផងដែរថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដែលគេធ្វើឡើងទៅលើអ្នកទោសជនជាតិវៀតណាមនៅទីនោះ។ ហើយចំពោះក្រាំងតាចាន់វិញ សាលាដំបូងបានរកឃើញថា របាយការណ៍អំពីការស្លាប់ត្រូវបានបញ្ជូនឡើងទៅលើថ្នាក់លើទៅដល់ -- ទៅដល់បក្ស។ គឺថាស្រុកត្រាំកក់ ដែលជាទីតាំងរបស់ក្រាំងតាចាន់ទទួលបាននូវពានរង្វាន់

ទង់ក្រហមកិត្តិយស ថាជាស្រុកគំរូផងដែរ។ ហើយម្ចាស់បណ្ដឹងសាទុក្ខប្រហែលជាបានទៅដល់ ទៅទស្សនកិច្ចនៅស្រុកនេះជាមួយ តាម៉ុក ផងដែរ ដែលគេដឹងច្បាស់ថា តាម៉ុក បានទៅទស្សនកិច្ចនៅក្រាំងតាចាន់ ហើយជំរុញឲ្យមានប្រតិបត្តិការ។

ចំពោះអូរកន្សែងវិញ សាលាដំបូងបានរកឃើញថា របាយការណ៍ទាក់ទងទៅនឹងការបោសសម្អាតផ្ទៃក្នុងនៅទូទាំងភូមិភាគ និងនៅក្នុងកងពល៨០១ ត្រូវបានបញ្ជូនដោយផ្ទាល់ទៅមជ្ឈិមបក្ស។

ចំណែកភ្នំក្រោលវិញ សាលាដំបូងសម្រេចថា មន្ទីរសន្តិសុខភ្នំក្រោល គឺដំណើរការដោយស្ថិតក្រោមការគ្រប់គ្រងរបស់តំបន់ ដែលរាយការណ៍ផ្ទាល់ទៅមជ្ឈិមបក្ស គឺទៅមន្ទីរ៨៧០ ដែលម្ចាស់បណ្ដឹងសាទុក្ខជាសមាជិកផងដែរ។ បន្ថែមលើនេះទៅទៀត គឺមានសង្ខឹកម្មជាច្រើនដែលថា តំបន់មិនមានសិទ្ធិក្នុងសម្រេចទៅលើការប្រព្រឹត្តទៅលើខ្មាំង ឬក៏មានការបញ្ជាណាមួយនោះឡើយ គឺត្រូវតែមកពីមជ្ឈិម។

[១១:៣៧:៣២]

ទឡ្ហីករណ៍របស់គាត់ដែលថាសាលាដំបូងបង្ហាញដោយខុសឆ្គងនូវពាក្យសម្ដីរបស់គាត់ នៅពេលដែលគាត់ជំរុញឲ្យកម្មាភិបាលកំណត់អត្តសញ្ញាណ ជំរុញឲ្យមានការស្អប់ទៅលើខ្មាំងនោះ គឺមិនមានការគាំទ្រ ហើយមិនបានគិតទៅដល់ការដែលគាត់បានជំរុញឲ្យសម្លាប់ខ្មាំង និងការប្រជុំ ព្រមទាំងការធ្វើសន្និសីទនានា។ ទឡ្ហីករណ៍របស់គាត់គឺថាការដឹងឮរបស់គាត់ហ្នឹង គឺគួរតែលុបចោល ដោយសារតែគាត់ -- ដោយសារតែគេអត់ចោទប្រកាន់គាត់ពីការដឹងឮអីទាំងអស់នោះទេ គឺមិនត្រឹមត្រូវនោះឡើយ។

ជាចុងក្រោយ ទឡ្ហីករណ៍របស់គាត់ដែលថាការសម្ភាសក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចប្រើប្រាស់ដើម្បីបង្ហាញអំពីការដឹងឮ និងចេតនានោះឡើយ គឺការអះអាងនេះគឺគ្មានមូលដ្ឋានផ្លូវច្បាប់នោះឡើយ។ ការពិតណាស់ គឺយើងត្រូវតែប្រុងប្រយ័ត្ននៅពេលដែលយើងប្រើប្រាស់ការទទួលស្គាល់ដើម្បីជួយក្នុងការបង្ហាញអំពីឧក្រិដ្ឋកម្ម ប៉ុន្តែការអះអាងដែលថាការទទួលយក គឺជាការត្រឹមត្រូវមួយ។

[១១:៣៨:៤០]

គាត់មិនអាចពន្យល់អំពីការទទួលស្គាល់ទាំងអស់របស់គាត់ចាប់ពីឆ្នាំ១៩៨០ កន្លង រហូតមកនៅក្នុងកំណត់ហេតុស្ដាប់ នៅក្នុងការសម្ភាសជាលាយលក្ខណ៍អក្សរ ដែលបានកត់ត្រាជាលាយលក្ខណ៍អក្សរក្ដី ជាវីដេអូក្ដី ដែលថាហេតុអីបានគាត់ដឹងនោះ។ និយាយឲ្យខ្លីទៅគឺម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញអំពីកំហុសឆ្គងណាមួយដែលបង្ហាញ -- ដែលៗអង្គជំនុំជម្រះបានធ្វើឡើយក្នុងការសម្រេចថាគាត់

មានចេតនាជំរុញឲ្យមានការសម្លាប់ខ្លាំងជាក់ស្ដែង ឬខ្មាំងតាមការសន្មតរបស់បក្សកុម្មុយនីស្ដកម្ពុជា។ ចំពោះមូលដ្ឋាន ដែលថាកំហុស -- សាលាដំបូងមានកំហុសឆ្គងក្នុងការសម្រេចថាគាត់ចូលរួមនៅក្នុងដំណើរការនៅក្នុងគោលនយោបាយការដ្ឋានសហករណ៍ហ្នឹង គឺគាត់មិនបានបង្ហាញនោះដែរ។

អង្គជំនុំជម្រះបានយល់ឃើញថា ម្ចាស់បណ្ដឹងសាទុក្ខរក្សា នៅតែបន្តគាំទ្រចំពោះគោលនយោបាយនេះ ដោយទី១ ជំរុញឲ្យមានគោលនយោបាយតាមរយៈការផ្សះផ្សារជាសាធារណៈ នៅពេលដែលចុះទៅពិនិត្យទៅលើកូតា ហើយនិងការនាំចេញស្រូវ ទី២ គ្រប់គ្រងទៅលើនយោបាយ ទី៣ បានដឹងអំពីស្ថានភាពរស់នៅ និងស្ថានភាពធ្វើការដ៏អាក្រក់នៅសហករណ៍ និងការដ្ឋាន។ ទី៤ គាត់បានដឹងហើយគាត់គាំទ្រ និងជំរុញទៅដល់ការរើសអើង ហើយនិងការស្វែងរកខ្មាំងនៅការដ្ឋាន និងសហករណ៍ និងទី៥ ទោះបីដឹងទាំងអស់ក៏ដោយ គាត់នៅបន្តក្នុងការគាំទ្រថាបន្តគោលនយោបាយហ្នឹងក្នុងកម្រិតមួយដែលមិនមានភាពស្ទាក់ស្ទើរ ដោយសារតែគាត់ពេញចិត្តក្នុងការជំរុញ ដើម្បីសម្រេចគោលនយោបាយដែលគ្មានភាពពិតប្រាកដអីទាំងអស់របស់បក្សកុម្មុយនីស្ដកម្ពុជា។

[១១:៤០:២៩]

ចំពោះការដែលថាគាត់អត់ដឹងអំពីហេតុការណ៍ជាក់លាក់ណាមួយនៃឧក្រិដ្ឋកម្ម ឬទីតាំងដូចដែលបានពិភាក្សាខាងលើអ៊ីចឹង គឺអត់ចាំបាច់ត្រូវមានការដឹងឮទាំងអស់នេះទេ។ ប៉ុន្តែអង្គជំនុំជម្រះបានរកឃើញថាគាត់បានដឹងអំពីការដ្ឋាន និងសហករណ៍ជាក់លាក់មួយ ដូចជា សហករណ៍ត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ ការ -- ទឡ្ហីករណ៍ដែលថា ការប្តូរប្រជាជនឲ្យទៅជាវណ្ណៈ កម្មករ កសិករ មិនបង្ហាញចេតនានោះ គឺខុសទាំងស្រុង។ ដូចដែលភស្តុតាងបានបង្ហាញអ៊ីចឹង គឺថាបក្សកុម្មុយនីស្ដកម្ពុជាជំរុញប្រជាជនឲ្យធ្វើការនៅតាមការដ្ឋានធ្វើការ បង្ខំឲ្យពួកគេធ្វើ និងមិនឲ្យពួកគេចាកចេញពីការដ្ឋាន។ នេះគឺជាកត្តាបង្ហាញជាគន្លឹះនៃឧក្រិដ្ឋកម្មនៃការដាក់ឲ្យទៅជាទាសករ។

ទឡ្ហីករណ៍របស់គាត់ដែលថាគាត់អត់ដឹងពីស្ថានភាពរស់នៅ និងស្ថានភាពធ្វើការដ៏អាក្រក់នៅតាមនោះ គឺមិនអាចកំណត់បានទេ ដោយសារអង្គជំនុំជម្រះសាលាដំបូងរកឃើញថាមេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាបានទទួលរបាយការណ៍ជាច្រើនអំពីការខ្វះខាតអាហារ និងជំងឺដង្កាត់នៅតាមការដ្ឋាន។ ពួកគេរកឃើញថាវាមានរបបរាយការណ៍ពីក្រោមទៅលើរបស់បក្សកុម្មុយនីស្ដកម្ពុជារួមមួយ និងភស្តុតាងរបស់គណៈតំបន់ ការចុះទៅតាមទីតាំងជាច្រើន ការដឹងឮជាក់ស្តែងរបស់គាត់អំពីពលកម្ម មធ្យោបាយ

ដែលធ្វើក្នុងការកែសម្រួល។ ហើយនេះគឺអ្វីម្ចាស់បណ្តឹងសាទុក្ខបានលើកខ្លួនឯង។ ហើយនិងរបាយការណ៍ជាដើម គឺមិន -- និងសេចក្តីថ្លែងការណ៍ជាដើម គឺមិនអាចធ្វើយ៉ាងណាឲ្យគេមើលឃើញថាគាត់អត់ដឹងអំពីស្ថានភាពអាក្រក់ទាំងអស់នេះទេ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ គាត់ -- ទោះបីគាត់ដឹងពីស្ថានភាពអាក្រក់យ៉ាងម៉េចក៏ដោយ ក៏នៅជំរុញកម្មករឲ្យធ្វើការដើម្បីសម្រេចនូវបដិវត្តន៍ឆាប់រហ័ស។ ចំពោះទឡ្ហីករណ៍ដែលថាគាត់មិនបានដឹងអំពីការប្រព្រឹត្តមិនស្មើភាពគ្នាទៅលើប្រជាជនថ្មី គឺវាអត់ត្រឹមត្រូវទេ។

អង្គជំនុំជម្រះ មិនត្រឹមតែពឹងផ្អែកទៅលើសៀវភៅរបស់គាត់ដែលម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់នោះទេ ប៉ុន្តែគេពឹងផ្អែកផងដែរទៅលើភស្តុតាងអំពីការដឹងឮរបស់គាត់ទៅការប្រព្រឹត្តមិនត្រឹមត្រូវ។ ភស្តុតាងទាំងអស់នោះមាននៅក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលថាម្ចាស់បណ្តឹងសាទុក្ខជំរុញកម្មាភិបាលឲ្យផ្តល់ការងារច្រើន និងអាហារតិចទៅដល់ប្រជាជនថ្មី។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញពីកំហុសឆ្គងសាលាដំបូងដែលថា គាត់មានចេតនាដាក់ប្រជាជនឲ្យទៅជាទាសករនៅក្នុងស្ថានភាពការងារនិងរស់នៅអមនុស្សធម៌ ដោយសារតែប្រជាជនទាំងអស់នោះត្រូវបានគេកំណត់អត្តសញ្ញាណ និងជាគោលដៅនៃការធ្វើទុក្ខម្នេញនៅការដ្ឋាននោះ។

[១១:៤៣:១៧]

ឥឡូវនេះខ្ញុំនឹងនិយាយអំពីមូលដ្ឋានចុងក្រោយរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា សាលាដំបូងមានកំហុសឆ្គងអង្គហេតុក្នុងការសម្រេចថា គាត់មានចេតនាជំរុញឲ្យមានឧក្រិដ្ឋកម្ម រៀបការដោយបង្ខំនិងការរំលោភផ្លូវភេទ។ ការចោទប្រកាន់របស់ពួកគាត់មិនត្រឹមត្រូវទេ ដោយសារគាត់មិនបានគិតទៅលើភស្តុតាងជារួមដែលសាលាដំបូងបានប្រើប្រាស់។ ផ្អែកទៅលើភស្តុតាងអង្គជំនុំជម្រះរកឃើញថាម្ចាស់បណ្តឹងសាទុក្ខមានចេតនាចូលរួមនៅក្នុងគោលនយោបាយ មានចេតនាបង្ខំប្រជាជនឲ្យរៀបការនិងផ្សំដំណេកដោយបង្ខំ។ ទី១ ដោយចេញបញ្ជាទៅដល់ក្រសួងស្ថាប័នទាំងអស់ឲ្យរៀបចំអាពាហ៍-ពិពាហ៍។ ទី២ បានដឹងអំពីកូតាអប្បបរមាសម្រាប់ការរៀបការដោយបង្ខំនៅក្រសួងពាណិជ្ជកម្មដែលគាត់គ្រប់គ្រងទាំងស្រុង។ ទី៣ គឺជំរុញតាមរយៈសុន្ទរកថា អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តក្នុងការបង្កើនដោយឆាប់រហ័សនូវចំនួនប្រជាជន។ និងទី៤ ជំរុញឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាគិតទៅដល់ប្រយោជន៍របស់បដិវត្តន៍ កុំឲ្យគិតទៅលើប្រយោជន៍ផ្ទាល់ខ្លួននិងគ្រួសារ។ និងទី៣ គាត់ទទួលស្គាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា ស្ត្រីក្មេងៗត្រូវបានបង្ខំឲ្យរៀបការជាមួយទាហាន

ពិការ។ នៅក្នុងបរិយាកាសដែលមានការបង្ខិតបង្ខំយ៉ាងធ្ងន់ធ្ងរហ្នឹង ដែលប្រជាជនគាត់ខ្លាចផលវិបាកនៃការមិនគោរពគោលនយោបាយរបស់ -- ប្រាកដណាស់ថាគឺអង្គជំនុំជម្រះអាចសម្រេចដោយត្រឹមត្រូវថាម្ចាស់បណ្តឹងសាទុក្ខបានដឹងថា ការណែនាំនិងការជំរុញឲ្យការរៀបការរបស់គាត់ហ្នឹងនឹងកើតឡើងដើម្បីឲ្យប្រជាជនបង្កើនចំនួនកាន់តែច្រើន។ ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់ថាការសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដោយថាគាត់ជំរុញឲ្យមានការផ្សំដំណេកដោយបង្ខំហ្នឹង គឺជារឿងមិនសមស្រប។

ឥឡូវនេះ គឺថាសរុបជារួមមក ម្ចាស់បណ្តឹងសាទុក្ខមិនអាចបង្ហាញដែលថាមូលដ្ឋានហ្នឹងគឺជារឿងខុសឆ្គងនៅក្នុង -- ដោយផ្អែកទៅលើមូលដ្ឋានកម្ពុជាប្រជាធិបតេយ្យ និងទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្ត។

ឥឡូវនេះខ្ញុំនឹងប្រគល់វេទិការជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ។

សូមអរគុណឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម។

[១១:៤៦:០៥]

**លោកស្រី ប្រេនដា ហូលិស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម!

មុននឹងខ្ញុំពិភាក្សាទៅលើចំណុចដទៃទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ ខ្ញុំសុំលើកឡើងសង្ខេបឆ្លើយទៅនឹងសំណួររបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងភស្តុតាងដោះបន្ទុក ដែលជាផ្នែកមួយរបស់អង្គជំនុំជម្រះសាលាដំបូង។ យើងពិនិត្យមើលទៅភស្តុតាងនៅមុខសាលាដំបូង ដែលថាការចោទប្រកាន់នេះ មិនត្រូវបានរកឃើញនៅត្រង់ចំណុចណាមួយនោះទេ។ នៅកថាខណ្ឌ ១១៣០ ដល់ ១១៣៦ និង ១១៣៧ សាលាដំបូងបដិសេធភស្តុតាងអំពីម្ចាស់បណ្តឹងបានទៅពិនិត្យមើលទីតាំងដាក់លាក់ជាមួយដែលបង្ហាញភស្តុតាងមិនអាចជឿជាក់បាននោះទេ។ ក្រៅអ្វីដែលលើកឡើងអំពីទីតាំងភូមិសាស្ត្រទាក់ទងនឹងមន្ទីរ៨៧០ ដែលធ្វើការចាប់ខ្លួនកម្មាភិបាល គឺអង្គជំនុំជម្រះសាលាដំបូងរកឃើញភស្តុតាងទាំងដែលថា ម្ចាស់បណ្តឹងសាទុក្ខគឺថាបានស្នងតំណែងជាប្រមុខរដ្ឋ ហើយក៏បានរកឃើញថាភស្តុតាងទាំងអស់នេះ -- គឺបានរកឃើញភស្តុតាងមិនគ្រប់គ្រាន់ថា មិនអាចរកឃើញភស្តុតាងដែលថាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាមទេ។ ហើយពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម និងការជួយនិងជ្រោមជ្រែង ពិតជាបានរកឃើញ ពីព្រោះភស្តុតាងដែលរកឃើញគឺមានការពួកគាត់ -- គ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលរកឃើញថាគាត់មានពិរុទ្ធភាពដោយសំអាងទៅលើសហឧក្រិដ្ឋកម្ម

រួម។ ដូច្នេះ អង្គជំនុំជម្រះក៏បានពិនិត្យមើលទម្រង់នៃការទទួលខុសត្រូវដទៃទៀត ហើយរកឃើញភស្តុតាងថា គាត់ពិតជាមានពិរុទ្ធភាពក្នុងការជួយ និងជួយជ្រោមជ្រែងឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនេះឡើង។

[១១:៤៨:១៩]

លោកប្រធានអង្គជំនុំជម្រះជាទីគោរព! ឥឡូវនេះ ខ្ញុំលើកឡើងចំណុចបីពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវតួនាទីរបស់គាត់ គឺតួនាទី របស់មុខងារ និងការជាប់ទាក់ទងជិតដិតជាមួយថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យដទៃទៀត។ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលគាត់ត្រូវបានផ្តន្ទាទោសអនុលោមទៅតាមសហឧក្រិដ្ឋកម្មរួម ហើយនិងការទទួលខុសត្រូវរបស់គាត់សម្រាប់ការជួយនិងជ្រោមជ្រែងក្នុងទីតាំងឧក្រិដ្ឋកម្មមួយចំនួន។ ជាពិសេសទៅលើចម្លើយ -- សារណាតបដែលពន្យល់ថាហេតុអ្វីបានជាបណ្តឹងសាទុក្ខខកខានមិនបានបង្ហាញការជំទាស់ការតវ៉ារបស់គាត់ ចំពោះវិភាគ និងការរកឃើញទាក់ទងទៅនឹងចំណុចចំនួនបីរបស់អង្គ -- របស់សាលាដំបូង។ ឧទាហរណ៍ ខ្ញុំបានប្រើប្រាស់សារណារបស់ខ្ញុំ ឧទាហរណ៍ដែលខ្ញុំបានប្រើប្រាស់នោះ គឺវាពាក់ព័ន្ធដូចគ្នាទៅនឹងចំណុចទាំងបីនេះ។ ផ្ទុយនឹងការលើករបស់គាត់ម្ចាស់បណ្តឹងសាទុក្ខ តួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខ និងមុខងារ គឺការជាប់ទាក់ទងជិតដិតជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ដូចជា ប៉ុល ពត, នួន ជា គឺបានឆ្លុះបញ្ចាំងអំពីឯកសិទ្ធិ និងថ្នាក់ដឹកនាំជាន់ខ្ពស់ប្រកបដោយឯកសិទ្ធិ និងជឿទុកចិត្តនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងបានផ្តល់អំណាចទៅឲ្យគាត់ ហើយគាត់គឺថាបាន -- ដើម្បីចូលរួមប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម ដើម្បីជួយជ្រោមជ្រែងនិងជំរុញឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនេះឡើង។ ហេតុដូច្នេះហើយ ខ្ញុំនឹងផ្តោតទៅលើមូលដ្ឋានខ្លះៗអំពីវិធីសាស្ត្ររបស់គាត់ដែលខកខានមិនបានបង្ហាញកំហុសអង្គហេតុ ឬអង្គច្បាប់ណាមួយទាក់ទងទៅនឹងចំណុចនេះ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ។

[១១:៥០:00]

ផ្នែក៨(ខ) នៅក្នុងកថាខណ្ឌ៨៨៦ ដល់៩៥២ នៃសារណាតបរបស់យើងខ្ញុំ ម្ចាស់បណ្តឹងសាទុក្ខនេះគឺមិនអាចជំទាស់តវ៉ាប្រកបទៅដោយហេតុផលអំពីតួនាទីរបស់គាត់មក មុខងារ និងការជាប់ពាក់ព័ន្ធជិតដិតរបស់គាត់។ ផ្ទុយទៅវិញ គាត់ព្យាយាមកាត់បន្ថយសារៈសំខាន់នេះ។ គាត់ជំទាស់តវ៉ាដោយខ្លួនឯង។ ខ្ញុំនឹងលើកឡើងពីសៀវភៅរបស់គាត់គឺE3/18 ដែលនឹងជាមួយនឹងរបាយការណ៍សហចៅក្រមស៊ើបអង្កេត គឺ E3/27 E3/37 និង E3/557 ហើយនិងសក្ខីកម្មនៅក្នុងតុលាការនេះ E3/193.1។ សារណាតបរបស់គាត់នៅក្នុងកថាខណ្ឌ១៧១០ ហើយនិងកិច្ចសម្ភាសន៍នៅក្រៅតុលាការរបស់គាត់មាន

E3/108, E3/3198 និង E34។ ដូច្នេះ សុំលើកពិចារណាទៅលើការទទួលស្គាល់ខ្លះទាក់ទងទៅនឹងតួនាទី មុខងារ និងការជាប់ទាក់ទងជិតដិតរបស់គាត់។ ឧទាហរណ៍ គាត់ទទួលថា គាត់ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សតាំងពីឆ្នាំ១៩៧១ និងសមាជិកពេញសិទ្ធិពីឆ្នាំ១៩៧៦។ ហើយគាត់បានចេញសេចក្តីណែនាំមួយចំនួន។ គាត់បានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដែលដាក់ចេញនូវគោលនយោបាយដែលគាត់ធ្វើការណែនាំ ដូចអង្គសាលាដំបូងបានរកឃើញ គឺមានរបាយការណ៍ស្តីអំពីការអនុវត្តហ្នឹង គឺត្រូវបានគណៈអចិន្ត្រៃយ៍នេះទទួលយកមក។

[១១:៥២:០៣]

តាមពិតយើងមានកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ចំនួន៣៨ ដែលអង្គជំនុំជម្រះរកឃើញ។ ក្នុងនោះកំណត់ហេតុ២២នេះ គឺថាគាត់បានចូលរួមចំនួន១៦លើក។ គាត់ចូលរួមញឹកញាប់ជាង ប៉ុល ពត និងនួន ជា ទៅទៀត។ មិនមានហេតុផលស្តីអំពីការចូលរួមប្រជុំជាញឹកញាប់ ការចូលរួមប្រជុំរបស់គាត់ដទៃទៀតមិនត្រូវបានកត់ត្រាទេ។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា គាត់បានចូលរួមនេះ។ អ៊ីចឹងគាត់ទទួលបានព័ត៌មានក្នុងឋានៈគាត់ជាប្រមុខរដ្ឋ ហើយគាត់មានការពិភាក្សាគ្នាជាមួយនឹងអ្នកការទូតដទៃទៀត។ នេះបញ្ជាក់នូវការពិតអំពីការចូលរួមកិច្ចប្រជុំក្នុង ដោយសារតែស្ថាប័ននេះគឺជាស្ថាប័នដែលដាក់ចេញនូវគោលនយោបាយ។ ដូច្នេះ វាសមហេតុផលណាស់ដែលអាចសន្និដ្ឋានបានថា ម្ចាស់បណ្តឹងសាទុក្ខបាន -- ជាអ្នកដែលចូលរួមបានជាញឹក -- យ៉ាងញឹកញាប់នៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ការប្រជុំដទៃទៀតនេះ គឺបានបង្ហាញឲ្យឃើញថា គាត់មានឋានៈមួយគួរឲ្យទុកចិត្តក្នុងឋានៈជាថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលអ្នកដទៃទៀតនេះ គឺថាចូលរួមតិចតួចណាស់។ ហើយការចូលរួមប្រជុំរបស់គាត់ក្នុងកិច្ចប្រជុំទាំងនេះ និងសមាជិកភាពក្នុងគណៈកម្មាធិការមជ្ឈិម គឺត្រូវបានពិនិត្យពាក់ព័ន្ធទៅនឹងបរិបទដទៃទៀតអំពីការដឹងឮរបស់គាត់ និងការចេញនូវ ដាក់ចេញនូវគោលនយោបាយទាក់ទងទៅនឹងគោលនយោបាយឧក្រិដ្ឋ និងការអនុវត្ត ក៏ដូចជាការអនុវត្តទៅលើថ្នាក់ដឹកនាំដទៃទៀត។ គណៈអចិន្ត្រៃយ៍បានចាត់តាំងសមាជិកគណៈ -- គណៈមជ្ឈិមបានចាត់តាំងគណៈអចិន្ត្រៃយ៍ ហើយម្ចាស់បណ្តឹងសាទុក្ខបានទទួលថា គណៈអចិន្ត្រៃយ៍បានជូនដំណឹងទៅគណៈមជ្ឈិមអំពីគោលនយោបាយនេះ អំពីការអនុវត្តដែលគណៈអចិន្ត្រៃយ៍បានពិភាក្សា។ ដូច្នេះវាគឺជាវេទិកាមួយនៃការផ្សព្វផ្សាយអំពីសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍។ វាក៏សមហេតុផលផងដែរ ដែលអាចសន្និដ្ឋានបានថា មិនមានគោលនយោបាយមួយមិនអាចអនុវត្តផ្ទុយអំពីជំហាររបស់គណៈមជ្ឈិម ហើយ

ម្ចាស់បណ្តឹងសាទុក្ខ គឺគាត់ជា -- ចូលរួមនៅក្នុងការពិភាក្សាជាមួយគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។ ហើយយ៉ាងហោចណាស់នៅកម្រិតគណៈមជ្ឈិម គាត់មានសិទ្ធិអាចនិយាយបានដែរ។ ហើយគាត់មានសិទ្ធិបោះឆ្នោត ហើយយ៉ាងហោចណាស់ គឺក៏គាត់មានសិទ្ធិអនុវត្តអំពីគោលនយោបាយទាំងអស់នេះផងដែរ។ ម្ចាស់បណ្តឹងសាទុក្ខក៏បានទទួលស្គាល់ថា ក្នុងនាមជាសមាជិកនៃមន្ទីរ៨៧០ ដែលហ្នឹងគឺថាគាត់ត្រូវបានប្រគល់ភារកិច្ចឱ្យអនុវត្តគោល -- សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ តាមដានសមាជិកណាដែល សមាជិកបក្សណាដែលសង្ស័យសម្រាប់គណៈមជ្ឈិម។ សាលាដំបូងបានរកឃើញយ៉ាងត្រឹមត្រូវថាម្ចាស់បណ្តឹងសាទុក្ខ ដូចជា តាមរយៈការស៊ើបអង្កេត ហើយក៏បានរកឃើញថាមន្ទីរ៨៧០នេះ បានបញ្ជូនព័ត៌មានទៅវិញទៅមកពាក់ព័ន្ធទៅនឹងការអនុវត្តនូវសេចក្តីសម្រេចរបស់ខ្លួន។

[១១:៥៥:២០]

បន្ទាប់ពីសហការីរបស់គាត់ ឌឿន នេះត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៧ ម្ចាស់បណ្តឹងសាទុក្ខគាត់បន្តកាន់កាប់មុខតំណែងប្រតិបត្តិការ និងទទួលរបាយការណ៍ពីកម្មាភិបាលជាន់ទាប ឧទាហរណ៍ស្តីអំពីទទួលបានរបាយការណ៍អំពីបញ្ហាសេដ្ឋកិច្ច យោធា សកម្មភាពការងារ ការខ្វះខាតម្ហូបអាហារ និងការកម្ទេចខ្មាំងផ្ទៃក្នុង។ ហើយវាក៏សមហេតុផលដែលសន្និដ្ឋានថាម្ចាស់បណ្តឹងសាទុក្ខហ្នឹងគាត់មានឯកសិទ្ធិទទួលបានរបាយការណ៍ទាំងអស់ហ្នឹង ដោយសារតែគាត់គឺជា -- គាត់ និង ឌឿន គឺជាសមាជិកសំខាន់សម្រាប់មន្ទីរនេះ។ ហើយអ៊ីចឹងហើយគាត់បានទទួលព័ត៌មាន ដើម្បីអនុញ្ញាតឱ្យគាត់ហ្នឹងអាចបន្តអនុវត្តភារកិច្ចក្នុងឋានៈជាប្រមុខរដ្ឋ និងឋានៈជាដើម្បីទាក់ទងជាមួយនឹងអ្នកការទូតដទៃទៀត។ ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ថា មន្ទីរ៨៧០ហ្នឹងទទួលខុសត្រូវ និងអនុវត្តសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងការបែងចែកផលិតផលទៅកាន់ភូមិភាគ តំបន់ និងក៏ដូចជាការនាំចូលផងដែរ។ គាត់ទទួលស្គាល់ថាគាត់ទទួលខុសត្រូវសម្រាប់ការទិញថ្នាំពេទ្យ ដើម្បីចែកចាយទៅដល់ឱ្យប្រជាជន។ ភស្តុតាងដទៃទៀតក៏បានបង្ហាញផងដែរថា គាត់មានការត្រួតពិនិត្យទៅលើសកម្មភាពពាណិជ្ជកម្មយ៉ាងច្បាស់ ឧទាហរណ៍ពាណិជ្ជកម្មពាក់ព័ន្ធ របាយការណ៍ពាក់ព័ន្ធពាណិជ្ជកម្ម គឺបានបញ្ជូនមកគាត់ ហើយគាត់បានផ្តល់មតិយោបល់ និងគោលការណ៍ណែនាំរបស់គាត់ទៅថ្នាក់ក្រោម។ ម្ចាស់បណ្តឹងសាទុក្ខក៏បានទទួលស្គាល់ផងដែរថា ការចុះ -- ទំនាក់ទំនងយ៉ាងជិតដិតជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ជាពិសេសជាមួយនឹង ប៉ុល ពត និង នួន ជា គឺបានបង្ហាញជាថ្មីអំពីអំណាចជាក់ស្តែងតែម្តងរបស់គាត់។

[១១:៥៧:១៧]

ឧទាហរណ៍ គាត់ទទួលស្គាល់ថា គាត់ -- ប៉ុល ពត បានហៅគាត់ឲ្យទៅកាន់ទីបញ្ជាការរបស់ ប៉ុល ពត ទាក់ទងទៅនឹងស្ថានភាពនៅភ្នំពេញចុងក្រោយ ហើយ ប៉ុល ពត ហ្នឹងក៏បានជួនគាត់មក ភ្នំពេញ ហើយមកទីក្រុង ដើម្បីឈានទៅដល់ការរឹបអូសយកទីក្រុងភ្នំពេញនោះ។ គាត់បានរស់នៅ និង ធ្វើការជាមួយ ប៉ុល ពត, នួន ជា និងថ្នាក់ដឹកនាំដទៃទៀតនៅទីកន្លែងជាច្រើនកន្លែង ក្រោយពីការកាន់ កាប់ទីក្រុងភ្នំពេញ ដូចជាស្ថានីយ៍អយស្ម័យយាន នៅវត្តឧណ្ណាលោម នៅក-៣, ក-១ ហើយ ក-៣ ទៀត គឺជាកន្លែងដែលមេដឹកនាំជាន់ខ្ពស់រស់នៅមាន នួន ជា។ ប៉ុល ពត គឺថាបានស្នាក់នៅក-៣ ជាញឹកញាប់ ហើយកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ហ្នឹងជួនកាលក៏ធ្វើឡើងនៅក-៣ ដែរ។ គាត់និយាយថា នៅក្នុងឆ្នាំ ៧៣ ទៅដល់៧៨ គាត់បានទាក់ទងជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលមានសិទ្ធិចូលរួមនៅក្នុង កិច្ចប្រជុំផ្ទៃក្នុងរបស់ខ្លួន។ ហើយគាត់បានចូលរួមនៅក្នុងកិច្ចប្រជុំនានា ដូចជា ជាមួយគណៈអចិន្ត្រៃយ៍ ហើយនិងការប្រជុំមួយថ្ងៃៗជាច្រើនដង នៅវិហារព្រះកែវមរកតនៅក្នុងឆ្នាំ១៩៧៥ ដើម្បីពិភាក្សាគ្នា។ ការចូលរួមរបស់គាត់នេះមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដែលគាត់បានទទួលស្គាល់ថា ចន្លោះពី៧០ ឆ្នាំ ៧០ ដល់៧៥នៀក គាត់ស្នាក់ជាអចិន្ត្រៃយ៍ជាមួយមេដឹកនាំខ្មែរក្រហម។ គាត់គឺថា ទៅតាម ប៉ុល ពត សឹងតែគ្រប់ពេល ដែលថាបន្ទាប់ពីគាត់ ប៉ុល ពត និង នួន ជា ត្រូវបានគេបម្លាស់ទីមកកាន់ទីក្រុងភ្នំពេញ ក្រោយពីហ្នឹងគឺ គឺថាគាត់មិនដែលរស់នៅបែកគ្នាទេ ហើយនិងស្គាល់គ្នាយ៉ាងច្បាស់។

[១១:៥៩:១១]

ដូច្នេះយើងឃើញថាគោលបំណងរបស់គាត់ ដើម្បីគឺថាលាបពណ៌ខ្លួនគាត់គឺថា គាត់ជាមេដឹកនាំ ដែលគ្មានអំណាច តាមរយៈការទទួលស្គាល់របស់គាត់នេះ គឺមិនយ៉ាងដូច្នោះទេ។ ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានជ្រើសរើសពីតួនាទី -- មានតួនាទីជាច្រើន និងទទួលមុខងារជាច្រើន ដោយសារតែគាត់គឺជា សមាជិកមួយដែលគេឲ្យតម្លៃ និងគួរឲ្យទុកចិត្តក្នុងចំណោមថ្នាក់ដឹកនាំកំពូលបក្សកុម្មុយនីស្តកម្ពុជា ដែល ជាស្រមោលរបស់ ប៉ុល ពត គឺជាអ្នកដែលជួយជ្រោមជ្រែងអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់បក្ស កុម្មុយនីស្តកម្ពុជា។ ហើយគឺមានរូបថតរបស់គាត់ដែរ គេព្យួរតាំងពីនៅផ្ទះ ហើយព្យួរទាំងនៅបរទេស ទៀត។ ឥឡូវនេះ ខ្ញុំសូមចូលទៅលើមូលហេតុនៃការជំទាស់តវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹង សហឧក្រិដ្ឋកម្មរួម។

ខ្ញុំសុំលើកឡើងអំពីផ្នែកទី៨(គ)(២) កថាខណ្ឌ១០៤០ ដល់ ១០៩៥ ដោយសហការីរបស់ខ្ញុំ

លោក ស្មីត បានលើកឡើងហើយ លើកឡើងអំពីច្បាប់ជាច្រើនពាក់ព័ន្ធទៅនឹងគោលបំណងរួម ហើយនិងការចូលរួមគាត់ គឺថាគាត់ត្រូវធ្វើហាក់មិនដឹងមិនឮទៅលើសហឧក្រិដ្ឋកម្មហ្នឹង។

អ៊ីចឹងគោលបំណងរួមនេះគឺជាបទឧក្រិដ្ឋនេះហើយ។ គាត់ជំទាស់តវ៉ាថា គោលបំណងរួមហ្នឹងគឺមិនមានការជាប់ពាក់ព័ន្ធអ្វីនោះទេ។ ហើយគាត់ៗលើកឡើងខុសផងដែរ នូវអ្វីដែលតម្រូវឱ្យបង្ហាញឱ្យឃើញពីការចូលរួមឱ្យបានគ្រប់គ្រាន់ដែលថា ដូចដែលគាត់បានធ្វើអ៊ីចឹង ម្ចាស់បណ្ដឹងសាទុក្ខបានចូលរួមតាមធ្យោបាយជាច្រើននៅក្នុងគោលបំណងឧក្រិដ្ឋរួម ហើយការចូលរួមរបស់គាត់នៅ ដោយផ្ទាល់ ឬដោយមិនផ្ទាល់ ជាមួយនឹងក្នុងការប្រព្រឹត្តឧក្រិដ្ឋសហឧក្រិដ្ឋកម្មរួមនេះ។ ការចូលរួមរបស់គាត់នេះគឺថាវាអាចច្រើនជាងនេះទៅទៀត ច្រើនជាងភស្តុតាងដែលបានបង្ហាញនេះទៅទៀត។ លើសពីនេះទៅទៀតចូលរួមម្ចាស់បណ្ដឹងសាទុក្ខមិនចាំបាច់ត្រូវចូលរួមពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់ណាមួយទេ ក៏ប៉ុន្តែវាមានទម្រង់ជាការចូលរួមទៅដល់ការអនុវត្តនូវគោលបំណងឧក្រិដ្ឋកម្មរួម ដូចដែលអង្គជំនុំជម្រះបានលើកឡើងហើយនៅក្នុងកថាខណ្ឌ៩៨៤ គឺគោលបំណងរួម គឺវាមានការជាប់ទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណគោលនយោបាយឧក្រិដ្ឋ ដូចជាសកម្មភាពដែលវាទាក់ទងទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលសកម្មភាពទាំងអស់នេះអាចគាំទ្រទៅដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម បើទោះបីជាដោយប្រយោលក្ដី។

[១២:០១:៥៧]

ហើយការចូលរួមរបស់គាត់យ៉ាងសំខាន់នេះ គឺដូចជាពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់ កម្រិតឋានៈរបស់គាត់ និងការ -- ហើយនិងការខិតខំប្រឹងប្រែងណាមួយផ្ទុយទៅនឹងការលើកឡើងរបស់គាត់។ ភស្តុតាងនៅក្នុងករណីបានបង្ហាញអំពីតួនាទីសំខាន់ៗ។ ភស្តុតាងក៏បានបង្ហាញយ៉ាងច្រើនដែលថាម្ចាស់បណ្ដឹងសាទុក្ខនោះមិនដែលរារាំង ឬក៏ធ្វើអន្តរាគមន៍ទៅក្នុងការប្រព្រឹត្តទេ។ តែផ្ទុយទៅវិញ គាត់បានប្រើប្រាស់អំណាចរបស់គាត់ដើម្បីដោះលែងសាច់ញាតិប្រពន្ធរបស់គាត់ សាច់ញាតិរបស់ប្រពន្ធគាត់នៅតំបន់ព្រះវិហារ។

ម្ចាស់ -- ទឡ្ហីករណ៍ម្ចាស់បណ្ដឹងសាទុក្ខនេះខកខានមិនបានបង្ហាញអំពីការចូលរួមរបស់គាត់។ គាត់មិនបានពិចារណាអំពីសកម្មភាពរួមរបស់គាត់ ដែលគាត់តម្រូវឱ្យធ្វើយ៉ាងដូច្នេះ ហើយដូចដែលអង្គជំនុំជម្រះបានរកឃើញយ៉ាងដូច្នេះឯង។ វិធីសាស្ត្ររបស់គាត់ក្នុងការធ្វើមិនដឹងមិនឮ ទៅលើការវិភាគយ៉ាងល្អិតល្អន់ទូលំទូលាយរបស់សាលាដំបូងទៅលើការចូលរួមរបស់គាត់ ជាពិសេសនៅក្នុងកថាខណ្ឌ

៤២៧ ដល់ ៨ ហើយនិងតួនាទីរបស់គាត់យ៉ាងជិតដិតជាមួយថ្នាក់ដឹកនាំនេះ។ ហើយការអះអាងរបស់ម្ចាស់បណ្ដឹង គាត់គឺជាជនរងគ្រោះដោយការចូលរួមនេះ។ សាលក្រមបានបង្ហាញយ៉ាងច្បាស់ហើយថា គាត់បានប្រព្រឹត្តដោយសំអាងទៅលើមូលហេតុនៃការរកឃើញរបស់សាលាដំបូង មិនមែនដោយសារតែទើបតែការជាប់ពាក់ព័ន្ធនេះទេ។ ការចូលរួមរបស់គាត់ត្រូវបានយកមកវាយតម្លៃរួមជាមួយនឹងអង្គហេតុដែលគាត់បានទទួលស្គាល់ថា គាត់មិនត្រូវបានចាត់ទុកជាមេដឹកនាំខ្មែរក្រហមតាំងពីឆ្នាំ តាំងរដ្ឋប្រហារ ១៩៧០ មកម៉្លេះ ហើយគាត់ជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ ហើយដូច្នេះអង្គជំនុំជម្រះដំបូងបានរកឃើញយ៉ាងត្រឹមត្រូវថានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយតាមពិតទៅដូចដែលម្ចាស់បណ្ដឹងសាទុក្ខលើកឡើងអ៊ីចឹងថា បក្សកុម្មុយនីស្តកម្ពុជាគឺជារដ្ឋហើយ។ ដូច្នេះ អំពើរបស់គាត់ត្រូវបានយល់ឃើញ ហើយជាពិសេសហ្នឹង គឺថាគាត់មានការជាប់ទាក់ទងជាមេដឹកនាំដោយផ្ទាល់ ឬដោយមិនផ្ទាល់។ អ៊ីចឹងអានេះវាលើសពីនេះ វាលើសពីតួនាទីរបស់គាត់ទៀត។ ប៉ុន្តែគាត់ធ្វើមិនដឹងមិនឮនៅស្ងៀមពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេច ហើយនិងការប្រកាសរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១២:០៤:៣៧]

ខ្ញុំសុំលើកឡើងឧទាហរណ៍មួយចំនួន ដែលមានសារៈសំខាន់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម សហឧក្រិដ្ឋកម្មរួម តាមរយៈ -- អ៊ីចឹងការជំទាស់តវ៉ារបស់គាត់ ដែលថាគាត់មិនមានធ្វើការអន្តរាគមន៍ទេ គាត់គាំទ្រទៅដល់គោលបំណងឧក្រិដ្ឋកម្មរួម ចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍យ៉ាងទៀងទាត់ និងជាសមាជិកគណៈមជ្ឈិម ដោយឧទាហរណ៍ គឺថានៅស្ងៀមធ្វើមិនដឹងមិនឮ ឬក៏គាំទ្រយ៉ាងជាវិជ្ជមានទៅដល់សេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍សម្រាប់រដ្ឋនោះ។ ឧទាហរណ៍ ពាក់ព័ន្ធទៅនឹងស្រូវដែលត្រូវ ៣០, ៥០, ១០០% ជាដើម ត្រូវគេយកជូន លក់ទៅបរទេស ប៉ុន្តែឯប្រជាជនវិញគឺថាមានភាពអត់ឃ្លាន ហើយគាត់ធ្វើការបង្ខំឲ្យប្រជាជន។ ឯនៅគណៈមជ្ឈិម សេចក្ដីសម្រេចរបស់គណៈមជ្ឈិម គឺថាបានឲ្យអំណាចទៅដល់ថ្នាក់ក្រោមដើម្បីកម្ទេច។ ឧទាហរណ៍ សម្លាប់នៅក្នុង និងក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ គាតគឺថាជាគណៈ ប្រធានគណៈ ប្រធានរដ្ឋ ដោយសារតែគាត់ជាសមាជិកជាគណៈមជ្ឈិម។ គាត់តម្រូវឲ្យគាត់ទទួលព័ត៌មានដើម្បីបំពេញតួនាទីរបស់គាត់ក្នុងឋានៈជាប្រមុខរដ្ឋ មានទំនាក់ទំនងជាមួយការទូត។ អ៊ីចឹងមានហេតុផលដែលស្រេចថាគាត់ដឹងអំពីសេចក្ដីសម្រេចទាំងអស់នេះ។ ក្នុងឋានៈជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់កម្ពុជា គាត់មានការទំនាកទំនងជិតដិតជាមួយ ប៉ុល ពត និង នួន ជា ជាពិសេសនៅជាមួយសង្គមនិយមប្រជាធិបតេយ្យនេះ គឺគាត់បាននិយាយប្រឆាំងទៅនឹង -- គាត់បាន

ចូលរួមប្រជុំជាមួយគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។

ម្ចាស់បណ្ដឹងសាទុក្ខបានៗបានលើកស្នើយ ក៏ដូចជាគាំទ្រសម្រេចទៅដល់គោលបំណងឧក្រិដ្ឋកម្ម ។ គាត់មាន ជួនកាលចូលរួមក្នុងគណៈមជ្ឈិមហ្នឹងច្រើនដងទៅទៀតនោះក្នុងថ្ងៃនីមួយៗហ្នឹង។ គាត់ចូលរួមប្រជុំជាមួយលេខាមជ្ឈិម លេខាភូមិភាគនៅព្រះកែវមរកត និងគាត់ក៏ចូលរួមក្នុងការបង្កើតនូវសហករណ៍ និងការកសាងប្រព័ន្ធធារាសាស្ត្រ។ ហើយគាត់បានជំរុញ និងបានផ្សព្វផ្សាយ និងធ្វើឱ្យគោល-ការណ៍នយោបាយរបស់នោះ គោលនយោបាយទាំងនោះស្របច្បាប់។ ឧទាហរណ៍ក្នុងឋានៈជាប្រធានរដ្ឋ ហើយគាត់ក៏មានសិទ្ធិដឹង និងទៅមើលអំពីគុកមួយចំនួន និងការលើកទំនប់ ជីកប្រឡាយផ្សេងៗដែលបង្ខំឱ្យប្រជាជនធ្វើការទាំងថ្ងៃទាំងយប់ មិនមានសម្រាកទេ។ ការគិត -- គាត់ គឺថាបង្ខំប្រជាជនឱ្យធ្វើការ បង្ខំឱ្យមានការបំពេញផែនការផលិតកម្ម ដើម្បីធ្វើម៉េចឱ្យសម្រេចបាននូវផែនការផលិតកម្មរបស់បក្សកុម្មុយនីស្ត ដូចសហការីរបស់ខ្ញុំលើកឡើង គឺថាគាត់មានភក្ដីភាពចំពោះអង្គការជាងម៉ែឪគាត់ទៅទៀត។ ហើយគាត់គឺថាញុះញង់ប្រជាជនហ្នឹងឱ្យស្អប់យួនខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ហើយធ្វើឱ្យគាត់ធ្វើការ គឺថាសម្លាប់ -- ញុះញង់ឱ្យសម្លាប់រង្គាលគ្រប់រូបភាព។

[១២:០៨:១៨]

គាត់បានណែនាំឱ្យអនុវត្តនូវគោលបំណងឧក្រិដ្ឋកម្មរួម ដោយអំពាវនាវឱ្យមានការជម្លៀសប្រជាជន ឱ្យមានការជម្លៀសជនជាតិវៀតណាមចេញពីកម្ពុជា គឺថាដោយក្រោយមកគាត់និយាយថាកម្ពុជាត្រូវតែមិនមានយួនរស់នៅទេ។ ហើយគាត់ក៏អាចមានលទ្ធភាពត្រួតពិនិត្យការអនុវត្តគោលបំណងឧក្រិដ្ឋរួមនេះតាមរយៈគោលនយោបាយទាំងនេះ ឧទាហរណ៍ និយាយអំពីការធ្វើម៉េចឱ្យមុខងាររបស់រដ្ឋបាលកម្ពុជាប្រជាធិបតេយ្យហ្នឹងក្នុងឋានៈជាសមាជិកនៃមន្ទីរ៨៧០ ដោយធានាថា ការទទួលខុសត្រូវទាក់ទងនឹងពាណិជ្ជកម្មរបស់ ឌឿន គឺថាត្រូវបានអនុវត្តក្រោយពី ឌឿន ត្រូវបានចាប់ខ្លួន ហើយធានាថាសហករណ៍នីមួយៗហ្នឹងត្រូវផលិតស្រូវ ដើម្បីអាចផលិតការនាំចេញឱ្យបានគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវគោលនយោបាយនេះ។ ពាក់ព័ន្ធទៅនឹងសកម្មភាពសរុបរបស់ជន -- ម្ចាស់បណ្ដឹងសាទុក្ខ ដូចអង្គជំនុំជម្រះសាលាដំបូងបានរកឃើញ គឺថា ម្ចាស់បណ្ដឹងសាទុក្ខនេះបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ហើយដែលមានជារឿងសំខាន់បំផុត។

[១២:០៩:៣៦]

ឥឡូវខ្ញុំសូមចូលទៅដល់មូលហេតុជំទាស់ត។របស់ម្ចាស់បណ្ដឹងសាទុក្ខ ដែលគាត់ខកខានថានៅ

ក្នុងផ្នែកទី៨(គ) នៃចម្លើយតបរបស់យើងខ្ញុំ កថាខណ្ឌ១២៤៧ ដល់ ១២៨៣ ពាក់ព័ន្ធទៅនឹងមូលដ្ឋានរបស់ម្ចាស់បណ្ដឹងសាទុក្ខ។ អ៊ីចឹងវាពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌពាក់ព័ន្ធនឹងការជំរុញ។ ទី១ ម្ចាស់បណ្ដឹងជំទាស់តវ៉ាមិនត្រឹមត្រូវទេ ថាសាលាដំបូងមានកំហុសដែលសម្រេចអំពីឧក្រិដ្ឋកម្ម ដែលថាគាត់ទំនងជាបានប្រព្រឹត្តឡើង និងជំទាស់តវ៉ាបទដ្ឋាននៃចេតនាទាក់ទងនឹងសកម្មភាពរបស់គាត់។ ការជំទាស់តវ៉ាម្ចាស់បណ្ដឹងសាទុក្ខយល់អំពីធាតុចេតនាដែលតម្រូវសម្រាប់ការជួយនិងជំរុញនេះ ហើយនិងភវនីយភាពដែលថាឧក្រិដ្ឋកម្មនេះអាចនឹងត្រូវបានប្រព្រឹត្តឡើងជាមួយនឹងការដឹងថា សកម្មភាពរបស់គាត់វាជួយនិងជំរុញទៅដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ។ ហើយការយល់ដឹងយ៉ាងត្រឹមត្រូវ នេះគឺថាវាច្បាស់ហើយដែលនាំឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេច ដែលទាំងនេះគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលម្ចាស់បណ្ដឹងសាទុក្ខធ្វើសកម្មភាពទាំងអស់នេះ។ ដូចមាននៅក្នុងចម្លើយតបរបស់យើងខ្ញុំកថាខណ្ឌ១២៦៦ និង ១២៧០។ ហើយក៏មិនមាន -- មិនបាច់តម្រូវថាឲ្យគាត់ដឹងថាឧក្រិដ្ឋកម្មជាក់លាក់ណាប្រព្រឹត្តឡើងនោះទេ គ្រាន់តែគាត់ដឹងថាសមាជិកនៃឧក្រិដ្ឋកម្មហ្នឹងបានប្រព្រឹត្តអ្វីមួយហ្នឹងវាជាហេតុផលមួយហើយ។ ការដឹងឮរបស់គាត់នោះគឺអំពីកាលៈទេសៈនៃរឿងក្ដីនេះ។ កាលៈទេសៈទាំងនេះបានពិភាក្សាលម្អិតនៅក្នុងសារណាតបជាលាយលក្ខណ៍អក្សរដែលលើកឡើងលម្អិតនៅក្នុងសារណា -- នៅក្នុងសវនាការផ្ទាល់មាត់ និងការទទួលស្គាល់របស់គាត់អំពីអំពើនៅក្នុង ដូចជាក្នុងឯកសារថា -- ខ្លួនគាត់ផ្ទាល់មិនអាចបញ្ចេញមតិប្រឆាំងទៅនឹងការលើកឡើងណាមួយទេ ហើយការដឹងឮរបស់គាត់នេះក៏បានកើតមានឡើង។

[១២:១២:០៣]

នៅក្នុងសាលក្រម កថាខណ្ឌ៤០៧, ០២ ដល់២៧ ដែលសាលាដំបូងបានលើកឡើងអំពីគោលនយោបាយដែលថា គោលនយោបាយនេះអនុវត្តតាំងពីមុនឆ្នាំ១៩៧៥ទៅទៀត ដែលម្ចាស់បណ្ដឹងសាទុក្ខបានដឹងថា បានប្រព្រឹត្តឧក្រិដ្ឋកម្មនេះតាំងពីមុន នៅក្នុងកថាខណ្ឌ -- ខ្ញុំៗសុំអធ្យាស្រ័យ អង្គជំនុំជម្រះប្រហែលជាខ្ញុំយល់ច្រឡំលើកឡើងច្រឡំហើយកថាខណ្ឌអម្បាញ់មិញនេះ។

ប្រសិនបើយើងមើលទៅលើកាលៈទេសៈទាំងអស់នៃរឿងក្ដីនេះ មានហេតុផលតែមួយទេដែលអាចសន្និដ្ឋានបាន គាត់ដឹងទាំងពីរហ្នឹង ដែលថាឧក្រិដ្ឋកម្មមួយចំនួនអាចនឹងកើតមានឡើង ហើយអំពើរបស់គាត់គឺបានចូលរួមចំណែកប្រសិនជាឧក្រិដ្ឋនោះបានកើតឡើង។ ម្ចាស់បណ្ដឹងសាទុក្ខហ្នឹងក៏យល់ច្រឡំ គាត់អត់ដឹងពីការកាប់សម្លាប់សំខាន់ៗណានោះទេ។ ដូច្នេះ ថាគាត់ៗមិនចាំបាច់ចែករំលែកអំពី

ចេតនារបស់គាត់ ស្ថានភាពផ្លូវចិត្តគាត់នោះទេ គឺការប្រព្រឹត្តរបស់ចារីឲ្យតែនាំឲ្យអ្នកណាម្នាក់ស្លាប់ហ្នឹង គឺវាជាផលវិបាកកើតឡើងចេញពីគោលនយោបាយទាំងនេះ។ ពាក់ព័ន្ធទៅនឹងធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មនេះ គាត់បានដឹងអំពីអំពើឧក្រិដ្ឋ ដែលគាត់មានចំណេះ គាត់មានការយល់ដឹង ហើយមិនមែនថាគាត់មិនដឹងអំពីភាពលម្អិតនៅក្នុងពេលវេលានោះទេ។ គាត់ក៏បានយល់ខុសចំពោះការជួយជ្រោមជ្រែង និងជំរុញពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ។ ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏បានបញ្ជាក់ថា ការចូលរួមរបស់គាត់ហ្នឹង គឺថាវាពាក់ព័ន្ធដោយផ្ទាល់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មហើយ ដោយមិនចាំបាច់បង្ហាញអំពីការដឹងឮជាក់លាក់របស់គាត់ណាមួយ ឲ្យតែមានលទ្ធភាពបញ្ជាក់ថា គាត់មានលទ្ធភាពចូលរួម *(គ្មានការបកប្រែ)*--

[១២:១៤:៥៤]

**ប្រធានអង្គជំនុំ៖**

សូមសហព្រះរាជអាជ្ញាផ្អាកបន្តិច អត់មានឮអ្នកបកប្រែទេ។

**លោក គង់ សំអុន៖**

ឯកឧត្តមប្រធាន សុំអនុញ្ញាត ដោយសារអត់ឮសំឡេងបកប្រែជាភាសាខ្មែរ

**លោកស្រី ប្រេនដា ហូលិស៖**

*(គ្មានការបកប្រែ)*

ទោះបីថាអំពើរបស់គាត់អាចចាត់ទុកថាជាការប្រព្រឹត្តក៏ដោយ ប៉ុន្តែវាមិន ច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏បានតម្រូវផងដែរឲ្យមានការចូលរួមរបស់គាត់ ជាពិសេសទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្មទោះបីថា បង្ហាញអំពីអំពើ--

**ប្រធានអង្គជំនុំ៖**

សូមផ្អាកសិន! សហព្រះរាជអាជ្ញាសូមផ្អាកសិន! សុំដូរឌីសមួយភ្លែត!

**លោកស្រី ប្រេនដា ហូលិស៖**

ទៅនឹងទឡ្ហីករណ៍របស់ព្រះរាជអាជ្ញា -- ផ្ទុយទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តី។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្ត!

[១២:១៧:៣៤]

**លោកស្រី ប្រេនដា ហូលិស៖**

សូមអរគុណឯកឧត្តមប្រធាន។ ផ្ទុយទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ការជួយនិងជំរុញតាមរយៈការជំរុញដោយផ្ទាល់ គឺមិនចាំបាច់ឲ្យមានការជំរុញទៅលើឧក្រិដ្ឋកម្មជាក់លាក់ណាមួយក៏ដោយ ប៉ុន្តែនៅពេលដែលយើងពិចារណាទៅការជំរុញជាក់លាក់ ហើយនិងការគាំទ្រជាក់លាក់របស់ពួកគាត់ទៅលើការរៀបចំផែនការ និងការអនុវត្តគោលនយោបាយទាក់ទងទៅនឹងសហករណ៍ ការដ្ឋាន និងខ្មាំង យើងត្រូវចាំថាគាត់នៅជិតជាមួយមេដឹកនាំដទៃទៀត។ ហើយគាត់ក៏ជាផ្នែកមួយនៃអ្នកធ្វើការសម្រេច ហើយក៏ជាសមាជិកនៃគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ផងដែរ ហើយនិងជាសមាជិកគណៈអចិ-ន្ត្រៃយ៍ ហើយឧទាហរណ៍ដូចជា សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងផែនការសេដ្ឋកិច្ច ផែនការផលិតផលជាដើមហ្នឹងទាំងអស់ ក៏ដូចជាការបោសសម្អាតទៅលើកម្មាភិបាលខ្មែរក្រហម។

ដូច្នេះទាំងអស់នេះគឺបង្ហាញច្បាស់ណាស់ថាគាត់អាចលើក ឬក៏បញ្ចេញមតិយោបល់របស់គាត់។ ការដែលនៅស្ងៀមរបស់គាត់ គឺបានន័យថាជាការគាំទ្រ ធ្វើឲ្យថ្នាក់ដឹកនាំដទៃទៀតគាត់ពេញចិត្តនៅក្នុងការអនុវត្តគោលនយោបាយ ហើយនិងការអនុវត្តការងារសហករណ៍ ក៏ដូចជាការងារផ្សេងៗ ហើយនិងការសម្លាប់អ្នកដែលក្បត់បក្ស ឬក៏បដិវត្តន៍។

ដើម្បីយល់ថាតើការជំរុញនិងការគាំទ្ររបស់គាត់ចំពោះក្រុមកម្មាភិបាលហ្នឹងជួយយ៉ាងសំខាន់បែបណាទៅដល់អំពើមនុស្សឃាត ឥឡូវនេះយើងទៅពិចារណាមួយសាទៀតថា ដោយសារតែតួនាទីរបស់គាត់ សំណេររបស់គាត់គឺចាត់ទុកថាជាសំឡេងរបស់បក្សកុម្មុយនីស្តកម្ពុជា គឺរបស់កម្ពុជាប្រជាធិបតេយ្យ។ ហើយវាតម្រូវឲ្យមានការយកចិត្តទុកដាក់ខ្ពស់។ ការស្ងៀមស្ងាត់របស់គាត់ទៅលើឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តឡើងក្នុងឈ្មោះរបស់គាត់ គឺវាដូចជាការដែលគាត់និយាយគាំទ្រដូច្នេះ។

ក្នុងបរិបទនេះអំពើរបស់គាត់រួមមានការប្រកាសជាសាធារណៈ ឬក៏សេចក្តីថ្លែងជាសាធារណៈ ឬក៏ការឯកភាពដោយស្ងាត់ស្ងៀមចំពោះការប្រកាសរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀត ដូចជា ប៉ុលពត, នួន ជា រួមទាំងការដែលគាត់មិនបានលើកការជំទាស់របស់គាត់ទៅលើអំពើហិង្សាដែលបានធ្វើឡើងក្នុងនាមគាត់ហ្នឹងគឺប្រាកដណាស់ជាការប្រព្រឹត្តឧក្រិដ្ឋកម្ម។

[១២:២០:២០]

ឧទាហរណ៍ខ្លះនៃការប្រកាសជាផ្លូវការរបស់គាត់នៅកិច្ចប្រជុំជាសាធារណៈរបស់កម្មករ កម្មា-ភិបាល ហើយនិងសេចក្តីថ្លែងជាសាធារណៈជួយឲ្យយើងយល់អំពីការចូលរួមរបស់គាត់ ឧទាហរណ៍

ដូចជា -- ដូចដែលសហការីខ្ញុំបានបញ្ជាក់អ៊ីចឹង គឺអំពាវនាវឲ្យប្រជាជនគិតអំពីប្រយោជន៍ជាតិ ប្រយោជន៍បដិវត្តន៍ ហើយព្យាយាមគិតទៅដល់បដិវត្តន៍ បង្គាប់ទៅដល់កម្មាភិបាលឲ្យផ្លាស់ប្តូរអាកប្ប-កិរិយា ដើម្បីបំពេញទៅតាមគោលដៅរបស់បក្ស និងកំណត់អត្តសញ្ញាណខ្មាំង។ បង្រៀនពួកគេអំពីភាពចាំបាច់ក្នុងការបំពេញតាមតម្រូវការផលិត ជំរុញឲ្យបំពេញផែនការដោយមិនគិតអំពីពលករ កម្មករ។ ប្រាប់អ្នកចូលរួមឲ្យផ្សព្វផ្សាយការប្រជុំហ្នឹងទៅមូលដ្ឋាន។

ក្នុងពេលជាមួយគ្នាហ្នឹង គាត់បានលើកសរសើរកម្មករដែលធ្វើការទាំងយប់ទាំងថ្ងៃ មិនឈប់មិនសម្រាក ដើម្បីសម្រេចគោលដៅបក្ស ជំរុញ បង្ខំឲ្យប្រជាជនដែលអត់អាហារស្រាប់ទៅហើយហ្នឹងឲ្យហូបតិចទៅៗ ដើម្បីសម្រេចតាមគោលដៅបក្ស ដើម្បីបំពេញទៅតាមគោលដៅដែលតាមគ្រប់កាលៈទេសៈ។ រហូតដល់ចុងឆ្នាំ៧៧ គាត់បន្តណែនាំកម្មាភិបាលថាគោលដៅបដិវត្តន៍គឺលុបបំបាត់សមាជិករបបលន់ នល់ ពួកសក្តិភូមិ មូលធននិយម និងបញ្ញវន្តប្រាប់កម្មាភិបាលថា ត្រូវតែកម្ទេចខ្មាំងក្បត់បក្ស។

[១២:២១:៥៩]

ប្រជាជនថ្មីដែលជាសក្តិភូមិត្រូវតែទទួលបានអាហារតិច ហើយអ្នកដែលក្បត់បក្ស និងបដិវត្តន៍ត្រូវសម្លាប់ ត្រូវតែដក ជីកស្មៅត្រូវជីកទាំងឫស។ ការប្រកាសរបស់គាត់គឺធ្វើឲ្យកម្មាភិបាលត្រូវប្រព្រឹត្តអំពើមនុស្សឃាត ហើយថាពលករត្រូវតែសម្រេចទៅតាមគោលដៅផលិតរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងកម្មាភិបាលត្រូវតែផ្លាស់ប្តូរអាកប្បកិរិយាដើម្បីធ្វើយ៉ាងណាឲ្យ កម្មករ ពលករ ធ្វើទៅតាមផែនការរបស់បក្ស។ ហើយការដែលផ្តល់អាហារកាន់តែតិច ហើយជំរុញឲ្យអ្នកឈឺហ្នឹងធ្វើការធ្ងន់ធ្ងរកាន់តែធ្ងន់ធ្ងរ ការទទួលបាបប្រជាជន ប្រជាជនថ្មី ហើយនិងអ្នកដែលគេចាត់ទុកថាជាខ្មាំងហ្នឹងក៏ជាកំហុសដែរ។

ហើយការប្រើប្រាស់ពាក្យជាដើម ដូចថា "ទុកមិនចំណេញ ដកចេញក៏មិនខាតដែរហ្នឹង" ទាំងអស់ហើយគឺ អាទាំងអស់នេះគឺវាចង់មានន័យថាធ្វើគ្រប់មធ្យោបាយទាំងអស់ ដោយមិនខ្វល់អំពីផលប៉ះពាល់អំពីការលំបាកអ្វីទាំងអស់។ អ្នកដែលមិនអាចគោរពទៅតាមគោលនយោបាយ មិនអាចសម្រេចទៅតាមគោលដៅ អ្នកឯងនឹងក្លាយទៅជាខ្មាំង។ ហើយច្បាស់ណាស់ នេះគឺជាអ្វីដែលគេដឹងគ្រប់គ្នាថាប្រសិនបើក្លាយទៅជាខ្មាំងបក្សកុម្មុយនីស្តកម្ពុជា មានន័យថាម៉េច គឺបាត់ខ្លួន គឺធ្វើទារុណកម្ម និងសម្លាប់។ ដោយសារគិតទៅដល់ឧទាហរណ៍ទាំងអស់ និងភស្តុតាងទាំងអស់គ្នា គឺយើងមិនមែនគិតតិចរើសម៉ុំៗមកនុំងទេ គឺច្បាស់ណាស់ថាការជំទាស់របស់គាត់ទៅលើការសម្រេចរបស់សាលាដំបូងពាក់ព័ន្ធ

ទៅនឹងការទទួលខុសត្រូវលើការជួយនិងជំរុញ គឺមិនមានមូលដ្ឋាន។ មូលដ្ឋានបណ្តឹងសាទុក្ខទាក់ទងទៅនឹងការផ្តន្ទាទោសចំពោះការជួយនិងជំរុញទៅដល់អំពើមនុស្សឃាត គួរត្រូវបានបដិសេធ។ ដូចគ្នានឹងមូលដ្ឋាននៃបណ្តឹងសាទុក្ខដទៃទៀតទាក់ទងទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ។

ឯកឧត្តមប្រធាន លោក លោកស្រី ចៅក្រម ខ្ញុំសូមបញ្ចប់សារណារបស់ខាងព្រះរាជអាជ្ញាទាក់ទងទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ម្ចាស់បណ្តឹងសាទុក្ខ។ សូមអរគុណ។

[១២:២៤:១៤]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបជូនថា យើងល្ងាចនេះយើងនឹងបន្តសវនាការទៅទៀត នៅវេលាម៉ោងដប់បួន និងប្រាំនាទី។ ដូច្នេះគឺសូមមន្ត្រីខាងពន្ធនាគារនាំជនជាប់ចោទទៅកន្លែងសម្រាក ហើយនិងនាំជនជាប់ចោទមកវិញនៅវេលាម៉ោងដប់បី និងហាសិបនាទី។

ហើយតុលាការប្រកាសសម្រាក!

*(សវនាការសម្រាកពីម៉ោង ១២:២៤ នាទី ដល់ម៉ោង ១៤:០៣ នាទី)*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសចាប់ផ្តើមបន្តសវនាការ ហើយនៅពេលល្ងាចនេះ គឺមានការផ្លាស់ប្តូរលោកក្រឡាបញ្ជីដោយ ក្រឡាបញ្ជី ស៊ា ម៉ៅ ចូលជំនួសក្រឡាបញ្ជី ផន ធឿន។ លោកក្រឡាបញ្ជី តើមានវត្តមានគ្រប់ចំនួនទេ?

**ក្រឡាបញ្ជី៖**

ជម្រាបប្រសាសន៍ឯកឧត្តមប្រធាន និងក្រុមប្រឹក្សាបាទ ភាគីមានវត្តមានគ្រប់ចំនួនហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាបន្តនេះ គឺយើងចូលដល់សំណួររបស់អង្គជំនុំជម្រះ។ អ៊ីចឹងចៅក្រមមានសំណួរសូមអញ្ជើញលើកសំណួរ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

ឥឡូវនេះ ខ្ញុំចង់សួរទៅលោកស្រី អង់តា ហ្គីសសេ ទាក់ទងទៅនឹងសារណារបស់លោកស្រី។ ខ្ញុំចង់ដឹងថា អំពីបញ្ហាការសម្ងាត់ខ្លាំងរបស់ខ្មែរក្រហម ខ្ញុំចង់បញ្ជាក់ថា តើអាការសម្ងាត់ហ្នឹងអនុវត្តដោយរបៀបណា? នៅពេលដែលមនុស្សម្នាក់ចូលរួមការប្រជុំអចិន្ត្រៃយ៍ ក្នុងគណៈអចិន្ត្រៃយ៍ហ្នឹង ហើយថា តើការផ្សព្វផ្សាយព័ត៌មានហ្នឹង ផ្សព្វផ្សាយដោយរបៀបណា? ហើយថាតើការរក្សាការសម្ងាត់របស់គាត់ហ្នឹង ថាតើ ការត្រូវរក្សាការសម្ងាត់របស់ ខៀវ សំផន ហ្នឹងប៉ះពាល់ដោយរបៀបណាទៅលើការងាររបស់គាត់ ឬក៏ការផ្សព្វផ្សាយរបស់គាត់នោះ? សូមអរគុណ។

[១៤:០៦:០៨]

**លោកស្រី អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

បើខ្ញុំមិនយល់ច្រឡំទេ គឺថា ការសម្ងាត់ហ្នឹង ត្រូវអនុវត្តយ៉ាងម៉េចដែរ ចំពោះអ្នកដែលចូលរួមក្នុងកិច្ចប្រជុំនៃគណៈអចិន្ត្រៃយ៍? ចម្លើយទី១របស់ខ្ញុំ អត់មានយោងទេ ប៉ុន្តែខ្ញុំនឹងត្រឡប់មកវិញនៅពេលក្រោយនៅពេលដែលខ្ញុំមានពេលមើលយោង។ ខ្ញុំគឺថា សាក្សីនេះ ធ្លាប់បានពន្យល់ថា កិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍នោះគឺមិនប្រព្រឹត្តទៅជាមួយនឹងអ្នកចូលរួមដដែលៗនោះទេ។ គឺថាមានអ្នកមកផ្សេងៗគ្នានិយាយពីប្រធានបទរបស់គេ។ ហើយចំណុចទី២គឺថា បញ្ហាប្រធានបទទូទៅដែលលើកឡើងក្នុងកិច្ចប្រជុំនេះ ដែលមានបន្ទាប់ពីអ្នកដែលទទួលបន្ទុកខាងផ្នែកប្រធានបទណាមួយជាក់លាក់ហ្នឹង គឺពួកគាត់ហ្នឹងអាចផ្តោតតែទៅលើវិស័យរបស់ខ្លួននោះទេ។ អានេះតាមការចងចាំរបស់ខ្ញុំទេ ចម្លើយនេះ។ ប៉ុន្តែខ្ញុំនឹងផ្តល់យោងនៅពេលក្រោយ។ គោលការណ៍សម្ងាត់នេះ រក្សាការសម្ងាត់នេះ គឺត្រូវបានរំឭកនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១ កាលនោះ យើងថាមាននៅក្នុងសារណាយើងនេះ ១៦៥០ ដល់១៦៥១ នៅក្នុងសារណារបស់យើង ហើយមានសាក្សី សាឡុត បាន, អិន តាន់ ខ្ញុំដឹងថាមាន ស្នួង ស៊ីគឿន ផងដែរ ដែលគាត់ផ្តល់សក្ខីកម្មដែរ គាត់ធ្វើការនៅក្រសួងការបរទេស ដែលគាត់បានពន្យល់ពីគោលការណ៍សម្ងាត់នេះផងដែរ។ ព័ត៌មានដែលនៅក្នុងមុខតំណែងរបស់គាត់ហ្នឹង គាត់មិនបានប្រាប់យើងនោះទេ។ ហើយខ្ញុំនឹងផ្តល់យោងនៅពេលក្រោយ។ ហើយនៅក្នុងសកម្មភាពទូទៅ ប្រចាំថ្ងៃនៅពេលនោះ នៅពេលដែលទទួលបន្ទុកពីគណៈអចិន្ត្រៃយ៍ទៅធ្វើការខាងពាណិជ្ជកម្មអីជាដើមនោះ គាត់មានព័ត៌មានមួយចំនួនដែលទាក់ទងនឹងផ្នែករបស់គាត់នោះ ទាក់ទងនឹងពាណិជ្ជកម្មហ្នឹងគឺគាត់ទទួលនូវក្រសួងពាណិជ្ជកម្មហ្នឹង

ប៉ុន្តែព័ត៌មានជាទូទៅ ចូលទៅមជ្ឈិមនោះ គឺយើងរិះគន់ថា តាមពិតព័ត៌មានទាំងអស់មិនត្រូវបានចែកចាយនៅពេលប្រជុំក្នុងគណៈអចិន្ត្រៃយ៍នោះទេ គឺមិនមានឆ្លងទៅឆ្លងមកទាំងអស់អ៊ីចឹងទេ គឺថាមានអ្នកទទួលផ្នែកៗរៀងខ្លួនគឺដូចជាអ្នកខាងសន្តិសុខអីជាដើម។ អ៊ីចឹងមានរបាយការណ៍ខាងសន្តិសុខហ្នឹង ដូចខាងមន្ទីរ៨៧០ហ្នឹង គឺគាត់សរសេរទៅតែខាងផ្នែកសន្តិសុខហ្នឹងទេ ដូចជាមានតែ ប៉ុល ពត ហើយ សុន សេន ទេដឹង។ អ៊ីចឹងតេឡេក្រាមទាំងអស់ហ្នឹង គឺអត់មានយកលើកមកពិភាក្សានៅក្នុងគណៈអចិន្ត្រៃយ៍នោះទេ។ នៅពេលដែលយើងមើលកំណត់ហេតុប្រជុំនោះគឺថាមានប្រធានបទផ្សេងៗគ្នា មាន -- ហើយយើងឃើញ ខៀវ សំផន តែពីរដងទេនៅក្នុងរបាយការណ៍ហ្នឹង គឺរបាយការណ៍ហ្នឹងគឺមានកាលៈទេសៈច្បាស់លាស់ទៀត។

[១៤:១០:២១]

ព្រះរាជអាជ្ញាកាលព្រឹកមិញហ្នឹងដូចនិយាយថា ដូចថា គេទាញការសន្និដ្ឋានថាដោយហេតុថាគាត់ ដោយសារ ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍នោះគឺបានន័យថាគាត់ចូលរួមជារៀងរហូតរាល់ពេល។ នេះគ្រាន់តែជាការសន្មតទេ អត់ទាន់មានភស្តុតាងណាបង្ហាញយ៉ាងដូច្នោះទេ។ អ៊ីចឹងចំណុចនេះសំខាន់ណាស់។ ខ្ញុំសូមកត់សម្គាល់ថានៅទីនេះ ហើយទាក់ទងទៅនឹងគោលការណ៍សម្ងាត់នេះ ថាគេអនុវត្តយ៉ាងម៉េចអីយ៉ាងម៉េចនោះ ថានៅក្នុងថ្នាក់លើខ្ពស់បំផុតក៏ដោយ តើគេត្រូវធ្វើយ៉ាងម៉េច? គឺធម្មតាមានរំឭកនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំនុំងមានហើយ ខ្ញុំផ្តល់ឯកសារយោងច្បាស់លាស់ហ្នឹងនៅពេលក្រោយ ដូចនិយាយពីរឿង ឌុច ដែលគាត់មានពាក់ព័ន្ធជាមួយនឹង ខៀវ សំផន គាត់ -- ឌុច គាត់និយាយថា ការប្រជុំនៅដើមខែមករា នៅដើមរដូវ នៅរបបខ្មែរក្រហម ហើយគាត់និយាយ -- ប៉ុន្តែរឿងដែលពាក់ព័ន្ធនឹងមន្ទីរស-២១នោះ គាត់អត់មាននិយាយអីជាមួយ ខៀវ សំផន ទេ គឺគាត់ពាក់ព័ន្ធតែជាមួយ សុន សេន ទេ ព្រោះគាត់ជាប្រធានមន្ទីរសន្តិសុខ ហើយ សុន សេន គាត់ជាខាងកងទ័ព អ៊ីចឹងគឺទាក់ទងគ្នានុំង។ អ៊ីចឹងគឺមានតែក្រុមតូចមួយទេដែលអាចដឹងបាន ហើយមិនមែនចែករំលែកព័ត៌មានទាំងអស់នេះជាមួយនឹងសមាជិកគណៈអចិន្ត្រៃយ៍ទាំងមូលនោះទេ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំនឹងត្រឡប់មកផ្តល់លិខិតយោងច្បាស់លាស់នៅពេលក្រោយ។

ហើយយោងចំពោះ ឌុច ហ្នឹងគឺ ១៩០៥, ១៩០៦ នៅក្នុងសារណារបស់យើង កថាខណ្ឌ។ ហើយទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង០០២/០១ នោះមានសាក្សីហ្នឹងគាត់តែមកក្នុងសំណុំរឿងហ្នឹងទេ អត់មានបានមកក្នុងសំណុំរឿង០០២/០២នោះទេ។

[១៤:១២:៥០]

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

ខ្ញុំចង់បញ្ជាក់ផងដែរ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែយើងទាំងអស់គ្នាគាំទ្រ យើងយល់ស្របជាមួយនឹងការរក្សាការសម្ងាត់ គឺថាគ្រប់គ្នាដែលមិននៅក្នុងគណៈអចិន្ត្រៃយ៍ក៏បានបញ្ជាក់ ហើយលោក ខៀវ សំផន ក៏បានបញ្ជាក់ដែរអំពី ហើយ អៀង សារី ក៏និយាយដូចគ្នាដែរ។ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយនៅពេលនេះ គឺចង់ផ្ដោតថាតើសមាជិកអចិន្ត្រៃយ៍ហ្នឹង ដែលជាអាជ្ញាធរខ្ពស់បំផុតនៅកម្ពុជាប្រជាធិបតេយ្យហ្នឹងថាតើគាត់ប្រតិបត្តិការដោយរបៀបម៉េច? វាថាទាល់តែពួកគាត់កំពូលបំផុត គាត់និយាយត្រង់ៗជាមួយគ្នាទៅវិញទៅមក បានអាចធ្វើការជាមួយគ្នាកើត? ខ្ញុំចង់និយាយអ៊ីចឹងទេ ប៉ុន្តែយ៉ាងណាក៏ដោយអរគុណចំពោះលោកស្រីដែលបានផ្ដល់នូវចម្លើយហ្នឹង។

**ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ៖**

ខ្ញុំមានសំណួរមួយចំពោះព្រះរាជអាជ្ញា។ ភស្តុតាងដែលព្រះរាជអាជ្ញាបានលើកឡើង គឺភស្តុតាងចរចាមអារ៉ាម ឬក៏ភស្តុតាងតាមកាលៈទេសៈ? ភស្តុតាងទាំងអស់នោះគឺវាមានលក្ខណៈ ជាលក្ខណៈដែលទទួលឥទ្ធិពល ថាតើយើងអាចពឹងផ្អែកភស្តុតាងហ្នឹង ថាតើយើងអាចជឿទុកចិត្តកម្រិតណា? ថាតើវាមានកាលៈទេសៈណាសម្រាប់ភស្តុតាងទាំងអស់ហ្នឹង? ខ្ញុំចង់បញ្ជាក់ពីកម្រិតនៃភាពអាចជឿជាក់បាន។ សូមអរគុណ។

[១៤:១៤:៤៣]

**លោកស្រី ប្រេនដា ហូលិស៖**

សូមអរគុណចំពោះសំណួរ។ ខ្ញុំគិតថាយើងអាចអនុវត្តគោលការណ៍ទូទៅនៃភស្តុតាង។ ដូច្នេះចំពោះភស្តុតាងឯកសារ ឬក៏ភស្តុតាងចរចាមអារ៉ាមនោះ យើងនឹងពិនិត្យមើលដើម្បីសម្រេចទៅលើភាពស៊ីសង្វាក់គ្នាផ្ទៃក្នុង។ ប្រសិនបើវាស្របគ្នាជាមួយភស្តុតាង ឬក៏ឯកសារដទៃទៀតហ្នឹងគឺប្រាកដណាស់។ ហើយម្យ៉ាងទៀត គឺមានសក្ខីកម្មសាក្សីជាច្រើនដែលបញ្ជាក់។ ហើយក៏មានឯកសារភស្តុតាងដែលសាលាដំបូងបានសម្រេចថាជឿជាក់បាន។ ដូច្នេះហើយអានេះគឺជាវិធីសាស្ត្រដែលយើងអនុវត្ត ហើយនិងការផ្ដល់នូវទម្ងន់នៃភាពជឿជាក់បានទៅលើឯកសារមួយចំនួន។ ហើយនេះគឺជាអ្វីដែលខ្ញុំចង់បញ្ជាក់គឺថាយើងប្រើប្រាស់កត្តាទាំងអស់នេះ ដើម្បីវាយតម្លៃ ដើម្បីឱ្យរកឃើញថាវាមានភាពស៊ីសង្វាក់គ្នាដែរឬក៏អត់។ ដូច្នេះហើយវាគឺជាឯកសារដែលមានទម្រង់ដូចគ្នា ដែលមានខ្លឹមសារដូចគ្នា ហើយនិងឯកសារ

ខ្លះទៀតដែលយើងជឿជាក់ថាមកពីប្រភពផ្សេងៗគ្នា ប្រសិនបើវាស្របគ្នាស៊ីសង្វាក់គ្នា អាហ្នឹងគឺជាអ្វីដែលយើងជឿជាក់បាន។ ហើយខ្ញុំគិតថា ប្រភេទនៃការវិភាគដែលសាលាដំបូងប្រើប្រាស់នុ៎ង គឺជាការវិភាគមួយ -- ឯកសារនីមួយៗដោយលម្អិតតែម្តង។ ហ្នឹងខ្ញុំជឿជាក់ថាអ៊ីចឹងលោកចៅក្រម។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

អ្វីដែលលោកស្រីចង់និយាយគឺថាលោកស្រីពឹងផ្អែកទៅលើឯកសារតាមកាលៈទេសៈ ឬក៏ឯកសារចរចាមអារ៉ាម អ៊ីចឹងមែនទេ?

**លោកស្រី ប្រេនដា ហូលិស៖**

គឺជាអ្វីដែល -- គឺយើងផ្អែកទៅលើអ្វីដែលសាក្សីបាននិយាយអំពីទីតាំង អំពីកន្លែង ហើយនិងគោលនយោបាយមួយផ្សេងៗទៀត។ អានេះគឺជាអ្វីដែលខ្ញុំចង់បញ្ជាក់ ហើយនេះគឺជាភស្តុតាងផ្ទាល់របស់សាក្សីដែលគាត់ឮថាម្ចាស់បណ្តឹងសាទុក្ខគាត់និយាយថាអ៊ីចេះ ថាអ៊ីចុះជាដើម។ ហ្នឹងជាលក្ខណៈពិសេសមួយនៃពាក្យចរចាមអារម្មណ៍ផងដែរ។ ដូច្នេះហើយខ្ញុំគិតថា វាជាពាក្យចរចាមអារ៉ាម។ យើងមានព័ត៌មានជាច្រើន ដូចដែលលោក លោកស្រីចៅក្រមជ្រាបហើយ ថាវាមានភស្តុតាងតាមកាលៈទេសៈមួយចំនួនផងដែរ។

[១៤:១៧:៤៨]

**ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ៖**

ប៉ុន្តែថាតើបញ្ជាក់បានដែរឬទេ យើងៗទទួលស្គាល់ការបង្ហាញភស្តុតាងមួយវាគឺជាការលំបាក។ ប៉ុន្តែយើងស្ថិតនៅក្នុងស្ថានភាពមួយដូចដែលសាលាដំបូងប្រឈម គឺយើងមានការប្រឈម ទាក់ទងទៅនឹងភស្តុតាងនៅក្នុងសំណុំរឿង។ សុំទោសលោកស្រីនិយាយថាម៉េចមិញ?

**លោកស្រី ប្រេនដា ហូលិស៖**

ខ្ញុំនិយាយថា ប្រាកដណាស់។ លោក លោកស្រីចៅក្រម គឺការពិតការបង្ហាញឲ្យហួសពីវិមតិសង្ស័យគឺជាការប្រឈមលំបាកមួយ។ ប៉ុន្តែយើងយល់ស្របដូចនឹងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងគាត់វិភាគ គឺថាជារួមសរុបទៅគឺភស្តុតាងអាចជឿជាក់បាន។ ហើយខ្ញុំស្របជាមួយនឹងការជំទាស់ដែលលោកចៅក្រមនិយាយ។ ប៉ុន្តែឥឡូវយើងធៀបដូចថា ឥឡូវប្រសិនបើយើងព្យាយាមឡើងភ្នំ នៅពេលដែលយើងឡើងទៅដល់កំពូលភ្នំ យើងអាចមើលឃើញច្បាស់។ វាដូចដែលសាលាដំបូងធ្វើអ៊ីចឹង គឺថាគាត់ ពិនិត្យមើលទៅលើជារួម ទិដ្ឋភាពជារួម ដូចយើងនៅលើភ្នំអ៊ីចឹង មើលទៅឃើញជារួមតែម្តង។

**ចៅក្រម ចាន់ដារ៉ា នីហាល ចាយ៉ាស៊ីញហេ៖**

អរគុណ។ ខ្ញុំយល់ពីអ្វីដែលលោកស្រីចង់បកស្រាយ។ បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបើមិនមានសំណួរបន្តទៀតទេ គឺសូមអញ្ជើញសហចៅក្រមរបាយការណ៍ អានរបាយ-ការណ៍ទាក់ទងនឹងវគ្គទី៥ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងការប្រកាសទោស។ សូមអញ្ជើញ!

[១៤:១៩:៤៨]

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

សូមជម្រាបសួរ។ យោងតាមសារណានៃបណ្តឹងសាទុក្ខរបស់ភាគីជនជាប់ចោទ ប្រធានបទស្តីអំពីការប្រកាសទោសនេះ ត្រូវម្ចាស់បណ្តឹងសាទុក្ខរៀបរាប់ចំនួន៤០ កថាខណ្ឌ គឺចាប់ពីកថាខណ្ឌ ២១៤៤ ដល់កថាខណ្ឌ ២១៨៤ ហើយដែលម្ចាស់បណ្តឹងសាទុក្ខបានដាក់ចំណងជើងថា "សំណើបន្ទាប់បន្សំបំផុត"។ ក្នុងនាមចៅក្រម នីហាល ចាយ៉ាស៊ីញហេ និងរូបខ្ញុំ ខ្ញុំបាទសូមធ្វើសេចក្តីសង្ខេបអំពីរបាយការណ៍ដូចខាងក្រោម៖

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចប្រកាសទោសជនជាប់ចោទដាក់ពន្ធនាគារ កំណត់រយៈពេលអស់មួយជីវិត ពីបទឧក្រិដ្ឋ ដែលរូបគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាព។ ការប្រកាសទោសនេះ គឺធ្វើឡើងដោយរួមគ្នា ដោយស្រូបបញ្ចូលគ្នាជាមួយនឹងការប្រកាសទោសអស់មួយជីវិតលើកមុន ដែលបានដាក់ពីបទឧក្រិដ្ឋនៅក្នុងសំណុំរឿង០០២/១ និងត្រូវបានប្រកាសតម្កល់ដោយអង្គជំនុំជម្រះតុលាការកំពូល។ នៅក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ខ្លួន ជនជាប់ចោទបានលើកអំណះអំណាងចំនួនបួនចំណុចសំខាន់ជំទាស់ទៅនឹងភាពត្រឹមត្រូវនៃការប្រកាសទោស ដែលខ្ញុំបាទសូមសង្ខេបដូចខាងក្រោម៖

ទី១ អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការបញ្ជាក់ថា គោលដៅចម្បងនៃការប្រកាសទោស គឺដើម្បីធានាដល់ជនរងគ្រោះ សាក្សី សាធារណជន និងថា ច្បាប់កំពុងបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងអនុវត្តទៅលើបុគ្គលទាំងអស់ ដោយមិនគិតអំពីឋានៈឡើយ។ ជនជាប់ចោទបានអះអាងថា នេះគឺជាគោលដៅបន្ទាប់បន្សំនៃការប្រកាសទោស។ ដូចនេះគឺបង្ហាញពីភាពលម្អៀង ហើយការប្រកាសទោសនេះគឺមានភាពធ្ងន់ធ្ងរហួសហេតុពេក។

[១៤:២២:០៧]

ទី២ អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តិកំហុសទាំងអង្គហេតុ និងអង្គច្បាប់នៅក្នុងការវាយ

តម្លៃអំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដោយសារអង្គជំនុំជម្រះបានពិចារណាលើបទឧក្រិដ្ឋ ដែលជនជាប់ចោទពុំត្រូវបានចោទប្រកាន់ ឬដាក់ពិរុទ្ធភាពនោះឡើយ។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានពិរណាទៅលើបទរំលោភសេពសន្ថវៈ ទៅលើអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខជាដើម។ ដោយសារតែបញ្ហាដែលថា ការបង្ហាញភស្តុតាងឲ្យហួសពីមតិសង្ស័យត្រូវបានលើកយកមកពិចារណានៅដំណាក់កាលនៃការប្រកាសទោស ដូច្នេះចំណុចនេះបានធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងរំលោភបំពានលើគោលការណ៍នៃការប្រកាសទោស។

ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងបានខកខានក្នុងការពិចារណាលើលក្ខណៈ និងវិសាលភាពមានកម្រិត និងដោយប្រយោលក្នុងការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មនៅពេលដែលធ្វើការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ។ ដូច្នេះបានរំលោភបំពានលើការអនុវត្តស្តីពីការដាក់ទោសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលចូលរួមដោយប្រយោល ដោយសំខាន់ ឬមិនសំខាន់ ដែលតាមធម្មតានាំទៅរកការប្រកាសទោសក្នុងកម្រិតស្រាលជាងនេះ។

ទី៣ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការវាយតម្លៃទៅលើខ្លួនអំពីស្ថានទម្ងន់ទោសចំនួនពីរចំណុច។ ទី១ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការរំលោភតួនាទី និងសិទ្ធិអំណាចរបស់គាត់--

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន ខ្ញុំមិនទទួលបានការបកប្រែជាភាសាខ្មែរ -- ជាភាសាអង់គ្លេសទេលោកប្រធាន។

[១៤:២៤:១៥]

*(មានបញ្ហាបច្ចេកទេស)*

[១៤:២៥:២៣]

លោកប្រធាន ខ្ញុំស្តាប់ឮអ្នកបកប្រែបកចេញទៅភាសាបារាំង។

**ប្រធានអង្គជំនុំ៖**

ចំពោះភាសាផ្សេងទៀត មានបញ្ហាអីចឹងទុកឲ្យបច្ចេកទេសគេរៀបចំបន្តិចសិន។

[១៤:២៥:៥៦]

*(មានបញ្ហាបច្ចេកទេស)*

[១៤:២៦:៤០]

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

ខ្ញុំអាចបន្តបានណ៎ា។ ទី៣ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសទាំងអង្គច្បាប់និងអង្គហេតុក្នុងការវាយតម្លៃលើស្ថានទម្ងន់ទោសចំនួនពីរចំណុច។ ទី១ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការរំលោភតួនាទី និងសិទ្ធិអំណាចរបស់គាត់ និងឥទ្ធិពលជាស្ថានទម្ងន់ទោសមួយដែលផ្ទុយគ្នាទៅនឹងការយល់ឃើញរបស់ខ្លួនដែលថា ជនជាប់ចោទពុំមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការបញ្ជាដោយផ្ទាល់ដល់ការប្រព្រឹត្តបទឧក្រិដ្ឋ។ តួនាទីនៃសិទ្ធិអំណាចរបស់គាត់ត្រូវបានយកមកពិចារណារួចរាល់ហើយក្នុងអំឡុងពេលនៃការវាយតម្លៃលើស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ២) អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្ហាញអំពីភាពពាក់ព័ន្ធនិងទំនាក់ទំនងនៃកម្រិតចំណេះដឹងរបស់គាត់ថាជាស្ថានទម្ងន់ទោស។ ទី៤ ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ នៅក្នុងការវាយតម្លៃអំពីស្ថានសម្រាលទោស។

ទី១ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្តល់ការពិចារណាសមស្របលើកិច្ចសហការរបស់គាត់ជាមួយនឹង អ.វ.ត.ក រួមទាំងការចូលរួមយ៉ាងសកម្មរបស់គាត់នៅពេលជំនុំជម្រះ អត្តចរិតល្អប្រសើររបស់គាត់ក្នុងអំឡុងពេលនៃការឃុំខ្លួន និងការទទួលស្គាល់នូវការរងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាដើម។ ទី២ អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការផ្តល់នូវទម្ងន់គ្រប់គ្រាន់សម្រាប់វ័យចំណាស់របស់គាត់ និងស្ថានភាពសុខភាព និងលទ្ធភាពដែលពុំអាចទ្រាំទ្រយូរក្នុងពន្ធនាគារជាដើម។

អង្គជំនុំជម្រះក៏មានកំហុសផងដែរ ដោយពុំបានវាយតម្លៃថ្មីអំពីតម្លៃដែលត្រូវផ្តល់ចំពោះសាក្សីចរិតលក្ខណៈ និងដោយខកខានក្នុងការពិចារណារាល់សមាសធាតុទាំងអស់ នៃបុគ្គលិកលក្ខណៈរបស់គាត់ និងមិនអើពើចំណុចល្អៗដែលគួរឲ្យសរសើរព្រមគ្នារបស់គាត់។ សរុបសេចក្តីមក ជនជាប់ចោទបានលើកឡើងថា កំហុសទាំងអស់នេះ បានធ្វើឲ្យសេចក្តីសម្រេចរបស់សាលាដំបូងទៅជាមោឃៈស្តីពីប្រកាសទោសលើរូបជនជាប់ចោទ ដែលតាមការអះអាងរបស់គាត់គប្បីត្រូវបានកាត់បន្ថយមកជាទោសជាប់ពន្ធនាគារមានរយៈពេលកំណត់។ របាយការណ៍របស់ខ្ញុំបាទ សូមបញ្ចប់ត្រឹមប៉ុណ្ណេះ និងសូមដាក់ជូនក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិនិត្យនិងពិចារណា។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញសហមេធាវីការពារក្តីធ្វើសារណា។

[១៤:២៩:៣៥]

**លោក គង់ សំអុន៖**

សូមអរគុណឯកឧត្តមប្រធាន។ ខ្ញុំបាទ គង់ សំអុន ជាសហមេធាវីជាតិការពារលោក ខៀវ សំផន សូមធ្វើសារណាផ្ទាល់មាត់ទាក់ទងទៅនឹងការប្រកាសទោស។

ឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម ខ្ញុំនឹងមិននិយាយច្រើនអំពីបញ្ហាទោសនេះទេ ពីព្រោះដូចឯកឧត្តម លោក លោកស្រីចៅក្រម បានជ្រាបរួចហើយ។ ជាការសំខាន់បំផុតនោះ យើងទាមទារឲ្យធ្វើមោឃភាពសាលក្រម និងដោះលែងលោក ខៀវ សំផន។ ប៉ុន្តែយ៉ាងណាក្តី សូម្បីតែពាក់ព័ន្ធនឹងបញ្ហាប្រកាសទោសនេះ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុដែលធ្វើឱ្យសេចក្តីសម្រេចរបស់ខ្លួនក្លាយជាមោឃៈដែរ។ កំហុសទាំងនេះមានច្រើនណាស់ ហើយគ្រប់ដណ្តប់លើគ្រប់ទិដ្ឋភាពនៃការកំណត់ទោស។ គ្មានទឡ្ហីករណ៍ណាមួយរបស់សហព្រះរាជអាជ្ញាធ្វើឱ្យឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម ជឿជាក់ថាអង្គជំនុំជម្រះសាលាដំបូងគ្មានកំហុសនោះឡើយ។ បន្ទាប់ពីបានអានសារណាតបរបស់សហព្រះរាជអាជ្ញារួចមក ខ្ញុំគ្រាន់តែសុំរំឭកត្រួសៗអំពីមូលដ្ឋានបណ្តឹងសាទុក្ខរបស់យើងទាំងអស់ និងផ្តល់ទឡ្ហីករណ៍ខ្លីៗតបទៅសហព្រះរាជអាជ្ញា លើចំណុចមួយចំនួនប៉ុណ្ណោះ។

[១៤:៣១:១២]

ខ្ញុំនឹងមិនបរិយាយពាក់ព័ន្ធនឹងចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហាកំណត់ទោសនេះទេ គឺគ្រាន់តែចង់លើកឡើងថា ពួកគេមិនគួរធ្វើអន្តរាគមន៍លើបញ្ហានេះឡើយ។ ដូចយើងបានរំឭកក្នុងសារណាចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ឯកសារ F60/1 រួចមកហើយ។ មានគោលការណ៍ជាមូលដ្ឋាននៅក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌដែលមានបណ្តឹងរដ្ឋប្បវេណី ដែលថា ទោះជាក្នុងករណីណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើអន្តរាគមន៍ក្នុងការកំណត់ទោសបានឡើយ ពីព្រោះវាជាការទទួលខុសត្រូវផ្តាច់មុខរបស់សហព្រះរាជអាជ្ញា។ ដូច្នេះជាគោលការណ៍ ដោយហេតុថាយើងត្រូវប្រឈមមុខនឹងភាគីចោទប្រកាន់តែមួយគត់ យើងសូមមិនឆ្លើយតបនឹងដើមបណ្តឹងរដ្ឋប្បវេណីឡើយ ដោយសង្ឃឹមថាឯកឧត្តម លោក លោកស្រីចៅក្រម នឹងមិនទទួលរងនូវឥទ្ធិពលពីទឡ្ហីករណ៍ដែលមិនគួរលើកឡើងទាល់តែសោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលលោក លោកស្រីចៅក្រម នឹងមិនយកទឡ្ហីករណ៍ទាំងនោះយកមកធ្វើការពិចារណានោះទេ។ ដូចខ្ញុំបាទបានលើករួចហើយ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសលើគ្រប់ទិដ្ឋភាពនៃការកំណត់ទោស។ និយាយឱ្យចំតែម្តង គឺពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស និងគោលបំណងនៃការប្រកាសទោស។ ខ្ញុំនឹងលើក

ឡើងនូវទិដ្ឋភាពទាំងនេះមួយម្ដងៗ។

[១៤:៣៣:០៦]

ជាបឋម ខ្ញុំសូមអនុញ្ញាតលើកអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។ ទាក់ទងចំណុចនេះអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសចំនួនពីរ។ កំហុសទី១ ដើម្បីកំណត់ភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់ទៅលើលោក ខៀវ សំផន គឺការរំលោភផ្លូវភេទដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខដែលសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ខ្ញុំសុំដកស្រង់៖ "គោលនយោបាយជាផ្លូវការរបស់ ប.ក.ក ពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ គឺបង្ការបទឧក្រិដ្ឋ និងដាក់ទណ្ឌកម្មដល់ចារី"។ បិទការដកស្រង់។ ដូច្នេះសហចៅក្រមស៊ើបអង្កេតបានសម្រេចមិនបញ្ជូនជនជាប់ចោទទៅជំនុំជម្រះពីអង្គហេតុទាំងនេះឡើយ។

សហព្រះរាជអាជ្ញាដែលមិនបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចនេះ ទទួលស្គាល់ថាលោក ខៀវ សំផន មិនបាន មិនចាំបាច់ទទួលខុសត្រូវចំពោះអង្គហេតុទាំងនោះទេ។ ទោះជាយ៉ាងនេះក្ដី សហព្រះរាជអាជ្ញាបែរជាប៉ានអះអាងថា នេះជាភស្តុតាងពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការឃុំឃាំងដែលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ ហើយអង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើភស្តុតាងទាំងនោះបានវិញ ។

[១៤:៣៤:៤១]

ទឡ្ហីករណ៍នេះគួរឲ្យភ្ញាក់ផ្អើលខ្លាំងណាស់។ តើចាប់ពីពេលណាមកដែលភស្តុតាងនៃឧក្រិដ្ឋកម្មដែលពិរុទ្ធជនមិនត្រូវបានចោទប្រកាន់ ត្រូវបានយកមកពិចារណាដើម្បីកំណត់អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលរូបគេមិនបានប្រព្រឹត្ត និងការប្រកាសទោសចំពោះឧក្រិដ្ឋកម្មរបស់ខ្លួននោះ។ ចម្លើយតាមផ្លូវច្បាប់ និងជាក់ស្ដែងនោះគឺថា គ្មានទាល់តែសោះ នេះជាទង្វើខុសច្បាប់នឹងមិនអាចទទួលយកបានរបស់អង្គជំនុំជម្រះសាលាដំបូងដែលបណ្ដោយឲ្យភស្តុតាងអំពីអង្គហេតុ ក្រៅពីបទចោទចូលក្នុងដំណើរការនីតិវិធីជំនុំជម្រះដែលមានលក្ខណៈជាប្រវត្តិសាស្ត្រផ្លូវច្បាប់នេះ។ ដើម្បីឆ្លើយទៅសហព្រះរាជអាជ្ញាយើងបានព្យាយាមរកករណីក្នុងយុត្តិសាស្ត្រមុនៗដែលមាន ប៉ុន្តែយើងរកមិនឃើញទេ ខ្ញុំសូមនិយាយថាកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងចម្លែកមែនទែន យើងរកឃើញយុត្តិសាស្ត្រតែមួយគត់ក្នុងស្ថានភាពស្រដៀងគ្នានេះ។ នៅក្នុងរឿង វ៉ុលឡេតប៊ូទែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់ប្រទេសរវ៉ាន់ដា បានកត់សម្គាល់ឃើញកំហុសចៅក្រមជំនុំជម្រះដែលបានពិចារណា

លើតួនាទីចម្បងរបស់ជនជាប់ចោទនៅក្នុងបទឧក្រិដ្ឋ ដែលពួកគេបានដោះលែងដើម្បីកំណត់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសាលដីកា ប៊ូទែរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ៣៤៣១។ ខ្ញុំមិនដឹងថា ករណីនេះគ្រប់គ្រាន់ធ្វើឲ្យសហព្រះរាជអាជ្ញាជឿជាក់បានដែរទេ ប៉ុន្តែខ្ញុំប្រាកដថា លោកលោកស្រីចៅក្រម ដឹងច្បាស់ គេមិនត្រូវកំណត់ទោសរបស់ជនជាប់ចោទណាម្នាក់ដោយផ្អែកលើឧក្រិដ្ឋកម្មដែលរូបគេ មិនបានប្រព្រឹត្ត ឬដោយផ្អែកលើឧក្រិដ្ឋកម្មដែលរូបគេមិនធ្លាប់ត្រូវបានចោទប្រកាន់នោះឡើយ។ កំហុសទី២ របស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើលក្ខណៈប្រយោលនៃការចូលរួមរបស់លោក ខៀវ សំផន នោះឡើយ។ បើតាមយុត្តិសាស្ត្រនៅតុលាការ នូរឹមប៊ឺក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា លោក ខៀវ សំផន គួរទទួលទោស ស្រាលជាងករណីចូលរួមផ្ទាល់។

[១៤:៣៧:៣២]

បន្ទាប់មកទៀត ចំពោះស្ថានទម្ងន់ទោស។ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសជាច្រើន អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា លោក ខៀវ សំផន បានរំលោភលើតួនាទីមានអំណាចរបស់ខ្លួន។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបែរជាទទួលស្គាល់ថា គាត់គ្មានអំណាចជាក់ស្តែង គ្មានការទទួលខុសត្រូវ ឬអំណាចយោធាឡើយ ប៉ុន្តែមានតួនាទីធំធេងជានិមិត្តរូបប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងបានអះអាងផងដែរថា លោក ខៀវ សំផន បានរំលោភអំណាចដ៏មានឥទ្ធិពលរបស់ខ្លួន ខណៈដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងនេះរួចហើយ នៅក្នុងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។ ក៏ប៉ុន្តែភស្តុតាងខាងអង្គច្បាប់បានបង្ហាញថា ធាតុមួយដែលមិនអាចយកមកពិចារណាសម្រាប់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មផង និងស្ថានទម្ងន់ទោសផងនោះទេ។ ពោលគឺ យកបានតែមួយ យកមកអនុវត្តបានតែមួយ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានទទួលយកជាស្ថានទម្ងន់ទោស ហើយគ្មានសំអាងហេតុនៅកម្រិតវប្បធម៌របស់លោក ខៀវ សំផន ដែលអាចឲ្យគាត់ ខ្ញុំសុំដកស្រង់៖ វាយតម្លៃលើវិសាលភាពនិងផលវិបាកនៃអំពើរបស់គាត់។ អ្នកណាក៏ដោយដែលមានបញ្ញាស្មារតីធម្មតា ក៏អាចវាយតម្លៃពីវិសាលភាព និងផលវិបាក នៃអំពើរបស់ខ្លួនបានដែរ ដោយមិនគិតពីប្រវត្តិនៃការសិក្សានោះទេ។

ឥឡូវនេះ ចំពោះស្ថានសម្រាលទោស។ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសចំនួនបី។ កំហុសទី១ កំហុសនេះអាចត្រូវបានសង្ខេបត្រឹមថា អង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំ កិច្ចសហការជាមួយតុលាការ ជាមួយនឹងការសារភាពពិរុទ្ធភាព។ កំហុសទី២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេច

ផ្តល់ទម្ងន់តិចតួចបំផុតដល់វ័យចាស់ជរា និងស្ថានភាពសុខភាពរបស់លោក ខៀវ សំផន។ ប៉ុន្តែអង្គជំនុំជម្រះបែរជាផ្តល់ឲ្យទម្ងន់ធ្ងន់ដល់កត្តាទាំងនេះនៅក្នុងសេចក្តីសម្រេចជាច្រើនដើម្បីជំនុំជម្រះលោក ខៀវ សំផន ឲ្យបានឆាប់រហ័សមុននឹងគាត់ស្លាប់។

[១៤:៤០:២៣]

លើសពីនេះទៅទៀត ផ្ទុយពីយុត្តិសាស្ត្រនិងសុភវិនិច្ឆ័យ អង្គជំនុំជម្រះមិនបានពិចារណាលើលក្ខណៈវិវឌ្ឍនៃកត្តាទាំងនេះទេ ដែលមិនអាចវិវឌ្ឍទៅរកភាពប្រសើរឡើងវិញបាននោះ។ សហព្រះរាជអាជ្ញាបានលើកឡើងនូវចំណុចមួយចំនួន ដែលបានដកស្រង់ចេញពីសេចក្តីសម្រេចមួយកាលពីឆ្នាំ២០១៨ ដូចជាថា លោក ខៀវ សំផន អាចដើរបានដោយគ្មានការជួយទប់ ឬគាត់ហាត់ប្រាណនៅពេលល្ងាច។ ក៏ប៉ុន្តែសព្វថ្ងៃនេះ គាត់មិនអាចធ្វើបែបនេះបានទេ។ ការចុះថមថយខាងរាងកាយរបស់លោក ខៀវ សំផន តាមកាលវេលាគប្បីនឹងត្រូវលើកយកមកពិចារណាផងដែរ។ កំហុសទី៣ ពាក់ព័ន្ធនឹងស្ថានសម្រាលទោស អង្គជំនុំជម្រះសាលាដំបូងគ្មានបំណងទាល់តែសោះ ក្នុងការពិចារណាលើសីលធម៌ល្អរបស់លោក ខៀវ សំផន ដែលត្រូវបានបញ្ជាក់ ដោយមិនអាចប្រកែកបានពីសំណាក់សាក្សីជាច្រើន ដែលបានស្គាល់ឬមិនស្គាល់គាត់។ សហព្រះរាជអាជ្ញា ជឿជាក់សមទំនងក្នុងការលើកឡើងនូវសក្ខីកម្មចំនួនបី ដែលបង្ហាញថា កេរ្តិ៍ឈ្មោះជាមនុស្សឈ្មោះត្រង់ និងសុចរិតរបស់លោក ខៀវ សំផន ឬការស្ងើចសរសើរពីសំណាក់មហាជនមានត្រឹមតែឆ្នាំ១៩៧៥ ប៉ុណ្ណោះ។ ចំណុចនេះ ដូចនឹងយុត្តិសាស្ត្ររបស់តុលាការអន្តរ-ជាតិនានាដែលពិចារណាដល់សីលធម៌ល្អនៅមុនពេលកើតហេតុក្នុងការកំណត់ទោសនោះ។

[១៤:៤២:១២]

យើងបានលើកឡើងរួចហើយនៅក្នុងសារណារបស់យើង។ ខ្ញុំសូមលើកយោងលើសាលក្រមប្រាំពីរផ្សេងទៀត ដែលខ្ញុំនឹងមិនដកស្រង់នៅទីនេះទេប៉ុន្តែយើងបានភ្ជាប់នឹងបញ្ជីឯកសារសំអាងសម្រាប់ការធ្វើសារណាការពាររួចហើយ ដែលបង្ហាញថា អង្គជំនុំជម្រសាលាដំបូងគួរតែពិចារណាដល់ចំណុចទាំងនេះ។ នៅទីបញ្ចប់ និងជាចំណុចចុងក្រោយ កំហុសដែលអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តពាក់ព័ន្ធទៅនឹងគោលបំណងនៃការប្រកាសទោស។ គោលបំណងនៃការប្រកាសទោសនេះ ជាដើមហេតុនៃកំហុសជាច្រើនដែលខ្ញុំទើបនឹងលើកឡើង។ បើតាមសហព្រះរាជអាជ្ញាថា ទឡ្ហីករណ៍របស់យើងមានលក្ខណៈស្រពិចស្រពិល។ ប៉ុន្តែទឡ្ហីករណ៍ទាំងនេះងាយយល់ និងច្បាស់លាស់បំផុត ដូចសេចក្តីសង្ខេបរបស់ចៅក្រមរបាយការណ៍បានធ្វើអម្បាញ់មិញនេះល្អណាស់។ ទោះបញ្ជាក់ថា លោកចៅក្រមបានយល់

ច្បាស់នូវខ្លឹមសារនេះ និងសារណានេះរបស់យើងយ៉ាងណាក្តី គោលបំណងនៃទោស គឺតម្រង់ទិសដល់ចៅក្រមក្នុងការកំណត់ទោសឲ្យបានត្រឹមត្រូវ។

នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ យុត្តិសាស្ត្រមានលក្ខណៈខ្ជាប់ខ្ជួន និងទទួលស្គាល់គោលដៅចម្បងពីរនៃទោសគឺការដាក់ទណ្ឌកម្ម និងការធ្វើឲ្យរាងចាល។ បើប្រើតាមពាក្យពេចន៍នៅក្នុងសាលក្រមរបស់តុលាការអន្តរជាតិ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅកថាខណ្ឌ ៥០៨ គឺគេប្រើជាវាំងននក្រោយឆាក សម្រាប់ការកំណត់ទោស។ ប៉ុន្តែ ដើម្បីកំណត់ទោសរបស់លោកខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ភារកិច្ចចម្បងរបស់ខ្លួន គឺបង្ហាញដល់ជនរងគ្រោះ និងសាធារណជនថា ទោសត្រូវបានដាក់ស្របតាមច្បាប់។ នៅពេលដែលតម្កល់ជនរងគ្រោះ និងសាធារណជននៅពីលើជនជាប់ចោទ ដោយភាន់ច្រឡំ អង្គជំនុំជម្រះសាលាដំបូងមិនអាចកំណត់ទោសឲ្យបានត្រឹមត្រូវសម្រាប់ជនជាប់ចោទ ដែលត្រូវជាអ្នកពាក់ព័ន្ធទី១នោះឡើយ។ ប្រសិនបើវាំងននក្រៅឆាកខុស អ្វីៗដែលនៅសេសសល់ក៏ខុសដូចគ្នាដែរ។

កំហុសចម្បងរបស់អង្គជំនុំជម្រះសលាដំបូងពាក់ព័ន្ធនឹងការប្រកាសទោស ក៏ដូចជាសាលក្រមទាំងមូល គឺថា អង្គជំនុំជម្រះសាលាដំបូងបានតម្កល់និមិត្តរូបឲ្យនៅពីលើច្បាប់ ដែលជាការអនុវត្តបែបលម្អៀង បែបអគតិ។ ទាំងនេះបង្ហាញឲ្យឃើញថា របៀបនៃការចេញសាលក្រមទាំងការកំណត់ទោស និងសាលក្រមទាំងមូល គឺមិនត្រឹមត្រូវឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកបន្តិចសិន គឺមានរយៈពេល ៣០នាទីគិតពីពេលនេះទៅបាទ។ អ៊ីចឹងសូមសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦នាទី ដល់ម៉ោង ១៥:១៤នាទី)*

[១៥:១៤:១០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសារណា។

**លោកស្រី ជា លាង៖**

សូមអរគុណ។ សូមគោរពឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម ក៏ដូចជាអង្គសវនាការទាំងមូល។ ថ្ងៃនេះ ខ្ញុំនឹងពិភាក្សាអំពីមូលហេតុដែលអំណះអំណាងរបស់ម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន មិនបានបង្ហាញអំពីកំហុសណាមួយ ដែលនឹងកាត់បន្ថយដល់ការកំណត់ទោសរបស់គាត់។ ទី១ គាត់បានជំទាស់ទៅនឹងគោលបំណងនៃការកំណត់ទោស ដោយវាយប្រហារទៅលើការសន្និដ្ឋាន ដែលដូចគ្នាបេះបិតទៅនឹងការសន្និដ្ឋាននៅក្នុងសំណុំរឿងក្ដី០០២/០១។ ទោះបីជាគាត់ប្រើពាក្យពេចន៍ខុសគ្នាបន្តិចបន្តួចក៏ដោយ ក៏គាត់លើកឡើងម្ដងទៀតនូវអំណះអំណាងមិនត្រឹមត្រូវរបស់គាត់ក្នុងសំណុំរឿង០០២/០១ ថា ការសន្និដ្ឋាននោះបង្ហាញពីភាពលម្អៀងដោយហេតុថា វាសង្កត់ធ្ងន់ទៅលើគោលបំណងនៃការកំណត់ទោស ដែលសំដៅទៅលើការបង្ការជាទូទៅ ជាជាងគោលបំណងនៃការកំណត់ទោសដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទ។ អំណះអំណាងនេះគប្បីត្រូវច្រានចោលដោយហេតុថា វានៅតែមិនច្បាស់លាស់ហើយសំខាន់ជាងនេះទៀតនោះ វាមិនមានភាពលម្អៀងដូចដែលលោក លោកស្រី ចៅក្រមបានសម្រេចនៅក្នុងរឿងក្ដី០០២/០១ ដែរ។ បណ្ដឹងសាទុក្ខមិនបានលើកឡើងនូវអ្វីថ្មីដែលចាំបាច់នាំឱ្យមានលទ្ធផលផ្សេងទេ។ ទី២ ការអះអាងរបស់គាត់ថា ការវាយតម្លៃអំពីទម្ងន់ទោសបានដាក់បញ្ចូលមិនត្រឹមត្រូវនូវឧក្រិដ្ឋកម្មនៅក្រៅវិសាលភាពនៃរឿងក្ដី ដកស្រង់តែអំពីបៀតបៀនផ្លូវភេទតែមួយប៉ុណ្ណោះនៅមន្ទីរសន្តិសុខក្រាំងតាចាន់ធ្វើជាមូលហេតុក្នុងការបន្ថយការកំណត់ទោសរបស់គាត់។

ទោះបីជាលោក លោកស្រី ចៅក្រមសម្រេចថា អង្គជំនុំជម្រះមានកំហុសដោយការពិចារណាលើការរំលោភសេពសន្ថវៈគប្បីបង្ហាញពីភាពសាហាវឃោឃៅនៃលក្ខណៈ -- នៃលក្ខខណ្ឌមន្ទីរឃុំឃាំងក្ដីក៏ភស្តុតាងដែលនៅសល់បានបង្ហាញយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមានលក្ខណៈធ្ងន់ធ្ងរខ្លាំង។ អង្គជំនុំជម្រះបានកត់សម្គាល់ថា មនុស្សរាប់ពាន់នាក់ត្រូវបានឃុំនៅក្នុងមន្ទីរឃុំឃាំង ដោយមិនមានការការពារផ្នែកផ្លូវច្បាប់ណាមួយឡើយ ដែលជាកន្លែងពួកគេទាំងនោះត្រូវស្ថិតក្នុងលក្ខខណ្ឌដ៏គួរឱ្យរន្ធត់ របបអាហារមិនគ្រប់គ្រាន់ ទទួលរងការវាយដំជាប្រចាំ ការធ្វើទារុណកម្មដ៏ឃោរឃៅ និងការសម្លាប់។

[១៥:១៨:១៧]

អង្គជំនុំជម្រះក៏បានរំឭកផងដែរថា អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាម ប្តីប្រពន្ធត្រូវបានបង្ខំឲ្យរៀបការ និងរួមដំណេក។ មនុស្សរាប់ពាន់នាក់នៅតាមសហ-ករណ៍និងការដ្ឋាន ត្រូវបានធ្វើឲ្យទៅជាទាសករក្នុងលក្ខខណ្ឌឃោឃៅ ដែលជាលទ្ធផលនាំឲ្យមានការស្លាប់បាត់បង់ជីវិតជាច្រើន។ ហើយឧក្រិដ្ឋកម្មទាំងនេះបានប៉ះពាល់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដល់ជនរងគ្រោះនិងគ្រួសាររបស់ពួកគេ។ ការដក -- ការរំលោភសេពសន្ថវៈនៅមន្ទីរសន្តិសុខក្រាំងតាចាន់ចេញក៏ដោយក៏មិនធ្វើឲ្យការសន្និដ្ឋានអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មគ្មានសុពលភាពឡើយ។ ដូច្នេះ អំណះអំណាងនេះទទួលបាន -- មិនទទួលបានជោគជ័យទេ។

ការអះអាងបន្ទាប់សម្រាប់បណ្តឹងសាទុក្ខលើកឡើងមិនត្រឹមត្រូវថាជាការកំណត់ទោសគាត់មានលក្ខណៈធ្ងន់ធ្ងរ ពីព្រោះការចូលរួមដោយប្រយោលដូចជាការជួយ និងការជំរុញ ជាធម្មតានាំឲ្យមានការកំណត់ទោសស្រាលជាង។ មានបញ្ហាបីនៅក្នុងការអះអាងរបស់គាត់ ទី១ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី ថៃល័រ បានសម្រេចថា វាគឺជាកំហុសឆ្គងអង្គច្បាប់ក្នុងការសន្និដ្ឋានថា ការជួយនិងជំរុញជាទូទៅធានាឲ្យមានការកំណត់ទោសតិចជាង សម្រាប់គោលបំណងនៃការកំណត់ទោសមិនមានឋានានុក្រមសម្រាប់ទម្រង់នៃការចូលរួមក្នុងឧក្រិដ្ឋកម្មទេ។ ទី២ ម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោសផងដែរ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនតាមរយៈការចូលរួមចំណែកដ៏សំខាន់របស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមមិនមែនតែជាការជួយ និងការជំរុញនោះទេ។ ទី៣ ប្រហែលជាសំខាន់បំផុតនោះមិនមែនការផ្តោតទៅលើទម្រង់នៃការចូលរួមបែបអរូបិយជាជាងផ្តោតលើការចូលរួមជាក់ស្តែង មិនមែនជាការអះអាងត្រឹមត្រូវនោះទេ។ ការកំណត់ទោសត្រូវតែមានលក្ខណៈឯកត្តបុគ្គល ផ្អែកលើការប្រព្រឹត្តរបស់ជនជាប់ចោទ។

សេចក្តីសង្ខេប និងភស្តុតាងជាមូលដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង បានធ្វើយ៉ាងត្រឹមត្រូវដោយរៀបរាប់លម្អិតអំពីរបៀបដែលសមាជិកភាពរបស់ ខៀវ សំផន នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស និងវត្តមានរបស់គាត់ក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បញ្ជាក់ថា គាត់បានដឹង បានចូលរួមក្នុងការប្រជុំនានា ដែលក្នុងនោះផែនការសេដ្ឋកិច្ច និងជោគវាសនារបស់ខ្មាំងត្រូវបានពិភាក្សា និងសម្រេច។

[១៥:២១:២៦]

អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា នៅក្នុងសុន្ទរកថា បទសម្ភាសន៍ សេចក្តីថ្លែងការណ៍

និងការប្រជុំជាច្រើន ជនជាប់ចោទ ខៀវ សំផន បានផ្សព្វផ្សាយ បានអនុម័ត និងបានការពារផែនការរួម និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដើម្បីកាន់តែជាក់លាក់ជាងនេះទៅទៀតនោះ គាត់បានផ្សព្វផ្សាយវោហាសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាយ៉ាងសកម្ម ដែលបានអំពាវនាវឱ្យមានការប្រព្រឹត្តបែបរើសអើងចំពោះជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា។ គាត់បានអំពាវនាវយ៉ាងចំហឱ្យសម្លាប់អ្នកដែលក្បត់បក្ស ឬបដិវត្តន៍។ គាត់បានណែនាំក្រសួងនានាឱ្យរៀបចំអាពាហ៍ពិពាហ៍ ដើម្បីឱ្យគូស្រករទាំងនោះអាចបង្កើតកូន ហើយគាត់ក៏បានលើកទឹកចិត្តឱ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាឱ្យអនុវត្តគោលនយោបាយ ទោះក្នុងតម្លៃណាក៏ដោយ។ ទោះបីដឹងថា ប្រជាជនកំពុងស្ថិតក្នុងការរស់នៅ និងលក្ខខណ្ឌការងារអមនុស្សធម៌ក៏ដោយ។

អង្គជំនុំជម្រះក៏បានពិចារណាផងដែរថា ដោយហេតុថា ប្រជាជនកម្ពុជាបានទុកចិត្ត និងគោរពគាត់ ការអនុម័តជាសាធារណៈទាំងអស់នេះ បានផ្ដល់នូវភាពស្របច្បាប់ដល់គោលនយោបាយនានា និងបានធ្វើឱ្យឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងកាន់តែសកម្ម។ ក្រោយពីពិចារណាលើចំណុចទាំងអស់នេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការចូលរួមរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងឧក្រិដ្ឋកម្មទាំងនោះមានលក្ខណៈធំធេង និងមានឥទ្ធិពលខ្លាំងក្លា ហើយការដាក់ទណ្ឌកម្មស័ក្ដិសមនោះគឺការជាប់ពន្ធនាគារអស់មួយជីវិត។ អំណះអំណាងដែលអរូបិយរបស់គាត់មិនផ្លាស់ប្ដូរភស្តុតាងជាក់ស្តែង ដែលអង្គជំនុំជម្រះបានពិចារណាយ៉ាងត្រឹមត្រូវនោះឡើយ។

[១៥:២៣:២៤]

ត្រឡប់មកនិយាយអំពីស្ថានសម្រាលទោសវិញ។ ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងថា ដោយសារគាត់បានទទួលការដាក់ទោសខ្ពស់បំផុត អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាលើស្ថានសម្រាលទោសតាមការចង់បានរបស់គាត់។ វាជាច្បាប់ដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ដែលថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការសម្រេចថា តើទម្ងន់ណាមួយប្រសិនបើមាន ខ្លួននឹងកំណត់ទៅលើស្ថានសម្រាលទោស។ ការប្រើពាក្យពេចន៍ "ប្រសិនបើមាន" មានន័យថា មិនមានលក្ខខណ្ឌតម្រូវដែលថា ទម្ងន់ណាមួយត្រូវកំណត់នោះទេ។ ចំណុចនេះស្របនឹងមាត្រា៩៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាដែលចែងថា តុលាការអាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស ក្នុងសាលដីកាក្នុងរឿងក្ដី មូស៊ីម៉ា ក៏បានបញ្ជាក់ច្បាស់ដែលថា សូម្បីតែនៅពេលដែលស្ថានសម្រាលទោសអង្គជំនុំជម្រះសាលាដំបូងនៅតែអាចដាក់ការកំណត់ទោសខ្ពស់បំផុត ប្រសិនបើភាពធ្ងន់ធ្ងរនៃបទល្មើសតម្រូវឱ្យ

ធ្វើដូច្នេះ។

[១៥:២៥:០០]

ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងពិរុទ្ធភាពរបស់ម្ចាស់បណ្តឹងសាទុក្ខចាំបាច់ត្រូវផ្តន្ទាទោសធ្ងន់បំផុតទោះជាស្ថាន មានស្ថានសម្រាលក៏ដោយ។ ប៉ុន្តែបណ្តឹងសាទុក្ខនេះខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះមានកំហុសក្នុងការសន្និដ្ឋាន មិនមានកត្តាសម្រាលទោសនោះទេ។ ឧទាហរណ៍ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីកិច្ចសហការ មិនបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវក្នុងការទទួលបានការបន្ធូរបន្ថយទោស។ កិច្ចសហការត្រូវតែមានលក្ខណៈពិសេស ទោះបីជាអាកប្បកិរិយាល្អ និងការអនុវត្តតាមច្បាប់ត្រូវបានរំពឹងទុកចំពោះជនជាប់ចោទម្នាក់ៗ។ ទោះជាទទួលយកថា អំណះអំណាងរបស់គាត់ពិតក្តី ក៏គាត់គ្រាន់តែបញ្ជាក់ថាគាត់បានចូលរួមក្នុងរឿងក្តីរបស់គាត់ប៉ុណ្ណោះ គឺជាអ្វីដែលបានរំពឹងទុក មិនមែនជាករណីពិសេសទេ។ ស្រដៀងគ្នានេះដែរ ការអះអាងរបស់គាត់ដែលថា-- ឯកឧត្តមប្រធានសហការីខ្ញុំថាស្តាប់ភាសាអង់គ្លេសអត់បាន។

**ប្រធានអង្គជំនុំ៖**

សូមសហព្រះរាជអាជ្ញាជាតិហ្នឹងគឺនិយាយសាដើមឡើងបន្តិច ពីរបីនាទីមុន ព្រោះដាច់អ៊ីនធឺណេត។ ឥឡូវភ្ជាប់វិញបានហើយ។ បាទ សូមអញ្ជើញបន្ត!

**លោកស្រី ជា លាង៖**

អរគុណឯកឧត្តមប្រធាន។ ខ្ញុំនឹងចាប់ផ្តើមពីកិច្ចសហការឡើងវិញ។

**ប្រធានអង្គជំនុំ៖**

និយាយពីស្ថានសម្រាលទោសមកតែម្តងមក បាទ។

**លោកស្រី ជា លាង៖**

ឧទាហរណ៍ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីកិច្ចសហការ មិនបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវក្នុងការទទួលបានការបន្ធូរបន្ថយទោស។ កិច្ចសហការត្រូវតែមានលក្ខណៈពិសេស ទោះបីជាអាកប្បកិរិយាល្អ និងការអនុវត្តតាមច្បាប់ត្រូវរំពឹងទុកចំពោះជនជាប់ចោទម្នាក់ៗ។ ទោះជាទទួលយកថា អំណះអំណាងរបស់គាត់ពិតក្តី ក៏គាត់គ្រាន់តែបញ្ជាក់ថាគាត់បានចូលរួមក្នុងរឿងក្តីរបស់គាត់ប៉ុណ្ណោះ គឺជាអ្វីដែលបានរំពឹងទុក មិនមែនជាករណីពិសេសទេ។ ស្រដៀងគ្នានេះដែរ ការអះអាងរបស់គាត់ដែលថា គាត់មិនបានរារាំងកិច្ចការរបស់តុលាការ ទោះជាមានការកាត់ទោសគាត់ជាប់

ពន្ធនាគារមួយជីវិតក្នុងសំណុំរឿង០០២/០១ ក៏ដោយ នោះក៏មិនគ្រប់គ្រាន់ ដើម្បីទទួលបានការបន្ធូរបន្ថយទោសដែរ។ ក្នុងរឿងក្តី ណាឡេទីលិក និង ម៉ាទីណូវិច, ណាឡេទីលិក បានតវ៉ាថា ការកាត់ទោសរបស់គាត់គួរតែត្រូវបានបន្ធូរបន្ថយ ដោយសារតែគាត់បានផ្តាក់ខ្លួនឈឺ គាត់មិនបានស្នើសុំឈប់សម្រាក ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា ការដែលមិនបានរារាំងដល់ការជំនុំជម្រះ គឺមិនគ្រប់គ្រាន់ទេ ដើម្បីបានការបន្ធូរបន្ថយទោស បើតាមឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែល ណាឡេទីលិក ត្រូវបានកាត់ឱ្យជាប់ទោស។ នេះគឺដូចគ្នាទៅនឹងអ្វីដែលមាននៅទីនេះដែរ។

អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីអាយុរបស់គាត់ក៏បរាជ័យផងដែរ។ សាលាដីកាបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តី នីយីថេហ្គេហ្កា ចែងថា អាយុមិនផ្តល់សិទ្ធិដោយស្វ័យប្រវត្តិដល់ជនជាប់ចោទទទួលបានលក្ខខណ្ឌចំពោះការកាត់ទោសរបស់គាត់ដែរ។ អង្គជំនុំជម្រះគ្រាន់តែតម្រូវឱ្យពិចារណាលើភស្តុតាងនៃកាលៈទេសៈបន្ធូរបន្ថយទោស ពេលធ្វើការសម្រេចចុងក្រោយរបស់ខ្លួនប៉ុណ្ណោះ។ ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ថា អាយុរបស់គាត់ត្រូវបានផ្តល់ឱ្យនៅទម្ងន់តិចតួចបំផុត និយាយម្យ៉ាងទៀតអង្គជំនុំជម្រះបានអនុវត្តតាមលក្ខខណ្ឌតម្រូវយ៉ាងពិតប្រាកដ គឺថាអង្គជំនុំជម្រះបានពិចារណាលើកត្តាបន្ធូរបន្ថយ។ ការមិនយល់ស្របរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការផ្តល់ទម្ងន់នេះ មិនអាចបដិសេធការអនុវត្តឆន្ទានុសិទ្ធិត្រឹមត្រូវរបស់អង្គជំនុំជម្រះឡើយ។

[១៥:៣០:១១]

ទាក់ទងនឹងសុខភាព។ បញ្ហាសុខភាពដែលមានជំងឺអាចនឹងត្រូវបានពិចារណាសម្រាប់ការបន្ធូរបន្ថយតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ។ រឿងក្តី មីឡានស៊ីមិច ដែលបានយោងនៅក្នុងអង្គជំនុំជម្រះសាលាដំបូង គឺមានលក្ខណៈជាសេចក្តីណែនាំ ពីព្រោះសេចក្តីយោងនោះបានកត់សម្គាល់ថា ការកំណត់ស៊ីមិច ឱ្យអង្គុយនៅលើរទេះរុញ មិនតម្រូវការនូវឧបករណ៍ពិសេស និងការថែទាំប្រចាំថ្ងៃ មិនមានគុណវុឌ្ឍិគ្រប់គ្រាន់ជាកត្តាបន្ធូរបន្ថយបានទេ។ ប៉ុន្តែជារួម បង្កើតបានជាកាលៈទេសៈពិសេស។ យ៉ាងណាមិញ ម្ចាស់បណ្តឹងសាទុក្ខមិនបានធ្វើការបង្ហាញភស្តុតាងអំពីសុខភាពដែលមានជំងឺនៅក្នុងការជំនុំជម្រះទេ ហើយគាត់ក៏មិនបានបង្ហាញដូចគ្នានេះ នៅពេលដែលបណ្តឹងសាទុក្ខនោះដែរ។ គាត់គ្រាន់តែកត់សម្គាល់សេចក្តីថ្លែងការណ៍មួយនៅក្នុងរបាយការណ៍ឆ្នាំ២០០៨ ដែលថា មុខងារចងចាំ និងបញ្ញាញាណរបស់គាត់ទំនងជានឹងកាត់តែចុះធ្លាក់ ធ្លាក់ចុះបន្តិចម្តងៗទៅតាមអាយុ។ នៅក្នុងរឿងក្តី ស៊ីមិច លក្ខខណ្ឌវេជ្ជសាស្ត្រដែលអាចប៉ះពាល់ដល់អាយុកាលមធ្យមក្នុងពេលអនាគត មិនកាត់បន្ថយទោសជាស្វ័យប្រវត្តិ

ឡើយ។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់អ្វីលើសពីនេះ ដើម្បីបំពេញនូវលក្ខខណ្ឌនៃកាលៈទេសៈពិសេសទាំងនេះទេ។ សរុបសេចក្តីមក ពុំមានការអះអាងណាមួយដល់ម្ចាស់បណ្តឹងសាទុក្ខ បង្ហាញពីកំហុស និងការវាយតម្លៃរបស់អង្គជំនុំជម្រះឡើយ។ ការកាត់ទោសគាត់មួយជីវិត គួរត្រូវបានតម្កល់ ព្រោះនេះគឺជាផលដែលគាត់បានទទួលពីអំពើប្រព្រឹត្តរបស់គាត់។

ចាស សូមអរគុណឯកឧត្តមប្រធាន និងក្រុមប្រឹក្សា។ ហើយសូមប្រគល់វេទិកានេះទៅខាងភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពឯកឧត្តមប្រធានសវនាការ ឯកឧត្តម លោក លោកស្រីចៅក្រម លោកជំទាវ លោក លោកស្រីតំណាងការិយាល័យសហព្រះរាជអាជ្ញា មេធាវីការពារក្តី សហការីដែលជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជនជាទីគោរព។ ពាក់ព័ន្ធទៅនឹងបញ្ហាការកំណត់ទោសនេះ ខ្ញុំបាទនឹងលើកជាបួនចំណុចពាក់ព័ន្ធនឹង ទី១ សិទ្ធិរបស់បណ្តឹងរដ្ឋប្បវេណី។ បញ្ហាទី២ ពាក់ព័ន្ធទៅនឹងការលើកថា ចៅក្រមសាលាដំបូងមានភាពលម្អៀង យើងក៏លើកផងដែរអំពីភាពការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងពាក់ព័ន្ធទៅនឹងសកម្មភាពរបស់លោក ខៀវ សំផន ជាចំណុចចុងក្រោយ។

ជាបឋម ពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើចំណុចការកំណត់ទោសនេះ លោកមេធាវី គង់ សំអុន ដែលជាមេធាវីរបស់ជនជាប់ចោទមួយរូប បានលើកថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីគ្មានសិទ្ធិអ្វីទាល់តែសោះនៅក្នុងការលើកពាក់ព័ន្ធទៅនឹងការកំណត់ទោស។ ការលើកឡើងយ៉ាងដូច្នេះ គឺជាការភាន់ច្រឡំមួយដ៏ធំចំពោះសិទ្ធិនៅក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ជាការពិត មាត្រា វិធាន១០៥(១)(គ) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះបាននិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការកំណត់ទោសទេ។

[១៥:៣៥:០០]

ក៏ប៉ុន្តែ យើងមិនមែនកំពុងតែធ្វើបណ្តឹងអំពីការកំណត់ទោសទេ យើងគ្រាន់តែធ្វើការឆ្លើយតបទៅនឹងបណ្តឹងរបស់មេធាវីការពារក្តីចំពោះការកំណត់ទោសដែលជាបណ្តឹងសាទុក្ខតែប៉ុណ្ណោះ។ យើង

គ្រាន់តែធ្វើការ ឆ្លើយតបតែប៉ុណ្ណោះ ដូច្នេះនេះជាចំណុចដែលមិនមានការហាមឃាត់នៅក្នុងវិធានផ្ទៃក្នុងនេះឡើយ។ សិទ្ធិរបស់យើងត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលតាមរយៈសេចក្តីសម្រេចពីរដងរួច មកហើយគឺសេចក្តីសម្រេច F10/2 និង F52/1 ដែលថាដើមបណ្តឹងរដ្ឋប្បវេណីអាចឆ្លើយតបទៅនឹង សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី កាលបើការឆ្លើយតបត្រូវបានកម្រិតទាក់ទងទៅនឹងមូលហេតុនានាដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិនិងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយចម្លើយនោះមិនមានភាពជាន់គ្នាទៅនឹងបញ្ហានានា ដែលត្រូវបានលើករួចមកហើយដោយខាងសហព្រះរាជអាជ្ញា។

[១៥:៣៦:២៣]

ពាក់ព័ន្ធទៅនឹងចំណុចសិទ្ធិនេះ យើងអាចមើលនៅក្នុងសាលក្រម០០១ សំណុំរឿង០០១ ដែលនៅក្នុងនោះមានយោបល់ដាច់ដោយឡែករបស់លោកចៅក្រម ឡាវែន៍ បាននិយាយអំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ គឺជាភាគីនៃដំណើរការនីតិវិធី ហើយលើកលែងតែវិធានផ្ទៃក្នុងចែងច្បាស់អំពីការហាមឃាត់ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬបានរឹតត្បិតសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្បាស់លាស់នោះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកថា ទទួលសិទ្ធិ និងកាតព្វកិច្ចដូចគ្នាទៅនឹងភាគីដទៃទៀត។ ជាការពិតការចូលរួមរបស់ដើម្បីបណ្តឹងរដ្ឋប្បវេណី គឺដើម្បីគាំទ្រអយ្យការ មិនមែនធ្វើឡើងដើម្បីគ្រាន់តែទាមទារសំណងតែប៉ុណ្ណោះទេ។នេះគឺជាមធ្យោបាយមួយដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមដើម្បីទាមទារសិទ្ធិដែលទទួលបានការពិតនិងយុត្តិធម៌ផងដែរ ហើយក៏ជាមធ្យោបាយមួយដើម្បីសម្រេចបានគោលដៅចម្បងរបស់ អ.វ.ត.កគឺការបង្រួបបង្រួមជាតិ។ ដូចដែលលោកចៅក្រមឡាវែន៍ បានទទួលស្គាល់ ការបង្រួបបង្រួមជាតិអាចសម្រេចបានមួយផ្នែក តាមរយៈការដាក់ទណ្ឌកម្មនិងវិធានការដែលត្រូវអនុវត្តដើម្បីរារាំងការកើតឡើងវិញនូវបទឧក្រិដ្ឋ។ ចំណុចនេះក៏ប៉ះពាល់ផងដែរដោយសារប្រធានបទនៃការសុំអភ័យទោសដែលត្រូវទទួលរងឥទ្ធិពលពីការដាក់ទណ្ឌកម្ម ព្រមទាំងកត្តាដទៃទៀតដែលជាមូលដ្ឋានដូចជាអត្តចរិតរបស់ជនជាប់ចោទ ការជំរុញឲ្យធ្វើសកម្មភាព អាកប្បកិរិយារបស់គាត់ចំពោះជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងកម្រិតនៃការសោកស្តាយរបស់គាត់។

[១៥:៣៨:២៥]

តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមដល់ការបង្រួបបង្រួមជាតិ តាមរយៈការចូលរួមរបស់ពួកគាត់ក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺសំដៅថា ពួកគាត់អាចផ្តល់សក្ខីកម្ម

លើប្រធានបទទាំងនោះ ដែលមានទំនាក់ទំនងមិនអាចកាត់ផ្តាច់បានពីការបង្រួបបង្រួមជាតិ និងការផ្តន្ទាទោស។ គោលការណ៍ណែនាំពីច្បាប់ជាតិ និងច្បាប់អន្តរជាតិ បានគាំទ្រយ៉ាងខ្លាំងទៅលើទស្សនៈនេះដែលថា ដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានអនុញ្ញាតឲ្យដាក់សារណាលើការផ្តន្ទាទោស។ ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានដកចេញនូវការផ្តន្ទាទោសពីសិទ្ធិដ៏ធំទូលាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការលើកសារណាផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរឡើយ។

ជនរងគ្រោះដែលបានចូលរួមត្រូវបានអនុញ្ញាតឲ្យលើកសារណាស្តីពីការផ្តន្ទាទោសនៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែលជាតុលាការពិសេសនៅលីបង់ តុលាការពិសេសរបស់ករណីកូសូវ៉ូ និងតុលាការអ៊ី.អេ.ស៊ី ដែលជាតុលាការអាហ្វ្រិកខាងកើត។ កន្លែងនេះខ្ញុំសុំយោងទៅចម្លើយរបស់មេធាវីនាំមុខសារណារបស់មេធាវីនាំមុខ ដើមបណ្តឹងរដ្ឋប្បវេណី ផារ៉ាក្រាហ្វ កថាខណ្ឌ៨៦២។ ទោះបីជាអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់កន្លងមកនូវភាពខុសគ្នារវាងប្រព័ន្ធនៃការចូលរួមរបស់ជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៅ អ.វ.ត.ក ក្តី តែអង្គជំនុំជម្រះនេះបញ្ជាក់ដោយកត់សម្គាល់ថា នៅ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិក្នុងការចូលរួមច្រើនជាង ក្នុងនាមជាភាគីពេញសិទ្ធិនៃដំណើរការនីតិវិធី គឺសិទ្ធិច្រើនជាងសិទ្ធិដែលផ្តល់ជូនជនរងគ្រោះដែលបានចូលរួមនៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែលខ្ញុំបានលើកអម្បាញ់មិញទៅទៀត។ ហេតុដូច្នេះវាជាការគួរឲ្យភ្ញាក់ផ្អើលប្រសិនបើនៅ អ.វ.ត.ក ដែលជាតុលាការជំនុំជម្រះអន្តរជាតិតែមួយដែលមានការចូលរួមរបស់ជនរងគ្រោះជាភាគី គឺសិទ្ធិរបស់យើងជាភាគីត្រូវបានបដិសេធនៅក្នុងការឆ្លើយតបទៅលើបញ្ហាផ្តន្ទាទោស។ ចំណុចទី២ ដែលពាក់ព័ន្ធទៅនឹងបញ្ហាចោទប្រកាន់ថាចៅក្រមសាលាដំបូងលម្អៀង ជាពិសេសលោកមេធាវី គង់ សំអុន បានលើកឡើងថា បើរាំងននខាងមុខមានការលម្អៀង ខ្លឹមសារខាងក្នុងក៏មានការលម្អៀងដែរ។ វាមិនដូច្នេះទេ រាំងននខាងមុខគឺមិន -- គ្រាន់តែការបញ្ជាក់ ដោយប្រើពាក្យដើមបណ្តឹងរដ្ឋប្បវេណីជាជនរងគ្រោះមុនពាក្យសាធារណជនមិនបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងឡើយ នៅក្នុង ផារ៉ាក្រាហ្វ កថាខណ្ឌ៤៣, ៤៨ នៃសាលក្រមសំណុំរឿង០០២របស់ខ្លួន។ ចំពោះបញ្ហាផ្នែកខាងក្នុងមិនអាចសន្និដ្ឋានថាមានភាពលម្អៀងដែរ គឺគេត្រូវមើលអំពីករណីជាក់លាក់មួយៗ ហើយលើកយកអំពីករណីដែលភាគីការពារក្តីចង់បញ្ជាក់ថាមានករណីលម្អៀង។ ដូចមេធាវីការពារក្តីកំពុងតែធ្វើនៅពេលនេះដូច្នេះដែរ។

[១៥:៤២:១៩]

ពាក់ព័ន្ធទៅនឹងបញ្ហាទី៣ ដែលយើងខ្ញុំចង់លើក គឺថា សិទ្ធិគួរតែផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី

នៅក្នុងការចូលរួម។ ដើមបណ្តឹង -- គឺខ្លឹមសារនៃសក្ខីកម្ម និងព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ហើយ ដែលត្រូវយកមកពិចារណាអំពីស្ថានទម្ងន់ និងស្ថានសម្រាលទោស ព្រមទាំងធាតុផ្សំនៃបទល្មើស ផងដែរ។ មេធាវីការពារក្តីចង់បញ្ជាក់ថា អង្គជំនុំជម្រះមានកំហុសដោយសារផ្តល់ទម្ងន់មិនត្រឹមត្រូវទៅ លើការបង្ហាញដល់ជនរងគ្រោះដែលរស់រានមានជីវិត ក្រុមគ្រួសាររបស់ពួកគេ សាក្សី និងសាធារណ ជនថា "ច្បាប់ត្រូវបានយកមកអនុវត្ត"។ ឃ្លាកន្លែងនេះក៏មិនត្រូវយកមកថា សាលាដំបូងគឺប្រាកដមាន លក្ខណៈលម្អៀងផងដែរ។ អ៊ីចឹងព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអាចជាប្រយោជន៍នៅក្នុង ការកំណត់អំពីធាតុផ្សំនៃបទល្មើស និងស្ថានទម្ងន់ និងស្ថានសម្រាល។ យើងខ្ញុំសូមលើកបីករណីដែល បញ្ជាក់អំពីភាពសាហាវឃោរឃៅដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ហើយការឈឺចាប់ដ៏ធ្ងន់ធ្ងរ ដែលពួកគាត់បានទទួលរងគឺមានលក្ខណៈធំធេង ហើយលើកបីរូបនេះគឺមិនមែនន័យថាមានតែប៉ុណ្ណេះទេ គឺដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងបានទទួលរងច្រើនណាស់ភាពធ្ងន់ធ្ងរ ការឈឺចាប់ដ៏ធំធេង ហើយ ដែលកំពុងបន្តមានរហូតមកដល់ពេលនេះ។

[១៥:៤៤:00]

ជាក់ស្តែងដើមបណ្តឹងរដ្ឋប្បវេណី ជុំ មុី នៅក្នុងឯកសារ E1/418.1 បានថ្លែងនៅក្នុងសក្ខីកម្ម របស់គាត់អំពីអ្វីដែលលោកបានទទួលរងនៅមន្ទីរសន្តិសុខ ស-២១ ថា នៅពេលដែលគាត់ត្រូវគេចាប់ គាត់បាននិយាយថា៖ ["បងៗសូមជួយមើលគ្រួសារខ្ញុំផង។ ពេលហ្នឹងវាធាក់ចង្កេះខ្ញុំដួលផ្កាប់មុខ វាចាប់ ទាញសក់ក្បាលខ្ញុំឡើង "អាចុយម៉ាយ ផ្តាំផ្ញើអីទៀតហ្អែង គេកម្ទេចទាំងអស់ហ្នឹង អង្គការកម្ទេចទាំង អស់ហ្នឹង។"] ពេលក្រោយមកទៀត លោក ជុំ មុី បាននិយាយថា៖ "រហូតទៅដល់ម៉ោងមួយ វាយកខ្ញុំ ទៅសួរចម្លើយនៅអគារខាងត្បូងហ្នឹង អគារA ខាងលើ ជាន់លើនោះវើសួរចម្លើយតែម្តង។ ពេលហ្នឹងវា សួរខ្ញុំថា៖ ["មើល៍! ហ្អែងៗឆ្លើយត្រង់មើលអាចុយម្រាយ គ្នាហ្អែងមានប៉ុន្មាននាក់ចូលសេ.អ៊ី.អា ចូល កា.ហ្សេ.បេ?" ខ្ញុំជម្រាបគេថា "ខ្ញុំអត់ស្គាល់ទេ" មុនដំបូងខ្ញុំថា អត់ស្គាល់ទេមិត្ត គេនិយាយមកលើខ្ញុំ "កណ្តួយម៉ែហ្អែង មិត្តអីជាមួយអញ អញមានមិត្តអីជាមួយឯង បើឯងក្បត់ជាតិទេតើ" ពេលនោះ គេ វាយខ្ញុំផ្ទូងៗ យកដែរវងអ៊ីចឹងបាក់កូនដៃ អាកូនដៃនេះបាក់ហើយនៅពេលនេះ។ បន្ទាប់មកទៀត វាដក ក្រចកមេជើងយើងម្ខាងបាត់ ដកក្រចកមេជើងម្ខាង វាដកទាញអត់ដាច់វាកន្ត្រាក់ៗអ៊ីចឹង! យើងចង់ សន្លប់ អាជើងម្ខាងវាដកដែលអាច -- តែអត់ដករួចទេ។"] ដើមបណ្តឹងរដ្ឋប្បវេណី ជុំ មុី ក៏បាននិយាយ អំពីការធ្វើទារុណកម្មដោយយកខ្សែភ្លើងយកមកឆក់នៅក្នុងរន្ធត្រចៀករបស់គាត់ផងដែរ។

ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ក៏បានលើកអំពីការឈឺចាប់ពីការបាត់បង់សមាជិកគ្រួសាររបស់គាត់ជាច្រើននាក់ដោយនៅខេត្តក្រចេះ គឺនៅក្នុងឯកសារ E1/394.1 ដែលនៅក្នុងនោះលោកបាននិយាយថា៖ ["ខ្ញុំបាទបានបាត់បង់ជីវិតមនុស្សនៅក្នុងក្រុមគ្រួសារខ្ញុំបាទហ្នឹង សរុប១៣នាក់ហ្នឹងគឺពិតមែន" ក្នុងនោះមានឪពុកក្មេក ចាយ គឹមអេង។ ទន្ទឹមនឹងដែរក៏បាត់បង់ក្រុមគ្រួសារប្រពន្ធកូនរបស់ខ្ញុំផង គឺលោកតា អ៊ុច ស៊ុនលី ហៅ តាំងឆាយ ដែលជា -- ក៏ត្រូវបាត់បង់ដោយគ្រាន់តែគាត់រកដើមព្រិចងាប់ៗ ហើយយកមកដុតដើម្បីធ្វើធូប គាត់នមស្ការព្រះរតនៈត្រ័យ ហើយពួកកងឈ្លបដែលបានមើលឃើញ វាថា "ស្អី! ព្រះរតនៈត្រ័យអី ទៅៗ! ព្រះពុទ្ធជាទីពឹង ទីរឭកឬអី?" ពេលនោះគេចាប់ចងគាត់អូសយកទៅ។ ក្នុងនោះដែរ ការចាប់ចងអូសមានឈ្មោះសមមិត្ត យាន ជាអ្នកមកប្រាប់ថា "ឪពួឡាយឯងនោះជឿងាប់ហើយ នៅព្រះពុទ្ធសាសនានោះ"]។ ហើយពីពេលនោះមក គាត់ក៏បាត់ខ្លួន។ ចំណែកឯប្រពន្ធរបស់លោក អ៊ុច ស៊ុនឡាយ ឈ្មោះ សា គឹមនី និងកូនៗរបស់គាត់ ដោយសារត្រូវបានចោទប្រកាន់ថា ជាវៀតណាម ត្រូវបានយកទៅសម្លាប់នៅកោះទ្រុង ហើយគេក៏បាននិយាយថា "មិត្តឯងមានគុណសម្បត្តិខ្ពស់ណាស់នឹងបក្សកម្មកររបស់យើង សមមិត្តបានខំបំពេញការងារកម្ចាត់ធាតុដើមលះបង់ខ្ពស់ជូនបក្ស វណ្ណៈកម្មករ កសិករ តែប្រពន្ធកូនរបស់សមមិត្ត យើងខ្ញុំបានប្រមូលយកទុកមួយដុំហើយ សូមសមមិត្តកាត់សាច់ស្អុយនេះចោលចុះ"។ នេះគឺជាប្រពន្ធកូនរបស់លោក អ៊ុច ស៊ុនឡាយ ដែលគេនិយាយថា ជាសាច់ស្អុយ។

[១៥:៤៨:០៣]

ចំពោះលោកស្រី អ៊ុង រ៉ន នៅក្នុងឯកសារ E1/307.1 លោកស្រីបានលើកអំពីការឈឺចាប់ដែលលោកស្រីធ្វើការនៅមូលដ្ឋាន គឺលោកបាននិយាយថា "ចាស ធ្វើការហ្នឹងហាលភ្លៀងនៅលើគោកផងយើងយ៉ាប់ប៉ុនណា ចុះទម្រាំតែខែភ្លៀងទៀត។ ទី១ រែកឡើងអត់រួចទេ រអិលជើងកាត់កូនឈើដាក់កល់ធ្វើជណ្ដើរ តែដល់ភ្លៀងខ្លាំងជោគជាំខ្លាំងមែនទែនទឹកក្រោមជង្គង់ទៅ ភ្លៀងខ្ពោកៗ។ ឧទាហរណ៍និយាយឲ្យអស់ ធម្មតាមនុស្សស្រីតែងតែមានរដូវឈាមហូរដូចអារកមាន់ ណាមកតស៊ូទ្រាំខ្លាចគេរៃចោល ណាខោខ្លីមិនដែលបើកឲ្យ អាវតូចក៏មិនដែលមាន គេមិនដឹង បើថាចំពោះខ្ញុំនៅ -- និងអ្នកដែលនៅរែកដីជាមួយគ្នាគឺរហែកអស់ហើយគ្មានសម្លៀកបំពាក់ និងគ្មានខោអាវទេ ហើយខោអាវតូចៗគឺបោកហាលនឹងចុងឈើ ហើយខ្លួនមានតែបន្តិចបន្តួចតែប៉ុណ្ណោះ ហើយក្រហមត្រាក់ទ្រិញហើយពេលមានរដូវម្ដងៗ បាត់អៀនបាត់ខ្មាស់អស់ហើយ។

ចំណុចទី៤ គឺយើងខ្ញុំសូមលើកពាក់ព័ន្ធទៅនឹងសកម្មភាពរបស់លោក ខៀវ សំផន--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីលើសចង់១០នាទីហើយៗ លោកប៉ុន្មានទៀតបានចប់?

[១៥:៤៩:៥៣]

**លោក ពេជ អង្គ៖**

បាទ សូមអនុញ្ញាតឯកឧត្តមប្រធានខ្ញុំត្រូវការ ៣នាទី ទៀតសូមអធ្យាស្រ័យ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទសូមអរគុណឯកឧត្តមប្រធាន។ ពាក់ព័ន្ធទៅនឹងចំណុចចុងក្រោយដែលជាចំណុចទី៤ របស់ខ្ញុំគឺអំពីសកម្មភាពរបស់លោក ខៀវ សំផន នៅក្នុងសំណុំរឿង០០២ វគ្គ២ នេះលោក ខៀវ សំផន មិនបានបង្ហាញនូវការសោកស្តាយ ឬក៏ការអាណិតអាសូរណាធំដុំឡើយ។ លោក ខៀវ សំផន ក៏មិនបានផ្តល់ចម្លើយពេញលេញនិងគ្រប់គ្រាន់ ដើម្បីជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យធូរស្បើយពីការឈឺចាប់របស់ពួកគាត់ឡើយ។ លោក ខៀវ សំផន មិនដែលទទួលខុសត្រូវចំពោះការរងទុក្ខរបស់ប្រជាជនកម្ពុជាឡើយ គាត់បន្ទោសតែអំពីការខ្វះអាហារ និងថ្នាំសង្កូវដែលជាការបន្ទោសទៅលើអាមេរិក និងសង្គ្រាមដោយអះអាងថា ខ្មែរក្រហមមិនដែលបង្អត់អាហារ ឬមិនដែលផ្តល់ថ្នាំសង្កូវ -- មិនដែលមិនផ្តល់ថ្នាំសង្កូវដល់អ្នកណាម្នាក់ដើម្បីជាការដាក់ទោសឡើយ។ គាត់មិនដែលទទួលស្គាល់អំពើឃោរឃៅ ឬក៏ឧក្រិដ្ឋកម្មណាមួយដែលប្រព្រឹត្តប្រឆាំងនឹងប្រជាជនកម្ពុជាឡើយ ប៉ុន្តែពួកគាត់ -- គាត់បែរជាបន្ទោសទៅភាគីវៀតណាម និងភាគីដទៃទៀតឡើយ។ ចំពោះការបង្ខំ ធ្វើការដោយបង្ខំ ការរំលោភ និងការកម្ទេចចោលក្រុមជនជាតិភាគតិច គាត់បានបដិសេធមិនដឹង មិនឮតែម្តង ហើយចំពោះមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង គាត់ក៏និយាយថាមិនដឹងអ្វីទាល់តែសោះ។

នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ៗនិយាយទាំងមិនទុកចិត្តថា គាត់ជាអ្នកច្រានចោលនៃអំពើឃោរឃៅដែលបានប្រព្រឹត្តចំពោះ -- ដែលស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានអះអាងថា ខ្មែរក្រហមត្រឹមតែជំរុញឲ្យប្រជាជនប្រឹងធ្វើការដើម្បីលើកស្ទួយប្រទេសជាតិ ពួកគេមិនដែលបង្ខំប្រជាជនឲ្យធ្វើការទេ ហើយការជម្លៀសចេញពីទីក្រុងគឺជាទម្រង់នៃការដាក់ទោសតែម្តង។

[១៥:៥២:២០]

ចំពោះសេចក្តីថ្លែងការរបស់លោក ខៀវ សំផន គាត់ចង់គោរពវិញ្ញាណក្ខន្ធទៅដល់ជនរងគ្រោះដែលគ្មានទោស មិនមែនជាការបញ្ជាក់អំពីការសោកស្តាយ ឬក៏ជាការអាណិតអាសូរដោយស្មោះត្រង់នោះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ នៅពេលដែលគាត់លើកអំពីការពាក់ព័ន្ធទៅនឹងការគោរពវិញ្ញាណក្ខន្ធដល់ជនរងគ្រោះ គាត់បានកត់សម្គាល់អំពីការកោតសរសើរ អំពីការខំប្រឹងរបស់យុទ្ធជន នៅក្នុងការវាយចូលភ្នំពេញដែលជាការអនុវត្តតាមគោលនយោបាយរបស់ថ្នាក់ដឹកនាំពេលនោះនៅក្នុងការគ្រប់គ្រងប្រទេសហើយទាំងនេះហើយ គឺជាសកម្មភាពដែលធ្វើឱ្យប្រជាជនកម្ពុជាមានការឈឺចាប់ ហើយនិងទុក្ខវេទនាគ្រប់បែបយ៉ាង។ ដូច្នេះសកម្មភាពរបស់លោក ខៀវ សំផន និងមិនសមធ្វើឱ្យលោកទទួលបាននូវការអនុគ្រោះបន្ធូរបន្ថយទោសបែបណាមួយឡើយ។ សូមអរគុណឯកឧត្តមប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តសូមអញ្ជើញចៅក្រមនៃអង្គជំនុំជម្រះ បើមានសូមអញ្ជើញសួរសំណួរ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

លោកប្រធាន ខ្ញុំមានសំណួរខ្លី នេះសំណួរសួរទៅកាន់សហព្រះរាជអាជ្ញា ខ្ញុំយល់ឃើញថា ពាក់ព័ន្ធទៅនឹងការផ្តន្ទាទោសលើការសេពសន្ថវៈនោះគឺថា វាថាតើៗនៅសហព្រះរាជអាជ្ញាយល់ឃើញថានេះវាជាកំហុសអត់ ដែលថាការផ្តន្ទាទោសលើការរំលោភសេពសន្ថវៈហ្នឹងគឺខុសហើយ?

**លោកស្រី រូថ ម៉ារី ហោកត្ល័រ៖**

សូមអរគុណលោកស្រីចៅក្រម នេះគឺយើងខ្ញុំយល់ឃើញថា អាស្រ័យទៅលើចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលជាអ្នកសម្រេច ពីព្រោះថានៅត្រឹមដំណាក់កាលនេះ មិនអាចទាន់ធ្វើមោឃភាពនៃសាលក្រមនេះបានទេ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

សំណួររបស់ខ្ញុំសួរថា តើទទួលស្គាល់ថា វាជា ទទួលថាវាជាកំហុសឬទេ ទោះបីវាមិនជាកំហុសធ្ងន់ធ្ងរក្តី?

[១៥:៥៥:០០]

**លោកស្រី រូថ ម៉ារី ហោកត្ល័រ៖**

លោកស្រីចៅក្រម! វាមិនច្បាស់ថា មានការបង្ហាញឱ្យហួសពីវិមតិសង្ស័យនៅក្នុងសាលក្រម

នោះទេ។ អ៊ីចឹងយោងទៅតាមយុត្តិសាស្ត្រវាអាចជាកំហុស។ ក៏ប៉ុន្តែនេះគឺថាវាអាចបំពេញលក្ខខណ្ឌទី២ នៃបទដ្ឋានក្នុងការវិនិច្ឆ័យទោសហើយ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

វាលើសពីនេះទៅទៀត អ្វីដែលមេធាវីការពារក្តី គឺថាគាត់មិនគួរត្រូវបានចោទប្រកាន់ពីបទចោទនេះផង កុំថាដល់ទៅការផ្តន្ទាទោស។ ខ្ញុំចង់ដឹងចំណុចហ្នឹង ថាតើនេះជាកំហុសអ៊ីចឹងដូចលើកឡើងមែនទេ?

**លោកស្រី រូថ ម៉ារី ហោកគ្គីរ៖**

លោកស្រីចៅក្រម សាលាដំបូងពិនិត្យមើលភស្តុតាងទាក់ទងទៅនឹងលក្ខខណ្ឌនៅតាមមន្ទីរសន្តិ-សុខ ពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ភាពសាហាវព្រៃផ្សៃ ក៏ដូចជាភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនេះ។ ក៏ប៉ុន្តែបើសិនជាចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាយ៉ាងណានោះ គឺថា សម្រេចទៅតាមនោះ ប៉ុន្តែយើងខ្ញុំនៅតែយល់ឃើញថា វាជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរហើយ។

**ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ៖**

សំណួររបស់ខ្ញុំសួរទៅកាន់សហព្រះរាជអាជ្ញាផងដែរ ថាតើមានយុត្តិកម្មក្នុងការផ្តន្ទាទោសមួយជីវិតចំពោះមនុស្សដែលមានអាយុ៩០ឆ្នាំហើយនេះដែរទេ? ពីព្រោះនៅតាមយុត្តាធិការផ្សេងៗវាមានគោលនយោបាយផ្តន្ទាទោសដែរ។ ទី១ គឺដើម្បីឱ្យរាងចាល ទី២ គឺដើម្បីតម្រូវការសង្គម។ តើសហព្រះរាជអាជ្ញា ថាតើមានកត្តាជំរុញអ្វីខ្លះ? ប៉ុន្តែតាមការយល់របស់សហព្រះរាជអាជ្ញា ថាតើការផ្តន្ទាទោសដាក់ពន្ធនាគារមនុស្សចាស់ដែលមានអាយុ៩០ឆ្នាំហើយនេះ មួយជីវិតនេះ ទៅលើអាមួយជីវិត យល់ថាយ៉ាងម៉េចដែរ?

[១៥:៥៧:៣៦]

**លោកស្រី រូថ ម៉ារី ហោកគ្គីរ៖**

សូមអរគុណលោកចៅក្រម។ ការពិចារណាបឋមទៅលើការផ្តន្ទាទោសនិយាយពីភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់របស់ជនជាប់ចោទនៅក្នុងស្ថានភាពនេះ គឺថាវាមានចំណុចសំខាន់ៗលេចធ្លោ ដូចខ្ញុំៗជឿជាក់ថានេះគឺជាការពិចារណាចម្បងដែលសាលាដំបូងបានប្រើប្រាស់ដើម្បីផ្តន្ទាទោសអស់មួយជីវិត។ ហើយនៅក្នុងសាលដីកាក្នុងកថាខណ្ឌ៣៩៦ នៅពេលដែលយើងមានស្ថានទម្ងន់ធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ អ៊ីចឹងការផ្តន្ទាទោសតម្រូវឱ្យធ្វើដូច្នេះឯង។ បើទោះណាជាមានស្ថានសម្រាលក្តី ក៏គេមិនអាចផ្តន្ទាទោសឱ្យ

ក្រោមការដាក់ទោសកម្រិតអតិបរមាបានដែរ។

[១៥:៥៨:៥២]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងយើងគ្មានសំណួរបន្តទៀតទេ គឺអង្គជំនុំជម្រះប្រកាសថា យើងផ្អាកនៅពេលនេះត្រឹមប៉ុណ្ណេះសិន ហើយនៅថ្ងៃស្អែកយើងនឹងបន្តនៅវេលាម៉ោងប្រាំបួនព្រឹក។ ហើយសូមមន្ត្រីខាងពន្ធនាគារនាំជនជាប់ចោទទៅទីកន្លែងវិញ ហើយនិងនាំមកវិញនៅថ្ងៃស្អែកនៅវេលាម៉ោងប្រាំបី សែសិបប្រាំនាទីដើម្បីបន្តសវនាការ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសផ្អាកសវនាការ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅ ម៉ោង១៦:០០នាទី)*